សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# វិធីសាស្ត្រស្រាវជ្រាវ និង
# ការសរសេរបែបសិក្សា

ហាប់ ផល្លី

ឆ្នាំ២០១៥

ឯកសារនេះត្រូវបានបង្កើតឡើង ដើម្បីជាជំនួយដល់ការសរសេរ ការនិពន្ធ និង ការសិក្សាស្រាវជ្រាវរបស់និស្សិត និងបញ្ញវន្តកម្ពុជា ជាពិសេសនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឲ្យប្រកបដោយគុណភាព និងមានលក្ខណៈអន្តរជាតិ។

©2014, 2013 by Phalthy Hap

រក្សាសិទ្ធិគ្រប់យ៉ាង ដោយបណ្ឌិត ហាប់ ផល្ធី, hphalthy@yahoo.com។

បណ្ឌិត ហាប់ ផល្ធី ជំនាញនីតិភូមិបាលបានៈ

-ចងក្រង កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី ពីឆ្នាំ ១៩៨៥ ដល់ឆ្នាំ២០១០ និងបោះពុម្ពលើកទី២ ឆ្នាំ២០១៤។

-បោះពុម្ព គុណធម៌នៃការសិក្សាស្រាវជ្រាវ, ឆ្នាំ២០១១។

-បកប្រែ Legal Terminology ដែលនិពន្ធដោយ GORDON W. BROWN និង បោះពុម្ពផ្សាយនៅឆ្នាំ២០១០ និង២០១១។

បោះពុម្ពនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ១. ការពិពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវ ផ្តល់ឱកាសឲ្យនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាមូលដ្ឋានសំខាន់ៗនៃការសរសេរបែបសិក្សា រួមមានវិធីបង្កើតប្រធានបទស្រាវជ្រាវ ការផ្តល់ប្រភពឯកសារ និងការលួចគំនិតអ្នកដទៃ។ និស្សិតក៏នឹងសិក្សាផងដែរពីប្រភេទនៃវិធីសាស្ត្រស្រាវជ្រាវ វិធីសាស្ត្រសរសេរនិក្ខេបបទ និងរបៀបសរសេរកិច្ចការស្រាវជ្រាវផ្សេងទៀត។ គុណភាពនៃការសរសេរបែបសិក្សា ដែលអាចឲ្យគេជឿជាក់ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងឡូស៊ិកគឺជាការចាំបាច់សម្រាប់ការសិក្សាកម្រិតខ្ពស់។

និស្សិតតម្រូវឲ្យត្រៀមខ្លួនជាស្រេច ពោលគឺអានអត្ថបទពាក់ព័ន្ធឲ្យបានច្រើន និងស្វែងយល់ បន្ថែម មុននឹងចូលរៀនក្នុងថ្នាក់។ ការពិភាក្សាគ្នាអំពីខ្លឹមសារមេរៀននៅក្នុងថ្នាក់គឺជាការចាំបាច់។ ក្រៅពីការពិភាក្សាគ្នានៅក្នុងថ្នាក់ និស្សិតម្នាក់ៗតម្រូវឲ្យធ្វើកិច្ចការស្រាវជ្រាវរៀងៗខ្លួន។ ប្រធានបទនៃកិច្ចការស្រាវជ្រាវគឺជាប្រធានបទដែលនិស្សិតជ្រើសរើសដោយសេរី។ និស្សិតគប្បីត្រៀមខ្លួនគិតពីប្រធានបទណាដែលខ្លួនគិតថាមានសារៈសំខាន់នៅក្នុងសង្គម គួរឲ្យចាប់អារម្មណ៍ និងមានប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវក្រោយៗទៀត។

## ២. វត្ថុបំណង

មុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវមានគោលបំណងឲ្យនិស្សិតយល់ដឹងអំពីរបៀបស្រាវជ្រាវ ការផ្តល់ ប្រភពឯកសារ និងការសរសេរប្រកបដោយក្រមសីលធម៌ខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ។

ក្រោយពីរៀនមុខវិជ្ជានេះចប់ និស្សិតអាចៈ

- បញ្ជាក់បានពីរបៀបផ្តល់ប្រភពឯកសារនៅពេលសរសេរយោង។

- ជៀសវាងការលួចគំនិតអ្នកដទៃ។
- វិភាគបញ្ហាសម្រាប់ការសិក្សាស្រាវជ្រាវបានល្អ។
- ស្រាវជ្រាវ និងសរសេរប្រកបដោយលក្ខណវិទ្យាសាស្ត្រមានគុណភាព និងគួរឲ្យជឿជាក់បាន។

## ៣. រង្វាយតម្លៃ

រង្វាយតម្លៃនិស្សិតសម្រាប់មុខវិជ្ជានីតិទ្រព្យសម្បត្តិសាធារណៈរួមមាន៖

- ពិន្ទុវត្តមាន៖ ១០% (និស្សិតត្រូវរៀនយ៉ាងតិច១២ពេលទើបអនុញ្ញាតឲ្យប្រឡងបញ្ចប់)
- ពិន្ទុកិច្ចការស្រាវជ្រាវ៖ ៤០%
- ពិន្ទុប្រឡងពាក់កណ្តាលវគ្គ៖ ផ្អែកលើពិន្ទុរង្វាន់ជារៀងរាល់ពេលចាប់ផ្តើម
- ពិន្ទុប្រឡងបញ្ចប់៖ ៥០%

ទោះជាយ៉ាងណាក៏ដោយ ភាគរយនៃការដាក់ពិន្ទុអាចនឹងប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងនៃថ្នាក់រៀន ទៅតាមការសម្រេចចិត្តរបស់សាស្ត្រាចារ្យបង្រៀន។

## ៤. ផែនការបង្រៀន

ផែនការបង្រៀនមុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវ ចែកចេញជា១៨សប្តាហ៍ ដែលក្នុងនោះនិស្សិតត្រូវចំណាយពេល១សប្តាហ៍ ដើម្បីចែករំលែកបទពិសោធន៍ពីគ្នាតាមរយៈការឡើងធ្វើបទបង្ហាញកិច្ចការស្រាវជ្រាវ។ ផែនការបង្រៀនលំអិតមានដូចតទៅ៖

| សប្ដាហ៍ | ខ្លឹមសារមេរៀន | ផ្សេងៗ |
|---|---|---|
| 1 | **សេចក្ដីផ្ដើមចំពោះវិធីសាស្ត្រស្រាវជ្រាវ**<br>• អត្ថន័យនៃការស្រាវជ្រាវ<br>• ការស្រាវជ្រាវបែបសិក្សា<br>• ហេតុអ្វីបានជាត្រូវការការស្រាវជ្រាវ? | និស្សិតទទួលបាននូវគោលការណ៍មួយចំនួនពីការសិក្សាសម្រាប់មុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវ |
| 2 | **ការបង្កើតប្រធានបទ**<br>• បញ្ហាស្រាវជ្រាវ<br>• សំណួរស្រាវជ្រាវ<br>• សម្មតិកម្ម | និស្សិតត្រូវបានប្រគល់កិច្ចការស្រាវជ្រាវ |
| 3 | **ការបង្កើតប្រធានបទ "តចប់"**<br>• អនុវត្តន៍ | និស្សិតស្រាវជ្រាវ |
| 4 | **វិធីសាស្ត្រសរសេរនិក្ខេបបទ**<br>• ការរៀបចំមាតិកា សេចក្ដីផ្ដើម និងសេចក្ដីសន្និដ្ឋាន | |
| 5 | **វិធីសាស្ត្រសរសេរនិក្ខេបបទ (តចប់)**<br>• ការសេរសង្ខេបសេចក្ដី<br>• អនុវត្តន៍ | |
| 6 | **ការផ្ដល់ប្រភពឯកសារ**<br>• សម្គាល់ក្រោមទំព័រ សម្គាល់ចុងអត្ថបទ សម្គាល់ក្នុងអត្ថបទ គន្ថនិទ្ទេស ឯកសារយោង<br>• ការផ្ដល់ប្រភពឯកសារទាក់ទងនឹងសៀវភៅ | |
| 7 | **ការផ្ដល់ប្រភពឯកសារ (ត)**<br>• សម្គាល់ក្រោមទំព័រ សម្គាល់ចុងអត្ថបទ សម្គាល់ក្នុងអត្ថបទ គន្ថនិទ្ទេស ឯកសារយោង<br>• ការផ្ដល់ប្រភពឯកសារទាក់ទងនឹងប្រភពផ្សេងៗ | |

| | | |
|---|---|---|
| 8 | ការផ្តល់ប្រភពឯកសារ (តចប់)<br>• សម្គាល់ក្រោមទំព័រ សម្គាល់ចុងអត្ថបទ សម្គាល់ក្នុងអត្ថបទ គន្ថនិទ្ទេស ដកសារយោង និងអនុវត្តន៍ | |
| 9 | ការលួចគំនិតអ្នកដទៃ<br>• គោលការណ៍សំខាន់ៗចំពោះការលួចគំនិតអ្នកដទៃ | |
| 10 | ការលួចគំនិតអ្នកដទៃ (ត)<br>• កំហុសផ្ទាល់ខ្លួនក្នុងការយោងទៅនឹងប្រភពអ្នកដទៃ | |
| 11 | ការលួចគំនិតអ្នកដទៃ (តចប់)<br>• អនុវត្តន៍ | និស្សិតប្រគល់កិច្ចការស្រាវជ្រាវ |
| 12 | ការបង្កើតសំណួរ<br>ការប្រើប្រាស់កាល | និស្សិតត្រៀមធ្វើបទបង្ហាញកិច្ចការស្រាវជ្រាវ |
| 13 | ការសរសេរកថាខណ្ឌ<br>• ប្រយោគចម្បង<br>• ប្រយោគគាំទ្រ<br>• ប្រយោគសន្និដ្ឋាន | |
| 14 | ប្រភេទនៃវិធីស្រាវជ្រាវ<br>• ការស្រាវជ្រាវបែបបរិមាណ<br>• ការស្រាវជ្រាវបែបគុណភាព | |
| 15 | បទបង្ហាញកិច្ចការស្រាវជ្រាវ | និស្សិតឡើងធ្វើបទបង្ហាញ |
| 16 | បទបង្ហាញកិច្ចការស្រាវជ្រាវ "ត" | និស្សិតឡើងធ្វើបទបង្ហាញ |
| 17 | បទបង្ហាញកិច្ចការស្រាវជ្រាវ "តចប់" | និស្សិតឡើងធ្វើបទបង្ហាញ |
| 18 | វាយតម្លៃ និងបញ្ចប់មេរៀន | |

# មាតិកា

**ការបង្កើតសំណួរ**......1
សំណួរបិទ......1
សំណួរបើក......3
សំណួរស្រាវជ្រាវ......4
**លក្ខណៈនៃការសរសេរ**......6
ការប្រើប្រាស់កាល......7
បច្ចុប្បន្នកាល......7
អតីតកាល......7
ការសរសេរកថាខណ្ឌ......8
ប្រយោគចម្បង......8
ប្រយោគគាំទ្រ......9
ប្រយោគសន្និដ្ឋាន......9
**ការបង្កើតប្រធានបទ**......10
**ការផ្តល់ប្រភពឯកសារ**......12
1. សៀវភៅ......15
2. សំបុត្រ និងឯកសារទំនាក់ទំនងផ្សេងៗដែលបានប្រមូលបោះពុម្ព......55
3. ការបោះពុម្ព......56
4. ស្នាដៃដែលមានច្រើនភាគ......60
5. សៀវភៅអេឡិចត្រូនិក......64
6. ជើនណល ទស្សនាវដ្តី និងកាសែត (Periodicals)......66
7. បទសម្ភាស និងទំនាក់ទំនងផ្ទាល់ខ្លួន......78

8. ឯកសារមិនបានបោះពុម្ពផ្សាយ និងបានបោះពុម្ពផ្សាយ
មិនផ្លូវការ ....................................................................................80
9. របាយការណ៍ និងលិខិតបោះពុម្ពផ្សាយផ្សេងៗ.....................88
10. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត.........................................90
11. ការយោងដូចគ្នានឹងការយោងមុនៗ ....................................98
12. អនុវត្តន៍ការផ្តល់ប្រភពឯកសារ .........................................101
13. អនុវត្តន៍ការតម្រៀបបញ្ជីប្រភពឯកសារ.............................105
**ការលួចគំនិតអ្នកដទៃ**...........................................................111
1. **គោលការណ៍សំខាន់ៗចំពោះការលួចគំនិតអ្នកដទៃ** ..113
1.1. ការដកស្រង់សំដីទាំងស្រុង.........................................113
1.1.1. ការដកស្រង់សំដីទាំងស្រុងដោយដាក់ក្នុង
អព្ភន្តរសញ្ញា ប៉ុន្តែមិនបានបញ្ជាក់ប្រភព .............................114
1.1.2. ការដកស្រង់សំដីទាំងស្រុងដោយមិនដាក់ក្នុង
អព្ភន្តរសញ្ញា ប៉ុន្តែបញ្ជាក់ប្រភព .........................................125
1.1.3. ការដកស្រង់សំដីទាំងស្រុងដោយផ្នែកខ្លះនៅក្នុង
អព្ភន្តរសញ្ញា និងផ្នែកខ្លះនៅក្រៅអព្ភន្តរសញ្ញា ទោះមាន
បញ្ជាក់ប្រភពក៏ដោយ .......................................................126
1.2 ការប្រើប្រាស់ពាក្យពេចន៍ខ្លួនឯងដោយយោងទៅលើ
ប្រភពអ្នកដទៃ តែមិនបញ្ជាក់ប្រភព....................................128
2. **កំហុសផ្ទាល់ខ្លួនក្នុងការយោងទៅលើប្រភពអ្នកដទៃ** .133
2.1. កំហុសផ្ទាល់ខ្លួននៃការស្រង់សំដីទាំងស្រុង.................133
2.2. កំហុសផ្ទាល់ខ្លួននៃការប្រើពាក្យពេចន៍ផ្ទាល់ខ្លួនដោយ
យោងទៅនឹងប្រភពដទៃ ប៉ុន្តែយោងខុស............................137
**ការសរសេរសង្ខេបសេចក្តី**......................................................142

**ការសរសេរនិក្ខេបបទ**............................................................144
ជម្រើសទី១..............................................................144
ជម្រើសទី២ ..............................................................145

# ការបង្កើតសំណួរ

នៅផ្នែកនេះ និស្សិតអាចរៀបចំកម្រងសំណួរដើម្បីធ្វើការសម្ភាស ឬចុះសួរដោយផ្ទាល់។ សំណួរដែលប្រើញឹកញាប់ជាងគេគឺសំណួរពហុជ្រើសរើស និងមានសំណួរបើកមួយចំនួនដើម្បីទទួលបាននូវយោបល់របស់អ្នកដែលត្រូវគេសម្ភាស។

ផ្នែកនេះផ្តោតជាចម្បងទៅលើសំណួរបិទ សំណួរបើក និងសំណួរស្រាវជ្រាវ។

## សំណួរបិទ

សំណួរបិទជាសំណួរដែលតម្រូវឲ្យឆ្លើយជាកន្សោមពាក្យទោល ឬខ្លីៗ ឬក៏អាចឆ្លើយបាទ ឬចាស។ វាមានលក្ខណៈមួយចំនួនដូចខាងក្រោម៖[1]

- ផ្តល់ឲ្យនូវចម្លើយដែលជាការពិត ឬអង្គហេតុ។
- ងាយស្រួលឆ្លើយ។
- អាចឆ្លើយបានលឿន។
- រក្សានូវការត្រួតពិនិត្យរវាងកិច្ចសន្ទនា និងអ្នកសួរ។

សំណួរបិទមានរបៀបប្រើប្រាស់ងាយស្រួល មិនចង់ដឹងពីហេតុផលលំអិត ស្មុគស្មាញទេ។ វាជាសំណួរដែលគេចូលចិត្តប្រើនៅពេលផ្តើមនាពេលដំបូង។

[1] http://changingminds.org/techniques/questioning/open_closed_questions.htm ទស្សនាចុងក្រោយថ្ងៃទី០៥ មករា ២០១១។

- សំណួរបិទធ្វើឲ្យអ្នកឆ្លើយងាយឆ្លើយ និងមិនបង្ខំឲ្យអ្នកឆ្លើយធ្វើការលាតត្រដាងហេតុផលរបស់ខ្លួនទេ។
  - ខែធ្នូឆ្នាំនេះ អាកាសធាតុនៅប្រទេសកម្ពុជាត្រជាក់ល្មម។ តើពិតមែនទេ?
  - តើអ្នកក្រោកនៅម៉ោងប៉ុន្មានកាលពីព្រឹកមិញ?
  - តើអ្នកបានរស់នៅឯណា កាលពីមុនពេលមករស់នៅភ្នំពេញ?
  - តើអ្នកបានចាប់ផ្ដើមស្គាល់គាត់តាំងពីឆ្នាំណា?
  - តើអ្នកបានទៅលេងសហរដ្ឋអាមេរិកជាមួយអ្នកណា?
  - តើអ្នកឈ្មោះអ្វី?
  - តើអ្នកមានស្រុកកំណើតនៅឯណា?
- សំណួរបិទតម្រូវឲ្យអ្នកឆ្លើយផ្ដល់នូវចម្លើយបាទ ឬចាស ហើយវាមិនតម្រូវឲ្យផ្ដល់ហេតុផលទេ។
  - តើអ្នកចូលចិត្តទៅលេងមាត់សមុទ្រឬទេ?
  - តើអ្នកត្រូវការជំនួយពីខ្ញុំទេ?
  - តើការចរចារវាងរដ្ឋមន្ត្រីរវាងប្រទេសទាំងពីរបានបញ្ចប់ហើយឬនៅ?
  - តើអ្នកចង់បានបន្ទប់មានគ្រែពីរឬ?
- សំណួរបិទក៏អាចដឹងពីគំនិតរបស់អ្នកឆ្លើយ ថាតើមានគំនិតវិជ្ជមានឬអវិជ្ជមានចំពោះអ្វីមួយ ទោះជាប្រភេទចម្លើយបាទ ឬចាសក៏ដោយ។
  - តើអ្នកសប្បាយចិត្តនឹងការដឹកនាំរបស់ប្រធានាធិបតីថ្មីឬទេ?
  - តើអ្នកចូលចិត្តការបង្រៀនរបស់គាត់ឬ?
  - តើអ្នកពេញចិត្តនឹងការបំភ្លឺរបស់ខ្ញុំឬទេ?
  - តើអ្នកចង់រកអ្នកផ្ដល់សេវាថ្មីឬ?
  - តើការបង្រៀនរបស់គាត់លឿនពេកឬ?

**សំណួរបើក**

សំណួរបើកជាប្រភេទសំណួរដែលត្រូវការចម្លើយវែង ឬយោបល់របស់អ្នកឆ្លើយ។ វាបើកចំហឲ្យអ្នកឆ្លើយយល់ឃើញតាមគំនិតរបស់ខ្លួន។

ជាទូទៅ សំណួរបើកមានលក្ខណៈដូចខាងក្រោម៖[2]

- សួរអ្នកឆ្លើយឲ្យគិត និងឆ្លុះបញ្ចាំង។
- ផ្តល់ឲ្យអ្នកនូវគំនិត និងអារម្មណ៍។
- ត្រួតពិនិត្យការសន្ទនាចំពោះអ្នកឆ្លើយ។

- សំណួរបើកជជីកសួរអ្នកដែលស្ងាត់ស្ងៀម ដើម្បីឲ្យមានយោបល់។
  - ➢ តើអ្នកបានធ្វើអ្វីខ្លះនៅចុងសប្តាហ៍កន្លងទៅ?
  - ➢ តើអ្នកមានយុទ្ធវិធីរៀនយ៉ាងដូចម្តេច?
  - ➢ តើអ្នកបានរំឭកមេរៀនអ្វីខ្លះកាលពីរាត្រីកន្លងទៅ?
  - ➢ តើគាត់មករៀនដោយសារអ្វី?
- សំណួរបើកស្វែងរកនូវតម្រូវការ ចំណង់ចំណូលចិត្ត ឬបញ្ហារបស់អ្នកណាម្នាក់។
  - ➢ តើកត្តាអ្វីខ្លះដែលជួយអ្នកឲ្យរៀនពូកែ?
  - ➢ ហេតុអ្វីបានជាមេរៀននេះសំខាន់ណាស់ចំពោះអ្នក?
  - ➢ ហេតុអ្វីបានជាអ្នកមិនចូលចិត្តគាត់?
  - ➢ តើអ្វីដែលធ្វើឲ្យអ្នកទៅរៀនទាន់ម៉ោង?
  - ➢ តើអ្វីខ្លះជាឧបសគ្គក្នុងការសិក្សារបស់អ្នក?
- សំណួរបើកធ្វើឲ្យមនុស្សទទួលស្គាល់វិសាលភាពនៃបញ្ហាដែលត្រូវស្វែងរកដំណោះស្រាយ។

---

[2] http://changingminds.org/techniques/questioning/open_closed_questions.htm ទស្សនាចុងក្រោយថ្ងៃទី០៥ មករា ២០១១។

- តើមានអ្វីនឹងកើតឡើង ប្រសិនបើមេឃភ្លៀង?
- បើអ្នកទៅលេងកោះពេជ្រថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ តើមានអ្វីកើតឡើង?
- ប្រសិនបើការប្រកាសទ្រព្យសម្បត្តិត្រូវបានធ្វើជាសាធារណៈ តើមានអ្វីនឹងកើតឡើង?
- តើមានអ្វីនឹងកើតឡើងចំពោះលោក សំណាង ពេលគាត់ចេញទៅក្រៅតែម្នាក់ឯង?

- សំណួរបើកធ្វើឲ្យមនុស្សមានអារម្មណ៍ល្អប្រសើរ ឬធូរស្រាលក្នុងចិត្ត បន្ទាប់ពីត្រូវបានគេសួរទាក់ទងនឹងសុខភាព ឬទាក់ទងនឹងកង្វល់របស់គេចំពោះខ្លួន។

- តើសុខភាពរបស់អ្នកយ៉ាងដូចម្ដេចហើយ បន្ទាប់ពីបានទៅសម្រាកព្យាបាលនៅប្រទេសវៀតណាមមួយរយៈកន្លងមក?
- តើជីវភាពរបស់អ្នកយ៉ាងដូចម្ដេចដែរ តាំងពីមករស់នៅកន្លែងថ្មី?
- អ្នកហាក់ដូចជាស្រងូតស្រងាកចិត្ត តើមានអ្វីកើតឡើង?
- តើអ្នកមានភាពកក់ក្ដៅយ៉ាងណាដែរ តាំងពីរៀបការជាមួយនាងមក?
- បន្ទាប់ពីបានចាកចេញពីគ្រួសារភរិយារបស់អ្នក តើអ្នកមានសេចក្ដីសុខទុក្ខយ៉ាងណា?
- តើដំណាំរបស់អ្នកនៅលើដីដែលទើបនឹងទិញល្អយ៉ាងណាដែរ?

## សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវជាសំណួរដែលតម្រូវឲ្យធ្វើការស្រាវជ្រាវមុននឹងផ្ដល់ចម្លើយ។ វាក៏បិតក្នុងប្រភេទសំណួរបើកដែរ តែមានលក្ខណៈទូលំទូលាយ ដែលការឆ្លើយតម្រូវឲ្យផ្ដល់នូវទឡ្ហីករណ៍ច្បាស់លាស់ និងកើតចេញពីការស្រាវជ្រាវជាក់លាក់។

សំណួរស្រាវជ្រាវបញ្ជាក់ពីអ្វីដែលការសិក្សានឹងធ្វើការអង្កេត ឬមានបំណងនឹងធ្វើឲ្យចម្រើន។[3] សំណួរស្រាវជ្រាវត្រូវជាក់ច្បាស់ និងមិនត្រូវចង្អៀតពេក និងទូលាយពេក។ ជាទូទៅ សំណួរប្រភេទនេះត្រូវមានធាតុអថេរដែលអាចធ្វើពិសោធន៍ ឬស្រាវជ្រាវបាន។ វាត្រូវបញ្ជាក់ច្បាស់ថាតើការស្រាវជ្រាវត្រូវចាប់ផ្តើមពីណា។

- តើការផ្តល់សម្បទានដីសេដ្ឋកិច្ចជំរុញសេដ្ឋកិច្ចជាតិខ្មែរយ៉ាងដូចម្តេច?
- តើការមិនពាក់មួកសុវត្ថិភាពពេលបើកបរម៉ូតូមានផលប៉ះពាល់អ្វីខ្លះទៅលើជីវភាពរស់នៅរបស់ពួកគេ?
- តើការនេសាទខុសច្បាប់នៅរដូវបិទឡូត៍នេសាទមានទំនាក់ទំនង ដូចម្តេចទៅនឹងធារត្រីនៅរដូវសម្រក?
- តើអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាជះឥទ្ធិពលដល់សង្គមជាតិយ៉ាងដូចម្តេច?
- តើការចុះបញ្ជីដីធ្លីដោយដុំ ជួយជំរុញដល់ការប្រមូលពន្ធលើដីធ្លីយ៉ាងដូចម្តេច?

---

[3] http://www.sahs.utmb.edu/pellinore/intro_to_research/wad/res_ques.htm
ទស្សនាចុងក្រោយថ្ងៃទី០៦ មករា ២០១១។

# លក្ខណៈនៃការសរសេរ

ការសរសេរបែបសិក្សាទាមទារឲ្យអ្នកសរសេរ ចេះប្រើប្រាស់កាលត្រឹមត្រូវ។ ចំពោះកថាខណ្ឌនីមួយៗ ជាទូទៅមានធាតុផ្សំចំនួន ៣គឺ ប្រយោគចម្បង ប្រយោគគាំទ្រ និងប្រយោគសន្និដ្ឋាន។ ការសរសេរកម្រិតស្រាវជ្រាវ មានលក្ខណៈខុសគ្នាពីការសរសេរតែងសេចក្តីនៅកម្រិតចំណេះទូទៅ ដែលនៅទីនោះ សិស្សអាចរៀបរាប់អ្វីមួយទៅតាមការយល់ឃើញ និងចំណេះដឹងដែលពួកគេមាន ដោយមិនចាំបាច់បញ្ជាក់ប្រភពអ្វីឡើយ។ ចំណែកការសរសេរកម្រិតស្រាវជ្រាវវិញ តម្រូវឲ្យអ្នកសរសេរ ចេះប្រើប្រាស់ព័ត៌មានដែលគេទទួលបានទៅតាមលក្ខណៈវិទ្យាសាស្ត្រ និងមានភាពសមហេតុផល។ បញ្ហានេះអ្នកស្រាវជ្រាវគួរស្វែងយល់ឲ្យបានច្បាស់លាស់ពីរបៀបនៃការសរសេរ និងការរៀបចំគំនិតដើម្បីបញ្ជាក់នូវអំណះអំណាងរបស់ខ្លួន។

គួរកត់សម្គាល់ថា ការសិក្សាស្រាវជ្រាវទៅលើអ្វីមួយ មិនមែនគ្រាន់តែជាការផ្តល់ព័ត៌មានតែ ប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវមានការបង្កប់នូវគំនិតរបស់អ្នកស្រាវជ្រាវក្នុងការពិភាក្សា។ ពិតមែនហើយ ការសិក្សាស្រាវជ្រាវត្រូវធ្វើឡើងទៅតាមដំណាក់កាលសំខាន់ជាច្រើន ដូចជា៖

- ការស្វែងរកឯកសារ និងប្រភពព័ត៌មានពាក់ព័ន្ធផ្សេងៗដែលអាចជាបទសម្ភាសជាដើម
- ការរៀបចំឯកសារឲ្យត្រូវគ្នានឹងដំណើររឿង
- ការវិភាគ
- ការធ្វើសេចក្តីសន្និដ្ឋាន
- ការចូលរួមចំណែកដល់សង្គម (អនុសាសន៍)

ទោះជាយ៉ាងណាក៏ដោយ អ្នកសិក្សាស្រាវជ្រាវគប្បីចេះឲ្យបានច្បាស់លាស់ពីរបៀបប្រើប្រាស់កាល នៅក្នុងប្រយោគនីមួយៗរបស់

ខ្លួន និងត្រូវផ្តល់ប្រភពជាក់លាក់ចំពោះអំណះអំណាង ឬព័ត៌មានដែលត្រូវបានយោង។

## ការប្រើប្រាស់កាល

ជាទូទៅ កាលសំខាន់ៗនៅក្នុងការសរសេរបែបសិក្សារួមមាន បច្ចុប្បន្នកាល និងអតីតកាល។

បច្ចុប្បន្នកាល

**1.1.1. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលកំពុងនៅជាធរមាន**

ជាទូទៅ គេប្រើបច្ចុប្បន្នកាល ចំពោះការយោងទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលកំពុងនៅជាធរមាន។

**1.1.2. សៀវភៅ និងការសិក្សាស្រាវជ្រាវផ្សេងៗដែលមានឆ្នាំសរសេរច្បាស់លាស់**

ជាទូទៅ កាលណាគេសរសេរឈ្មោះអ្នកនិពន្ធ ឬឈ្មោះអ្នកស្រាវជ្រាវអ្វីមួយដែលមានបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់ ត្រូវប្រើបច្ចុប្បន្នកាល។

អតីតកាល

**1.1.3. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលកំលែងនៅជាធរមាន**

ជាទូទៅ ចំពោះការយោងទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលលែងនៅជាធរមាន ឬអស់សុពលភាពត្រូវប្រើអតីតកាល។

**1.1.4. ឈ្មោះអ្នកនិយាយនៅពេលណាមួយ**

ជាទូទៅ កាលណាគេសរសេរឈ្មោះអ្នកណាម្នាក់ដែលបានមានប្រសាសន៍នៅពេលណាមួយ ច្បាស់លាស់ ត្រូវប្រើអតីតកាល។

## ការសរសេរកថាខណ្ឌ

ជាទូទៅ កថាខណ្ឌនីមួយៗត្រូវមានធាតុផ្សំចំនួន៣គឺ ប្រយោគចម្បង ប្រយោគគាំទ្រ និង ប្រយោគសន្និដ្ឋាន។

### ប្រយោគចម្បង

ប្រយោគចម្បងគឺជាប្រយោគដែលមានលក្ខណៈណាមួយដូចខាងក្រោម៖

- គួរឲ្យចាប់អារម្មណ៍
- គួរឲ្យឆ្ងល់
- គួរឲ្យចង់ដឹង ចង់តាមដាន
- មិនជឿ

*ឧទាហរណ៍*

- ការកាត់ក្តីលោក កាំងហ្គិចអ៊ាវ ហៅឌុច ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ បានបញ្ចប់ទៅប្រកបដោយក្តីចម្រូងចម្រាស។
- ដំណោះស្រាយបញ្ហាជម្លោះប្រដាប់អាវុធព្រំដែនកម្ពុជា-ថៃ បានអូសបន្លាយពេលយ៉ាងយូរគួរឲ្យសង្ស័យ។
- ការខិតខំប្រឹងប្រែងចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរបស់កម្ពុជាតាំងពីឆ្នាំ២០០២មក បានទទួលលទ្ធផលតិចតួចនៅឡើយ។

## ប្រយោគគាំទ្រ

ប្រយោគគាំទ្រផ្តល់អំណះអំណាងដល់ប្រយោគចម្បង។ វាអាចផ្តល់នូវភស្តុតាង ប្រភព ឬទឡ្ហីករណ៍ផ្សេងៗ ដើម្បីការពារ គាំទ្រដល់ប្រយោគចម្បង។ ជាទូទៅ ប្រយោគគាំទ្រមានច្រើនជាងមួយ។

*ឧទាហរណ៍*

- គាំទ្រទៅនឹងប្រយោគចម្បង "ការកាត់ក្តីលោក កាំងហ្គិចអ៊ាវ ហៅឌុច ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ បានបញ្ចប់ទៅប្រកបដោយក្តីចម្រូងចម្រាស" ប្រយោគគាំទ្រអាចត្រូវបានសរសេរដូចខាងក្រោមៈ

  មតិមួយចំនួនបានលើកឡើងថា ការដាក់ទោសឌុចចំនួន៣៥ឆ្នាំនៅតិចតួចនៅឡើយ ពោលគឺមិនសមទៅតាមអំពើដែលគាត់បានប្រព្រឹត្ត។ ឌុចដែលបានសម្លាប់មនុស្សអស់ជាង១៧០០០នាក់ នៅក្នុងអំឡុងពេលខ្លួនមេគុកស២១ សមតែទទួលទោសអស់មួយជីវិត។ ចំណែកមតិពីជនរងគ្រោះមួយចំនួនទៀតបានលើកឡើងថា ការដាក់ទោសនេះ គឺជាការល្អហើយ ព្រោះវាបានធ្វើជាមេរៀនដល់អ្នកដឹកនាំខ្មែរជំនាន់ក្រោយៗ កុំឲ្យប្រព្រឹត្តអំពើអមនុស្សធម៌តទៅទៀត។ មេធាវី និងអ្នកច្បាប់នានាបានផ្តល់ការយល់ឃើញរបស់ពួកគេផ្សេងៗគ្នា។

## ប្រយោគសន្និដ្ឋាន

ប្រយោគសន្និដ្ឋានគឺជាប្រយោគដែលសន្និដ្ឋានទៅលើអ្វីដែលបានលើកឡើងខាងលើ។

# ការបង្កើតប្រធានបទ

ការបង្កើតប្រធានបទសម្រាប់ការសិក្សាស្រាវជ្រាវ មានសារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវ ក្នុងការស្វែងរកអ្វីមួយដែលខ្លួនចង់ដោះស្រាយ។ ចូរចាំថា ការងារស្រាវជ្រាវមិនមែនគ្រាន់តែជាការផ្តល់ព័ត៌មានតែប៉ុណ្ណោះទេ ពោលវាត្រូវមានការបង្កប់នូវគំនិតរបស់អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវទាក់ទងទៅនឹងព័ត៌មាននោះ។ ព័ត៌មានដែលប្រមូលបានមានសារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវ ថាតើពួកគេនឹងប្រើព័ត៌មានទាំងនោះដោយរបៀបណា។ ព័ត៌មានដែលនឹងត្រូវបានយកទៅប្រើគួរមកពីប្រភពផ្សេងៗ ដូចជាតាមរយៈសៀវភៅ កាសែត ទស្សនាវដ្តី (magazine) ជើនណាល (journal) គេហទំព័រ និងប្រភពផ្សេងៗទៀត។ បើស្រាវជ្រាវត្រឹមកម្រិតកិច្ចការស្រាវជ្រាវដែលត្រូវការរយៈពេល៤ ឬ៥សប្តាហ៍ អ្នកត្រូវរកប្រធានបទតូចល្មមទៅតាមពេលវេលានោះ។ បើស្រាវជ្រាវត្រឹមនិក្ខេបបទថ្នាក់អនុបណ្ឌិត ប្រធានបទត្រូវសមល្មមទៅតាមពេលវេលា២ឆ្នាំនៃការស្រាវជ្រាវនោះ ពោលគឺវាធំជាងប្រធានបទនៃកិច្ចការស្រាវជ្រាវ។ បើស្រាវជ្រាវត្រឹមកម្រិតនិក្ខេបបទបណ្ឌិត ប្រធានបទនោះត្រូវធំជាងនិក្ខេបបទអនុបណ្ឌិតទៅទៀត។

ជាទូទៅ ប្រធានបទស្រាវជ្រាវមានលក្ខណៈដូចខាងក្រោម៖

1. ច្បាស់
2. មិនទូលាយពេក មិនចង្អៀតពេក ពោលគឺល្មមអាចស្រាវជ្រាវបាន
3. មានអថេរអាចស្រាវជ្រាវបាន ឬពិសោធបាន
4. ជាកន្សោមពាក្យ
5. គួរឲ្យចាប់អារម្មណ៍

ក្នុងការបង្កើតប្រធានបទស្រាវជ្រាវ អ្នកត្រូវគិតពីបញ្ហាស្រាវជ្រាវ សំណួរស្រាវជ្រាវ និងសម្មតិកម្ម។

## បញ្ហាស្រាវជ្រាវ

អ្នកមើលឃើញបញ្ហាអ្វី?

ឧទាហរណ៍ អ្នកបានសង្កេតឃើញកុមារកម្ពុជាដែលកំពុងប្រើប្រាស់គ្រឿងញៀនបានបោះបង់ចោលការសិក្សា។ កុមារទាំងនោះមិនមានចំណេះដឹងខ្ពង់ខ្ពស់ទេ ពួកគេមួយចំនួនបង្កបញ្ហានៅក្នុងសង្គមយ៉ាងច្រើន។ អ្នកចង់ដោះស្រាយបញ្ហានេះ តាមរយៈការសិក្សាស្រាវជ្រាវ។

## សំណួរស្រាវជ្រាវ

ត្រូវតែច្បាស់ មិនទូលាយពេក មិនចង្អៀតពេក ពោលគឺល្មមអាចស្រាវជ្រាវជ្រាវបាន សមរម្យ ទៅតាមពេលវេលាកំណត់។

ឧទាហរណ៍ តាមរយៈបញ្ហាខាងលើ យើងអាចបង្កើតសំណួរដូចខាងក្រោម៖

"តើការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនរបស់កុមារកម្ពុជា នឹងជួយលើកកម្ពស់វិស័យអប់រំ របស់ពួកគេយ៉ាងដូចម្ដេចដែរ?"

## សម្មតិកម្ម

ជាចម្លើយព្រាងទុកទៅនឹងសំណួរខាងលើ។

ឧទាហរណ៍ ទាក់ទងនឹងសំណួរស្រាវជ្រាវខាងលើ យើងអាចបង្កើតសម្មតិកម្មដូចខាងក្រោម៖

"ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនរបស់កុមារកម្ពុជាជួយឲ្យពួកគេលះបង់គំនិតបោះបង់ចោលការសិក្សា។"

# ការផ្តល់ប្រភពឯកសារ

(Citation)

នៅក្នុងពិភពសិក្សា រាល់ការស្រាវជ្រាវ ការនិពន្ធ និងការផលិតស្នាដៃផ្សេងៗ ការបញ្ជាក់នូវប្រភពឯកសារដើមដើម្បីផ្តល់ទំនុកចិត្តដល់អ្នកអានគឺជាការចាំបាច់។

ការស្វែងយល់ពីរបៀបសរសេរអំពីការផ្តល់ប្រភពឯកសារ ជាការសំខាន់ណាស់។ អ្នកគួរដឹងថា មានរបៀបសរសេរជាច្រើននៅក្នុងពិភពសិក្សានេះគឺវាអាស្រ័យទៅតាមតម្រូវការរបស់សាកលវិទ្យាល័យ និងរបស់រោងពុម្ពផ្សេងៗ។ របៀបសរសេរធំៗមានដូចជា របៀបជីកាហ្គោ (Chicago Style) របៀបសមាគមចិត្តវិទ្យាអាមេរិកាំង (APA Style: American Psychological Association Style) របៀបសមាគមភាសាទំនើប (MLA Style: Modern Language Association Style) និងរបៀបសៀវភៅខៀវ (Bluebook Style) ជាដើម។

សៀវភៅនេះនឹងលើកយករបៀបសរសេរមួយមកបង្ហាញ គឺរបៀបជីកាហ្គោ (Chicago Style)[4] ដែលបានបោះពុម្ពនៅឆ្នាំ២០០៣ដោយសាកលវិទ្យាល័យសារព័ត៌មានជីកាហ្គោ (University of Chicago Press) ព្រោះរបៀបសរសេរនេះអាចនឹងត្រូវបានប្រើប្រាស់គ្រប់មុខវិជ្ជាទាំងអស់ រួមទាំងវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រធម្មជាតិ វិស័យច្បាប់ និងសេដ្ឋកិច្ច ជាដើម។ ទោះជាយ៉ាងណាក៏ដោយ ឧទាហរណ៍ទាំងឡាយនៃការផ្តល់ប្រភព មិនត្រូវបានដកស្រង់ចេញពីសៀវភៅខាងលើនេះទាំងស្រុងទេ។

---

[4] The Chicago Manual of Style: The Essential Guide for Writers, Editors, and Publishers [ក្បួនសរសេរជីកាហ្គោ៖ មគ្គុទ្ទេសសំខាន់សម្រាប់អ្នកនិពន្ធ អ្នកកែសម្រួល និងអ្នកបោះពុម្ព], 15th ed. (Chicago: University of Chicago Press, 2003), 643-728។

ខ្ញុំសូមជូនឧទាហរណ៍អំពីការផ្ដល់ប្រភពក្នុងសៀវភៅជាភាសាខ្មែរ ដើម្បីឲ្យមានភាពងាយស្រួលដល់ការអនុវត្តជាក់ស្ដែង សម្រាប់អ្នកទាំងឡាយដែលមានចំណាប់អារម្មណ៍ក្នុងការសរសេរអំពីការផ្ដល់ប្រភពឯកសារ ទៅតាមក្បួនខ្នាតត្រឹមត្រូវ។ ឧទាហរណ៍មួយចំនួនត្រូវបានដកស្រង់ពីសៀវភៅ ឬប្រភពច្បាស់លាស់ដែលអាចរកបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែឧទាហរណ៍ខ្លះទៀតមិនមែនឧទាហរណ៍ពិតជាក់ស្ដែងថា បានដកស្រង់ចេញពីសៀវភៅ ឬប្រភពណាមួយឡើយ។

គួរកត់សម្គាល់ថាការផ្ដល់ប្រភពឯកសារគឺជាការផ្ដល់ឱកាសដល់អ្នកអានដើម្បីស្វែងរកប្រភពឯកសារដើម ដែលជាអំណះអំណាងក្នុងការស្រាវជ្រាវ ឬក្នុងការពិភាក្សាតែប៉ុណ្ណោះ។ ដូច្នេះ មានរបៀបសរសេរផ្សេងៗជាច្រើនអំពីការផ្ដល់ប្រភពឯកសារ អាស្រ័យទៅតាមចំណង់ចំណូលចិត្តរបស់អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវ ឬទៅតាមតម្រូវការរបស់សាកលវិទ្យាល័យ ឬស្ថាប័ននានា។ ទោះជាយ៉ាងណាក៏ដោយ រាល់ការផ្ដល់ប្រភពឯកសារ ដែលមានព័ត៌មានគ្រប់គ្រាន់សម្រាប់ឲ្យអ្នកអានស្វែងរកប្រភពឯកសារដើមបាន គឺចាត់ទុកថាអាចយកជាការបានហើយ។

ដើម្បីសម្រួលដល់ភាពស៊ីសង្វាក់គ្នារវាងការផ្ដល់ប្រភពជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងសៀវភៅនេះ ខ្ញុំនឹងប្រើសញ្ញាវណ្ណយុត្តមួយចំនួនរបស់ខ្មែរ ដូចជាសញ្ញាចុចពីរ ":" ប្រើជាសញ្ញាភ្នែកមាន់ "៖" សញ្ញាចុចមួយចុងក្រោយគេ "." ប្រើជាសញ្ញាខណ្ឌខ្មែរ "។" វិញ។ ប៉ុន្តែ មានសញ្ញាវណ្ណយុត្តមួយចំនួនទៀត មិនត្រូវបានផ្លាស់ប្ដូរទេ ដូចជាសញ្ញាក្បៀស "," សញ្ញាចុចមួយ "." ក្រៅពីសញ្ញាចុចមួយខាងលើ។ ការធ្វើបែបនេះនឹងផ្ដល់ភាពងាយស្រួល ព្រោះថានៅពេលគេបកប្រែវាជាភាសាអង់គ្លេស វានឹងមិនមានការផ្លាស់ប្ដូរខ្លាំងទេ។

សម្គាល់ក្រោមទំព័រ (Foot-note = N) ឬសម្គាល់ចុងអត្ថបទ (End-note =N) គឺជាការផ្ដល់ប្រភពឯកសារដែលមានព័ត៌មានលំអិត។ គេប្រើសម្គាល់ក្រោមទំព័រ នៅគ្រប់ទំព័រនីមួយៗដែលមានវា ដើម្បីសម្រួលដល់អ្នកអាន

អាចពិនិត្យមើលប្រភពភ្លាមៗ ដោយមិនចាំបាច់បើកទៅទំព័រណាផ្សេង។ រីឯសម្គាល់ចុងអត្ថបទវិញក៏ដូចគ្នានឹងសម្គាល់ក្រោមទំព័រដែរ គ្រាន់តែគេសរសេរវានៅខាងចុងអត្ថបទវិញ។ បើគេចង់អានព័ត៌មានទាក់ទងទៅនឹងសម្គាល់ចុងអត្ថបទនោះ គេត្រូវទៅមើលវានៅខាងក្រោយអត្ថបទ។ ការសរសេរសម្គាល់ចុងអត្ថបទ អាចមាននៅខាងចុងផ្នែក ចុងជំពូក ចុងមេរៀន ឬចុងសៀវភៅតែម្តង។ សម្គាល់ម៉្យាងទៀតគឺសម្គាល់ក្នុងអត្ថបទ (Text-note = T)។ ជាទូទៅ គេសរសេរកាត់បំផុត ពីព្រោះវាបិតនៅក្នុងកថាខណ្ឌជាមួយអត្ថបទតែម្តង។ នៅពេលគេប្រើសម្គាល់ជាទម្រង់សម្គាល់ក្នុងអត្ថបទ គេត្រូវតែតម្រូវដាច់ខាតឲ្យមានគន្ថនិទ្ទេស ឬឯកសារយោង។

ចំណុចសំខាន់របស់សម្គាល់ក្រោមទំព័រ និងសម្គាល់ចុងអត្ថបទគឺថា គ្រប់សម្គាល់ទាំងពីរនេះមិនមែនសុទ្ធតែជាការផ្តល់ប្រភពឯកសារទេ។ វាអាចជាការផ្តល់ព័ត៌មានបន្ថែម ការពន្យល់ចំណុចណាមួយលំអិត ឬការសម្រាយអក្សរកាត់ជាដើម។ ប៉ុន្តែ គ្រប់សម្គាល់ក្នុងអត្ថបទសុទ្ធតែជាការផ្តល់ប្រភពឯកសារ។ នៅក្នុងការសរសេរជាទម្រង់សម្គាល់ក្នុងអត្ថបទ ក៏អាចមានសម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទដែរ ប៉ុន្តែសម្គាល់ទាំងពីរនេះមិនមែនជាការផ្តល់ប្រភពឯកសារទេ ពោលគឺវាគ្រាន់តែជាការពន្យល់បន្ថែម ឬការផ្តល់ព័ត៌មានបន្ថែមតែប៉ុណ្ណោះ។

គន្ថនិទ្ទេស (Bibliography = B) ឬឯកសារយោង/ឯកសារពិគ្រោះ (Reference = R) ជាការសរុបប្រភពឯកសារយោងទាំងអស់ដែលបានយោងនៅក្នុងការពិភាក្សាខាងលើ។ វាមិនមានព័ត៌មានលំអិតពីទំព័រយោង ឬមាត្រាយោងទេ។ ក្នុងចំណោមការសរុបប្រភពឯកសារយោងទាំងពីរនេះ គេអាចជ្រើសរើស យកប្រភេទនៃការសរសេរមួយណាក៏បាន វាមិនមានភាពខុសគ្នាទេ គ្រាន់តែ បើជ្រើសរើសប្រភេទមួយណា ត្រូវសរសេរទៅតាមទម្រង់របស់វាដើម្បីឲ្យមានភាពដូចគ្នា។ ជាទូទៅ វាបិតនៅខាងក្រោយអត្ថបទ ឬនៅខាងចុងសៀវភៅ។

# 1. សៀវភៅ

## 1.1. អ្នកនិពន្ធតែម្នាក់

ស្នាដៃដែលមានអ្នកនិពន្ធតែម្នាក់ នៅក្នុងសម្គាល់ក្រោមទំព័រ គេត្រូវសរសេរឈ្មោះអ្នកនិពន្ធភ្ជាប់ដោយក្បៀសខាងក្រោយ បន្ទាប់មកចំណងជើងសៀវភៅដោយប្រើអក្សរទ្រេត ហើយដាក់ក្នុងវង្ងង់ក្រចកកន្លែងបោះពុម្ពភ្ជាប់ដោយសញ្ញាភ្នែកមាន់ "៖" និងឈ្មោះរោងពុម្ព រួចក្បៀសដោយដាក់ឆ្នាំបោះពុម្ព បន្ទាប់ពីវង្ងង់ក្រចកបិទមកត្រូវដាក់ក្បៀសមួយ និងលេខទំព័ររបស់វា រួចបញ្ចប់ដោយសញ្ញាខណ្ឌ។

ចំពោះគន្ថនិទ្ទេស និងឯកសារយោងវិញមិនមានវង្ងង់ក្រចកទេ ហើយគ្រប់ក្បៀសដែលកាត់ផ្តាច់ផ្នែកនីមួយៗ ត្រូវដូរជាសញ្ញាចុចវិញលើកលែងតែក្បៀសបញ្ជាក់ទៅលើផ្នែកណាមួយតែប៉ុណ្ណោះ។

ការស្រង់ជាភាសាអង់គ្លេស ឈ្មោះអ្នកនិពន្ធត្រូវសរសេររបៀបបច្ចឹមប្រទេស។ នៅក្នុងសម្គាល់ក្រោមទំព័រ គេសរសេរឈ្មោះអ្នកនិពន្ធដោយផ្តើមនូវនាមខ្លួនរបស់អ្នកនិពន្ធ និងបញ្ចប់ដោយនាមត្រកូល។ រីឯនៅក្នុងគន្ថនិទ្ទេសវិញ ឈ្មោះអ្នកនិពន្ធត្រូវផ្តើមដោយនាមត្រកូលរួចក្បៀស និងចុងក្រោយនាមខ្លួនអ្នកនិពន្ធ ហើយបញ្ចប់ដោយសញ្ញាខណ្ឌ"។" តែម្តង។ ចូរកត់សម្គាល់ថាមិនមានសញ្ញាវង្ងង់ក្រចកទេ ចំពោះឯកសារយោង និងគន្ថនិទ្ទេស។






ការសរសេរទម្រង់ N, T, B, R មានដូចខាងក្រោម៖

N: 1. សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១៥៣។

T: (សាយ បូរី ២០០៧, ១៥៣)

B: សាយ បូរី. *វិទ្យាសាស្ត្ររដ្ឋបាល.* ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧។

R: សាយ បូរី. ២០០៧. *វិទ្យាសាស្ត្ររដ្ឋបាល.* ភ្នំពេញ៖ បណ្ណាគារអង្គរ។

**សៀវភៅដែលមានចំណងជើងធំ និងចំណងជើងរង**

សៀវភៅខ្លះមានចំណងជើងពីរគឺមួយជាចំណងជើងចម្បង (ចំណងជើងមេ ឬចំណងជើងធំ) និងមួយទៀតជាចំណងជើងរង ឬចំណងជើងតូច។ ក្នុងករណីនេះចំណងជើងទាំងពីរត្រូវខណ្ឌចែកដាច់ពីគ្នាដោយសញ្ញា "៖" ដើម្បីឲ្យងាយស្រួលមើលឲ្យឃើញច្បាស់ថាមួយជាចំណងជើងធំ និងមួយទៀតជាចំណងជើងរង។


សារិន ឆាក
បណ្ឌិតសេដ្ឋកិច្ចនយោបាយ
ព្រំដែន
នៃប្រទេសកម្ពុជា
ជាមួយបណ្ដាប្រទេសនៃ
អតីតសហព័ន្ធឥណ្ឌូចិន
ឡាវ-វៀតណាម (កូសាំងស៊ីន និងអណ្ណាម)
ឥន្ទ្រទេវី
ក្របមុខសៀវភៅ
ឈ្មោះអ្នកនិពន្ធ
ចំណងជើងធំ
ចំណងជើងរង ឬ
ចំណងជើងតូច
ឈ្មោះរោងពុម្ព
មជ្ឈមណ្ឌលសិក្សានៃបណ្ដាប្រទេសនៅចុងបូព៌ានៃអាស៊ីអាគ្នេយ៍
ព្រំដែននៃប្រទេសកម្ពុជា
ជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន
ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)
ដោយ
សារិន ឆាក
បណ្ឌិតសេដ្ឋកិច្ចនយោបាយ
អារម្ភកថា របស់
សម្ដេចនរោត្ដម សីហនុ
ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា
និងរបស់
លោក PAUL REUTER
បោះពុម្ពផ្សាយលើកទី២ ជាខេមរភាសាដោយ
ឥន្ទ្រទេវី
ទំព័រទី២បន្ទាប់ពីក្របមុខ
ចំណងជើងរង អាចយកដូច
នៅក្នុងក្របមុខក៏បាន
ឥន្ទ្រទេវី
ឯកសារប្រែសម្រួលជាខេមរភាសាដោយឥន្ទ្រទេវីបោះពុម្ពផ្សាយ
ស្រាវជ្រាវនិងនិពន្ធដោយ សារិនឆាក
ប្រែសម្រួលជាខេមរភាសាដោយ គឹម យ៉ាន
រៀបរៀងនិងកែសម្រួលដោយ ទៀ ថេន
រចនានិងតួសៀវភៅ ជា សុភាព, ជា វុត្ថា
កុំព្យូទ័រ ផាត សុភ័ក្ត្រ
ឆ្នាំ២០០៤ បោះពុម្ពចំនួន៥០០០ច្បាប់
បោះពុម្ពនៅកម្ពុជា ដោយរោងពុម្ពឥន្ទ្រទេវី
រក្សាសិទ្ធិគ្រប់យ៉ាង
ទំព័រទី៣បន្ទាប់ពីក្របមុខ
ឆ្នាំបោះពុម្ពផ្សាយ
ទីកន្លែងបោះពុម្ព (ឥន្ទ្រទេវី ត្រូវបានគេស្គាល់ថាមានទីតាំងនៅភ្នំពេញ

ចំណាងជើងធំ

ចំណាងជើងរងត្រូវសរសេរ ទាំងអស់បើមានវង្ងង់ក្រចក ត្រូវសរសេរចូលដែរ

N: 2. សារិន ឆាក, *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤), ៣៣។

T: (សារិន ឆាក ២០០៤, ៣៣)

B: សារិន ឆាក. *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)*. ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤។

R: សារិន ឆាក. ២០០៤. *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)*. ភ្នំពេញ៖ ឥន្ទ្រទេវី។

រក្សាទុកវង្ងង់ក្រចក ដូចនៅក្នុងចំណាងជើងដើមស្រាប់

### សៀវភៅដែលមិនមានឈ្មោះរោងពុម្ព

សៀវភៅខ្លះមិនមានឈ្មោះរោងពុម្ពទេ តែមានឈ្មោះកន្លែងបោះពុម្ពផ្សាយ ក្នុងករណីនេះគេអាចសរសេរតែឈ្មោះកន្លែងបោះពុម្ពផ្សាយ និងឆ្នាំបោះពុម្ពផ្សាយនៅក្នុងសញ្ញាវង្ងង់ក្រចកក៏បាន។ គួរកត់សម្គាល់ថាគេត្រូវប្រើសញ្ញាក្បៀស ដើម្បីផ្ដាច់ឈ្មោះកន្លែងបោះពុម្ពផ្សាយ និងឆ្នាំបោះពុម្ពផ្សាយ។

ទំព័រក្រុបមុខ

**ស្ថាប័នរដ្ឋបាល**

**នៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម ឥន យឿន**

ចំណងជើងសៀវភៅ

ឈ្មោះអ្នកនិពន្ធ

(ក្រុបមុខនេះមានព័ត៌មានមិនគ្រប់គ្រាន់ទេ)

ទំព័រទី២បន្ទាប់ពីក្រុបមុខ

**ស្ថាប័នរដ្ឋបាល**
**នៃ**
**ព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម ឥន យឿន**

**រក្សាសិទ្ធិគ្រប់យ៉ាង**
**បោះពុម្ពលើកទី១**
**ឆ្នាំ២០១១**

ចំណងជើងសៀវភៅ

ឈ្មោះអ្នកនិពន្ធ

ការបោះពុម្ពលើកទី

(ការបោះពុម្ពលើកទី១ មិនចាំបាច់បញ្ជាក់ក៏បាន)

ឆ្នាំបោះពុម្ពផ្សាយ

បរមងារនៅពីមុខឈ្មោះមិនចាំបាច់

N: 3. ឥន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា* (ភ្នំពេញ, ២០១១), ១០។

មានតែកន្លែងបោះពុម្ព តែមិនមានរោងពុម្ព

T: (ឥន យឿន ២០១១, ១០)

B: ឥន យឿន. *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ, ២០១១។

R: ឥន យឿន. ២០១១. *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា .* ភ្នំពេញ។

**សៀវភៅដែលមិនមានឈ្មោះរោងពុម្ព និងកន្លែងបោះពុម្ពផ្សាយ**

ក្នុងករណីសៀវភៅខ្លះដែលមិនមានទាំងឈ្មោះរោងពុម្ព និងកន្លែងបោះពុម្ពផ្សាយ គេត្រូវសរសេរតែឆ្នាំបោះពុម្ពផ្សាយនៅក្នុងរង្វង់ក្រចកតែម្តងជាការស្រេច។



មានតែឆ្នាំបោះពុម្ព ហើយមិនមានឈ្មោះរោងពុម្ព និងកន្លែងបោះពុម្ពទេ

N: 4. ជា សំ, *ប្រវត្តិសាស្ត្រខ្មែរ និងការធ្លាក់ចុះនៃអរិយធម៌អង្គរ* (២០០៤), ២០៣។

T: (ជា សំ ២០០៤, ២០៣)

B: ជា សំ. *ប្រវត្តិសាស្ត្រខ្មែរ និងការធ្លាក់ចុះនៃអរិយធម៌អង្គរ*. ២០០៤។

R: ជា សំ. ២០០៤. *ប្រវត្តិសាស្ត្រខ្មែរ និងការធ្លាក់ចុះនៃអរិយធម៌អង្គរ*។

**1.2. អ្នកនិពន្ធពីរនាក់**

ដូចគ្នានឹងអ្នកនិពន្ធម្នាក់ដែរ ឯកសារដែលមានអ្នកនិពន្ធពីរនាក់ ត្រូវសរសេរឈ្មោះអ្នកនិពន្ធទាំងពីរដោយភ្ជាប់នឹងឈ្នាប់ "និង"។

ទំព័រក្របមុខ




ចំណងជើងធំ

ចំណងជើងរង

ឈ្មោះអ្នកនិពន្ធ

ទំព័រទី២បន្ទាប់ពីក្របមុខ

**ប៉ែន សុវណ្ណ**

**ជីវប្រវត្តិសង្ខេប និង បុព្វហេតុជាតិមាតុភូមិ កម្ពុជា**

បោះពុម្ពលើកទី១
នៅទីក្រុងស៊ីអាថុល រដ្ឋវ៉ាស៊ីងតោន សហរដ្ឋអាមេរិក

ចំណងជើងធំ

ចំណងជើងរង (ទំហំអក្សរដូចគ្នា អាច ញែកមិនច្បាស់ឡើយ បើផ្អែកលើតែទំព័រនេះ)

មិនមានឈ្មោះអ្នកនិពន្ធ ទេនៅទំព័រនេះ

កន្លែងបោះពុម្ពផ្សាយ (ទំព័រនេះមានព័ត៌មាន មិនគ្រប់គ្រាន់ឡើយ)

ទំព័រទី៣បន្ទាប់ពីក្របមុខ

និពន្ធដោយ លោក ប៉ែន សុវណ្ណ
លោក នាង សាវុន
រៀបចំក្របសៀវភៅដោយ លោក អ៊ូច ចិត្រ
បោះពុម្ពផ្សាយដោយ រោងពុម្ពចក្ខុវិស័យខ្មែរ

Copyright©2002 by Pen, Sovann and Neang, Savun

For more information contact:
Khmer Vision Publishing Company
P.O.BOX 46212
Seattle, WA 98146 U.S.A
www.madelincambodia.net
ISBN0-9708952-0-8
Printed in the United States of America

ឈ្មោះអ្នកនិពន្ធ

ឈ្មោះរោងពុម្ព

ឆ្នាំបោះពុម្ពផ្សាយ

កន្លែងបោះពុម្ពផ្សាយ

N: 5. ប៉ែន សុវណ្ណ និងនាង សារុន, *ប៉ែន សុវណ្ណៈ ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា* (វ៉ាស៊ីងតោនៈ ចក្ខុវិស័យខ្មែរ, ២០០២), ១៩៧។

T: (ប៉ែន សុវណ្ណ និងនាង សារុន ២០០២, ១៩៧)

B: ប៉ែន សុវណ្ណ និងនាង សារុន. *ប៉ែន សុវណ្ណៈ ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា.* វ៉ាស៊ីងតោនៈ ចក្ខុវិស័យខ្មែរ, ២០០២។

R: ប៉ែន សុវណ្ណ និងនាង សារុន. ២០០២. *ប៉ែន សុវណ្ណៈ ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា.* វ៉ាស៊ីងតោនៈ ចក្ខុវិស័យខ្មែរ។

### 1.3. អ្នកនិពន្ធបីនាក់

ដូចគ្នានឹងអ្នកនិពន្ធពីរនាក់ដែរ ឯកសារដែលមានអ្នកនិពន្ធបីនាក់ត្រូវសរសេរឈ្មោះអ្នកនិពន្ធទាំងបីរៀងគ្នាដោយមានសញ្ញាក្បៀស និងចុងក្រោយភ្ជាប់នឹងឈ្នាប់ "និង"។

ទំព័រក្របមុខ






N: 6. សោម វាសនា, សំណាង ផាន់ណា និងសួស សាលី, *នយោបាយខ្មែរ* (ភ្នំពេញៈ បណ្ណាគារអង្គរ, ២០០២), ៦៧។

T: (សោម វាសនា, សំណាង ផាន់ណា និងសួស សាលី ២០០៣, ៦៧)

B: សោម វាសនា, សំណាង ផាន់ណា និងសួស សាលី. *នយោបាយខ្មែរ*. ភ្នំពេញៈ បណ្ណាគារអង្គរ, ២០០២។

R: សោម វាសនា, សំណាង ផាន់ណា និងសួស សាលី. ២០០២. *នយោបាយខ្មែរ*. ភ្នំពេញៈ បណ្ណាគារអង្គរ។

**1.4. អ្នកនិពន្ធច្រើនជាងបីនាក់**

ចំពោះសៀវភៅដែលមានអ្នកនិពន្ធច្រើនជាងបីនាក់ ត្រូវសរសេរឈ្មោះអ្នកនិពន្ធទី១ និងភ្ជាប់ដោយកន្សោមពាក្យ "និងផ្សេងទៀត"។ ប៉ុន្តែចំពោះគន្ថនិទ្ទេស និងឯកសារយោង ត្រូវសរសេររាយឈ្មោះអ្នកនិពន្ធទាំងអស់រៀងគ្នាដោយមានក្បៀស និងចុងក្រោយមានសញ្ញាខណ្ឌ "។" សម្រាប់បញ្ចប់។

ទំព័រទី២បន្ទាប់ពីក្របមុខ




ទំព័រទី២បន្ទាប់ពីក្របមុខ



ប្រើពាក្យ "និងផ្សេងទៀត" ដោយមិនចាំបាច់រៀបរាប់ឈ្មោះអ្នកនិពន្ធផ្សេងទៀតទេនៅក្នុងគ្រប់ទម្រង់នៃសម្គាល់ទាំងអស់

N: 7. ហេង មុន្នីរតនា និងផ្សេងទៀត, *រដ្ឋបាលថ្នាក់មូលដ្ឋាន* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១២), ១២៥។

T: (ហេង មុន្នីរតនា និងផ្សេងទៀត ២០១២, ១២៥)

B: ហេង មុន្នីរតនា, សោម វាសនា, សំ ផាន់ណា និងគាន សាលី. *រដ្ឋបាលថ្នាក់មូលដ្ឋាន*. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១២។

R: ហេង មុន្នីរតនា, សោម វាសនា, សំ ផាន់ណា និងគាន សាលី. ២០១២. *រដ្ឋបាលថ្នាក់មូលដ្ឋាន*. ភ្នំពេញ៖ បណ្ណាគារអង្គរ។

ត្រូវរៀបរាប់ឈ្មោះអ្នកនិពន្ធទាំងអស់នៅក្នុងគន្ថនិទ្ទេសនិងឯកសារយោង

ចំណែកសៀវភៅរបស់លោក អ៊ុន លាង ដែលមានអ្នកនិពន្ធផ្សេងទៀតមិនមានឈ្មោះរោងពុម្ពទេ ដូច្នេះយើងត្រូវរំលងឈ្មោះរោងពុម្ព។

ប្រើពាក្យ "និងផ្សេងទៀត" ដោយមិនចាំបាច់រៀបរាប់ឈ្មោះអ្នកនិពន្ធផ្សេងទៀតទេនៅក្នុងគ្រប់ទម្រង់នៃសម្គាល់ទាំងអស់

N: 7. អ៊ុន លាង និងផ្សេងទៀត, *គ្រឹះរបស់ទស្សនវិជ្ជា* (ភ្នំពេញ, ២០០៦), ៥០។

T: (អ៊ុន លាង និងផ្សេងទៀត ២០០៦, ៥០)

B: អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សាវន, ឈត ប៊ុនថង និងឈុន ផារ៉េង. *គ្រឹះរបស់ទស្សនវិជ្ជា*. ភ្នំពេញ, ២០០៦។

R: អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សាវន, ឈត ប៊ុនថង និងឈុន ផារ៉េង. ២០០៦. *គ្រឹះរបស់ទស្សនវិជ្ជា*. ភ្នំពេញ។

ត្រូវរៀបរាប់ឈ្មោះអ្នកនិពន្ធទាំងអស់នៅក្នុងគន្ថនិទ្ទេសនិងឯកសារយោង

**1.5. ស្នាដៃឥតមានឈ្មោះអ្នកនិពន្ធ (មិនស្គាល់ឈ្មោះអ្នកនិពន្ធ)**

ចំពោះសៀវភៅដែលឥតមានឈ្មោះអ្នកនិពន្ធ ឬអ្នកនិពន្ធអនាមិក នៅគន្ថនិទ្ទេស និងឯកសារយោងត្រូវសរសេរនៅត្រង់ឈ្មោះអ្នកនិពន្ធនូវពាក្យ "អ្នកនិពន្ធអនាមិក"។ បើអ្នកនិពន្ធអនាមិកច្រើនតៗគ្នា ត្រូវឆ្វូតបន្ទាត់ជំនួសកន្លែងអ្នកនិពន្ធអនាមិកផ្សេងទៀតរៀងគ្នា ពោលគឺដូចគ្នាទៅនឹងឈ្មោះអ្នកនិពន្ធដូចគ្នាជាច្រើនដែរ។ ប៉ុន្តែ ចំពោះសម្គាល់ក្រោមទំព័រវិញ មិនចាំបាច់សរសេរ "អ្នកនិពន្ធអនាមិក" ទេ។



ឧទាហរណ៍ទី១

N: 8. *ជីវិតឆ្ពោះទៅរកជោគជ័យ* (ភ្នំពេញ, ២០០១), ៨០។

T: (អ្នកនិពន្ធអនាមិក ២០០១, ៨០)

B: អ្នកនិពន្ធអនាមិក. *ជីវិតឆ្ពោះទៅរកជោគជ័យ*. ភ្នំពេញ, ២០០១។

R: អ្នកនិពន្ធអនាមិក. ២០០១. *ជីវិតឆ្ពោះទៅរកជោគជ័យ*. ភ្នំពេញ។




ឧទាហរណ៍ទី២

N: 9. *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ* (ភ្នំពេញ, ២០១១), ១៥៩។

T: (អ្នកនិពន្ធអនាមិក ២០១១, ១៥៩)

B: អ្នកនិពន្ធអនាមិក. *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ*. ភ្នំពេញ, ២០១១។

R: អ្នកនិពន្ធអនាមិក. ២០១១. *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ*. ភ្នំពេញ។




ឧទាហរណ៍ទី៣

N: 10. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ* (ភ្នំពេញ, ២០០៣), ៤៣។

T: (អ្នកនិពន្ធអនាមិក ២០០៣, ៤៣)

B: អ្នកនិពន្ធអនាមិក. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ*. ភ្នំពេញ, ២០០៣។

R: អ្នកនិពន្ធអនាមិក. ២០០៣. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ*. ភ្នំពេញ។

ក្នុងករណីសរសេរក្នុងគន្ថនិទ្ទេស ឬឯកសារយោងដែលមានអ្នកនិពន្ធអនាមិកច្រើន ត្រូវឆូតបន្ទាត់មួយពីក្រោមអ្នកនិពន្ធអនាមិកខាងលើ 1 tab រួចប្រើសញ្ញាចុច "."។ ការតម្រៀបលំដាប់អក្ខរក្រមនៅពេលនេះ គឺផ្អែកតាមតួអក្សរនៃចំណងជើងសៀវភៅ។

ឧទាហរណ៍នៃការសរុបបញ្ជីប្រភពឯកសារនៅក្នុងគន្ថនិទ្ទេស ពាក់ព័ន្ធនឹងសៀវភៅដែលមានអ្នកនិពន្ធអនាមិកមានដូចខាងក្រោមៈ

**គន្ថនិទ្ទេស**

អ្នកនិពន្ធអនាមិក. *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ*. ភ្នំពេញ, ២០១១។

———. *ជីវិតឆ្ពោះទៅរកជោគជ័យ*. ភ្នំពេញ, ២០០១។

———. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ*. ភ្នំពេញ, ២០០៣។

បន្ទាត់នេះបញ្ជាក់ថាអ្នកនិពន្ធអនាមិកដូចខាងលើដែរ ប៉ុន្តែលំដាប់នៃការដាក់តម្រៀបគ្នានេះគឺតាមលំដាប់អក្សរដែលត្រូវផ្ដើមចេញពី "ចំណង = ច" បន្ទាប់មក "ជីវិត = ជ" និងចុងក្រោយគឺ "វិស័យ = វ" រៀងគ្នា។

ឧទាហរណ៍នៃការសរុបបញ្ជីប្រភពឯកសារ នៅក្នុងឯកសារយោង ពាក់ព័ន្ធនឹងសៀវភៅដែលមានអ្នកនិពន្ធអនាមិក

**ឯកសារយោង**

អ្នកនិពន្ធអនាមិក. ២០១១. *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ*. ភ្នំពេញ។

———. ២០០១. *ជីវិតឆ្ពោះទៅរកជោគជ័យ*. ភ្នំពេញ។

———. ២០០៣. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ*. ភ្នំពេញ។

លំដាប់នៃការដាក់តម្រៀបគ្នានេះគឺតាមលំដាប់អក្សរដែលត្រូវផ្ដើមចេញពី "ចំណង = ច" បន្ទាប់មក "ជីវិត = ជ" និងចុងក្រោយគឺ "វិស័យ = វ" ពោលគឺវាមិនអាស្រ័យនឹងលំដាប់នៃឆ្នាំបោះពុម្ពទេ។

**1.6. ស្នាដៃឥតមានឈ្មោះអ្នកនិពន្ធ (ឈ្មោះអ្នកនិពន្ធគេស្គាល់)**

ប្រសិនបើសៀវភៅដែលត្រូវយកមកយោង មិនមានសរសេរឈ្មោះអ្នកនិពន្ធ ឬឈ្មោះអ្នកនិពន្ធត្រូវបានគេលុបចោល ប៉ុន្តែឈ្មោះអ្នកនិពន្ធនោះត្រូវបានគេស្គាល់ ឬប៉ាន់ស្មានបាន ត្រូវសរសេរឈ្មោះអ្នកនិពន្ធនោះនៅក្នុងសញ្ញាឃ្នាប "[ ]"។

ឧទាហរណ៍នៃឈ្មោះអ្នកនិពន្ធដែលត្រូវបានគេស្គាល់




ឃ្នាបនេះមានន័យថាឈ្មោះអ្នកនិពន្ធនៃឯកសារយោងត្រូវបានអ្នកយោងស្គាល់។

N: 11. [ពៅ សុក], *ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា* (ភ្នំពេញ, ២០០៩), ៩៣។

T: ([ពៅ សុក] ២០០៩, ៩៣)

B: [ពៅ សុក]. *ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា*. ភ្នំពេញ, ២០០៩។

R: [ពៅ សុក]. ២០០៩. *ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា*. ភ្នំពេញ។

ឧទាហរណ៍នៃឈ្មោះអ្នកនិពន្ធដែលត្រូវបានគេស្មាន




ឃ្នាបដោយមានសញ្ញាសួរនេះមានន័យថាឈ្មោះអ្នកនិពន្ធនៃឯកសារយោងត្រូវបានអ្នកយោងស្មាន។

N: 12. [ពៅ សៅ?], *ការរីកដុះដាលសណ្ឋាគារនៅកម្ពុជា* (២០០៦), ៧៦។

T: ([ពៅ សៅ?] ២០០៦, ៧៦)

B: [ពៅ សៅ?]. *ការរីកដុះដាលសណ្ឋាគារនៅកម្ពុជា*. ២០០៦។

R: [ពៅ សៅ?]. ២០០៦. *ការរីកដុះដាលសណ្ឋាគារនៅកម្ពុជា*។

### 1.7. សៀវភៅដែលមិនមានឈ្មោះអ្នកនិពន្ធ តែមានឈ្មោះអ្នកប្រែសម្រួល

នៅពេលគ្មានឈ្មោះអ្នកនិពន្ធនៅលើក្របមុខសៀវភៅ ប៉ុន្តែមានតែឈ្មោះអ្នកប្រែសម្រួល អ្នករៀបរៀង អ្នកកែសម្រួល អ្នកចងក្រង ឬអ្នក

បកប្រែនៅលើក្របនៃសៀវភៅនោះ យើងត្រូវសរសេរឈ្មោះអ្នកទាំងនោះជំនួសឈ្មោះអ្នកនិពន្ធដោយគ្រាន់តែប្រើពាក្យ "ប្រែសម្រួល" "កែសម្រួល" "ចងក្រង"ឬ"បកប្រែ" នៅពីក្រោយឈ្មោះ។ ប៉ុន្តែចំពោះសម្គាល់ក្នុងអត្ថបទមិនចាំបាច់ប្រើពាក្យទាំងនេះទេ។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកប្រែសម្រួល



N: 13. គឹម ចាន់ណា, ប្រែសម្រួល, *បញ្ញាញាណរបស់អែនស្តែន* (ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៨), ២៧។

T: (គឹម ចាន់ណា ២០០៨, ២៧)

B: គឹម ចាន់ណា, ប្រែសម្រួល. *បញ្ញាញាណរបស់អែនស្តែន.* ភ្នំពេញ៖ ឥន្ទ្រីមាស, ២០០៨។

R: គឹម ចាន់ណា, ប្រែសម្រួល.២០០៨.*បញ្ញាញាណរបស់អែនស្តែន.* ភ្នំពេញ៖ ឥន្ទ្រីមាស។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នករៀបរៀង






N: 14. កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា, រៀបរៀង, *សេចក្តីផ្តើមនៃនីតិខ្មែរ* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ៦១។

T: (កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា ២០០៧, ៦១)

B: កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា, រៀបរៀង. *សេចក្តីផ្តើមនៃនីតិខ្មែរ.* ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧។

R: កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា, រៀបរៀង. ២០០៧. *សេចក្តីផ្តើមនៃនីតិខ្មែរ.* ភ្នំពេញ៖ បណ្ណាគារអង្គរ។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកកែសម្រួល




N: 15. កុយ ចំណាន, កែសម្រួល, *សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសេដ្ឋកិច្ចតំបន់* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០១១), ៣០៨។

T: (កុយ ចំណាន ២០១១, ៣០៨)

B: កុយ ចំណាន, កែសម្រួល. *សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសេដ្ឋកិច្ចតំបន់.* ភ្នំពេញ៖ ឥន្ទ្រទេវី, ២០១១។

R: កុយ ចំណាន, កែសម្រួល. ២០១១. *សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសេដ្ឋកិច្ចតំបន់.* ភ្នំពេញ៖ ឥន្ទ្រទេវី។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកចងក្រង




N: 16. ជា រតន:, ចងក្រង, *ប្រវត្តិសង្ខេបតំណាងរាស្ត្រពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨* (ភ្នំពេញ៖ សុខលាប, ២០១០), ៨០។

T: (ជា រតន: ២០១០, ៨០)

B: ជា រតន:, ចងក្រង. *ប្រវត្តិសង្ខេបតំណាងរាស្ត្រពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០០៨.* ភ្នំពេញ៖ សុខលាប, ២០១០។

R: ជា រតន:, ចងក្រង. ២០១០. *ប្រវត្តិសង្ខេបតំណាងរាស្ត្រពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨.* ភ្នំពេញ៖ សុខលាប។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកបកប្រែ




N: 17. ជា វិសុទ្ធ, បកប្រែ, *ប្រព័ន្ធបោះឆ្នោតពិភពលោក* (ភ្នំពេញ៖ បណ្ណាគារអង្គរធំ, ២០០១), ៩៨។

T: (ជា វិសុទ្ធ ២០០១, ៩៨)

B: ជា វិសុទ្ធ, បកប្រែ. *ប្រព័ន្ធបោះឆ្នោតពិភពលោក.* ភ្នំពេញ៖ បណ្ណា-គារអង្គរធំ, ២០០១។

R: ជា វិសុទ្ធ, បកប្រែ. ២០០១. *ប្រព័ន្ធបោះឆ្នោតពិភពលោក.* ភ្នំពេញ៖ បណ្ណាគារអង្គរធំ។

### 1.8. អ្នកកែសម្រួល ឬអ្នកបកប្រែបន្ថែមទៅលើឈ្មោះអ្នកនិពន្ធ

ចំពោះស្នាដៃកែសម្រួល ចងក្រង ឬបកប្រែរបស់អ្នកនិពន្ធណាមួយ ត្រូវសរសេរឈ្មោះអ្នកនិពន្ធមុន រួចចំណងជើង បន្ទាប់មកត្រូវសរសេរពាក្យថា "កែសម្រួល" "ចងក្រង" ឬ "បកប្រែ" ពីមុខឈ្មោះអ្នកកែសម្រួល ចងក្រង ឬបកប្រែ។ ប៉ុន្តែ នៅក្នុងគន្ថនិទ្ទេសវិញ ត្រូវសរសេរ "កែសម្រួល

ដោយ” “ចងក្រងដោយ” ឬ“បកប្រែដោយ” នៅពីមុខឈ្មោះវិញ។ ប្រសិនបើមានទាំងឈ្មោះអ្នកកែសម្រួលផង និងឈ្មោះអ្នកបកប្រែផងត្រូវសរសេរទៅតាមលំដាប់ដូចគ្នានឹងទំព័រក្របខាងមុខគេបង្អស់។ គួរកត់សម្គាល់ថា ឈ្មោះអ្នកបកប្រែត្រូវបានសរសេរទាំងអស់ ទោះបីជាមានចំនួនប៉ុន្មាននាក់ក៏ដោយ។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកកែសម្រួល បន្ថែមលើឈ្មោះអ្នកនិពន្ធ




N: 18. ចៅ វាសនា, *ដំបូន្មានខ្មែរ*, កែសម្រួល ទេព សំណាង (ភ្នំពេញះ សុខលាប, ២០០០), ៩៩។

> នៅក្នុងសម្គាល់ប្រើតែពាក្យ “កែសម្រួល” រួចឈ្មោះអ្នកកែសម្រួល

T: (ចៅ វាសនា ២០០០, ៩៩)

B: ចៅ វាសនា. *ដំបូន្មានខ្មែរ.* កែសម្រួលដោយ ទេព សំណាង. ភ្នំពេញ៖ សុខលាប, ២០០០។

> នៅក្នុងគន្ថនិទ្ទេសប្រើពាក្យ "កែសម្រួលដោយ" រួចឈ្មោះអ្នកកែសម្រួល

R: ចៅ វាសនា. ២០០០. *ដំបូន្មានខ្មែរ.* កែសម្រួល ទេព សំណាង. ភ្នំពេញ៖ សុខលាប។

> ខុសពីគន្ថនិទ្ទេស នៅក្នុងឯកសារយោងប្រើពាក្យ "កែសម្រួល" រួចឈ្មោះអ្នកកែសម្រួល

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកបកប្រែ បន្ថែមទៅលើឈ្មោះអ្នកនិពន្ធ



ទំព័រទី៣បន្ទាប់ពីក្របមុខ

| | |
|---|---|
| ដេវិឌ ឆាណ្ឌល័រ<br>(David Chandler) | ឈ្មោះអ្នកនិពន្ធ |
| **ប្រវត្តិសាស្ត្រខ្មែរ** | ចំណងជើងសៀវភៅជាភាសាខ្មែរ |
| បកប្រែពីភាសាអង់គ្លេសដោយ<br>ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា,<br>ម៉ម វណ្ណារី, សេង សោត | ឈ្មោះអ្នកបកប្រែ |
| A History of Cambodia | ចំណងជើងដើមជាភាសាអង់គ្លេស |

ទំព័រទី៣បន្ទាប់ពីក្របមុខ

| | |
|---|---|
| រក្សាសិទ្ធិ គ.ស. ២០០០<br>បោះពុម្ពលើកទី១នៅសហរដ្ឋអាមេរិក | ឆ្នាំបោះពុម្ពលើកទី១ |
| រក្សាសិទ្ធិក្នុងការបកប្រែ និងចេញ<br>ផ្សាយជាភាសាខ្មែរ©គ.ស. ២០០៥ | ឆ្នាំបោះពុម្ពលើកទី២ |
| បោះពុម្ពនៅប្រទេសកម្ពុជា<br>ដោយរោងពុម្ព JSRC | ឈ្មោះទីកន្លែង និងឈ្មោះរោងពុម្ព |

នៅក្នុងសម្គាល់អ្នកបកប្រែ ឬអ្នកកែសម្រួលច្រើន នាក់ក៏ដោយត្រូវសរសេរឈ្មោះទាំងអស់

N: 19. David Chandler, *ប្រវត្តិសាស្ត្រខ្មែរ*, បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត (ភ្នំពេញ៖ JSRC, ២០០៥), ៩០។

T: (David Chandler ២០០៥, ៩០) ឬ (Chandler ២០០៥, ៩០)

B: Chandler, David. *ប្រវត្តិសាស្ត្រខ្មែរ.* បកប្រែដោយ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត. ភ្នំពេញ៖ JSRC, ២០០៥។

R: Chandler, David. ២០០៥. *ប្រវត្តិសាស្ត្រខ្មែរ.* បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត. ភ្នំពេញ៖ JSRC។

ចូរកត់សម្គាល់ថា នៅពេលសរសេរឈ្មោះជាភាសាអង់គ្លេសនៅក្នុងគន្ថនិទ្ទេស និងឯកសារយោងត្រូវផ្ដើមដោយគោត្តនាម រួចក្បៀស បន្ទាប់មកនាមផ្ទាល់ខ្លួន។ ចំណែកនៅក្នុងសម្គាល់ក្រោមទំព័រ ត្រូវសរសេរនាម និងគោត្តនាម។

ឧទាហរណ៍នៃសៀវភៅដែលមានឈ្មោះអ្នកប្រែសម្រួល និងអ្នកកែសម្រួលបន្ថែមទៅលើឈ្មោះអ្នកនិពន្ធ

ក្នុងករណីឈ្មោះអ្នកប្រែសម្រួល និងអ្នកកែសម្រួលផ្សេងគ្នា ឬអ្នកបកប្រែ និងកែសម្រួលផ្សេងពីគ្នា នៅក្នុងសម្គាល់ ត្រូវខណ្ឌចែកគ្នាដោយសញ្ញាក្បៀស ",″ ប៉ុន្តែនៅក្នុងគន្ថនិទ្ទេស និងឯកសារយោង ត្រូវខណ្ឌចែកគ្នាដោយសញ្ញាចុចមួយ ".″។

**សេដ្ឋកិច្ចនយោបាយ** ← ចំណងជើងសៀវភៅជា

Claude Mouchot ← ឈ្មោះអ្នកនិពន្ធសៀវភៅដើម

ប្រែសម្រួលដោយ

Im François ← ឈ្មោះអ្នកប្រែសម្រួល

កែសម្រួលដោយ

Plang Kimsie ← ឈ្មោះអ្នកកែសម្រួល

(មិនមានកាលបរិច្ឆេទបោះពុម្ពផ្សាយ និងរោងពុម្ព)

> ពាក្យ "ប្រែសម្រួល" និង "កែសម្រួល" ត្រូវបានសរសេររៀងគ្នានៅក្របមុខនៃសៀវភៅ

N: 20. Claude Mouchot, *សេដ្ឋកិច្ចនយោបាយ*, ប្រែសម្រួល Im François, កែសម្រួល Plang Kimsie (គ្មានកាលបរិច្ឆេទ), ១៥០។

> សញ្ញាក្បៀស "," ខណ្ឌចែក "ប្រែសម្រួល" និង "កែសម្រួល" ដាច់ចេញពីគ្នា

T: (Mouchot គ្មានកាលបរិច្ឆេទ, ១៥០)

B: Mouchot, Claude. *សេដ្ឋកិច្ចនយោបាយ.* ប្រែសម្រួលដោយ Im François. កែសម្រួលដោយ Plang Kimsie. គ្មានកាលបរិច្ឆេទ។

> សញ្ញាចុចមួយ "." ខណ្ឌចែក "ប្រែសម្រួលដោយ" និង "កែសម្រួលដោយ" ដាច់ចេញពីគ្នា នៅក្នុងគន្ថនិទ្ទេស

R: Mouchot, Claude. គ្មានកាលបរិច្ឆេទ. *សេដ្ឋកិច្ចនយោបាយ.* ប្រែសម្រួល Im François. កែសម្រួល Plang Kimsie។

> សញ្ញាចុចមួយ "." ខណ្ឌចែក "ប្រែសម្រួល" និង "កែសម្រួល" ដាច់ចេញពីគ្នា នៅក្នុងឯកសារយោង

ក្នុងករណីឈ្មោះអ្នកបកប្រែ និងអ្នកកែសម្រួលតែមួយ គឺគេត្រូវសរសេរជាប់គ្នាតែម្តង។




N: 21. Rigoberta Menchú, *Crossing Borders* [ការឆ្លងកាត់ព្រំដែន], trans. and ed. Ann Wright (New York: Verso, 1999), 14។

> ក្នុងភាសាអង់គ្លេសគេអាចសរសេរអក្សរកាត់ បកប្រែ = trans. និងកែសម្រួល = ed.

T: (Menchú 1999, 14)

B: Menchú, Rigoberta. *Crossing Borders* [ការឆ្លងកាត់ព្រំដែន]. Translated and edited by Ann Wright. New York: Verso, 1999។

> នៅក្នុងគន្ថនិទ្ទេស គេប្រើពាក្យពេញ គឺ "Translated and edited by"

R: Menchú, Rigoberta. 1999. *Crossing Borders* [ការឆ្លងកាត់ព្រំដែន]. Trans. and ed. Ann Wright. New York: Verso។

> នៅក្នុងឯកសារយោង គេប្រើពាក្យដូចក្នុងសម្គាល់ដែរគឺ "Trans. and ed."

### 1.9. ឈ្មោះអ្នកកែសម្រួលសំខាន់ជាងឈ្មោះអ្នកនិពន្ធ

ប្រសិនបើឈ្មោះអ្នកកែសម្រួល ឬអ្នកបកប្រែសំខាន់ក្នុងការពិភាក្សាជាងឈ្មោះអ្នកនិពន្ធដើម សៀវភៅនោះអាចនឹងត្រូវសរសេរឈ្មោះអ្នកកែសម្រួល ឬអ្នកបកប្រែជំនួសឲ្យកន្លែងឈ្មោះអ្នកនិពន្ធវិញ។ គួរកត់សម្គាល់ថា ឈ្មោះអ្នកនិពន្ធត្រូវឋិតនៅក្រោយឈ្មោះចំណងជើងដោយប្រើពាក្យ "ដោយ" នៅបន្ទាប់ពីសញ្ញាក្បៀស ","។

> អ្នកកែសម្រួល ឬអ្នកបកប្រែដែលសំខាន់ក្នុងការពិភាក្សាជាងអ្នកនិពន្ធដើម

N: 22. ជា សៅ, កែសម្រួល, *ដំណើរជីវិតឆ្ពោះទៅរកភាពជោគជ័យ*, ដោយ សំ សារាយ (ភ្នំពេញ៖ សុខលាប, ២០០៣), ៧៦។

> ឈ្មោះអ្នកនិពន្ធ

T: (ជា សៅ ២០០៣, ៧៦)

B: ជា សៅ, កែសម្រួល. *ដំណើរជីវិតឆ្ពោះទៅរកភាពជោគជ័យ,* ដោយ សំ សារាយ. ភ្នំពេញ៖ សុខលាប, ២០០៣។

R: ជា សៅ, កែសម្រួល. ២០០៣. *ដំណើរជីវិតឆ្ពោះទៅរកភាពជោគជ័យ,* ដោយ សំ សារាយ. ភ្នំពេញ៖ សុខលាប។

### 1.10. អ្នកនិពន្ធនៃបុព្វកថា ឬសេចក្តីផ្តើម

អ្នកនិពន្ធនៃបុព្វកថា ឬសេចក្តីផ្តើមចំពោះសៀវភៅដែលសរសេរដោយអ្នកនិពន្ធផ្សេង ត្រូវសរសេរចូលប្រសិនបើបុព្វកថា ឬសេចក្តីផ្តើមនោះសំខាន់ចំពោះការពិភាក្សា។

N: 23. អ៊ុន លាង និងផ្សេងទៀត, *គ្រឹះរបស់ទស្សនវិជ្ជា*, ជាមួយនឹងសេចក្តីផ្តើមដោយ វុន វ៉េត (ភ្នំពេញ, ២០០៦), ២។

T: (អ៊ុន លាង និងផ្សេងទៀត ២០០៦, ២)

B: អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សារន, ឈត ប៊ុនថង និងឈុន ផារ៉េង. *គ្រឹះរបស់ទស្សនវិជ្ជា*, ជាមួយនឹងសេចក្តីផ្តើមដោយ វុន វ៉េត. ភ្នំពេញ, ២០០៦។

R: អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សារន, ឈត ប៊ុនថង និងឈុន ផារ៉េង. ២០០៦. *គ្រឹះរបស់ទស្សនវិជ្ជា*, ជាមួយនឹងសេចក្តីផ្តើមដោយ វុន វ៉េត. ភ្នំពេញ។

### 1.11. អង្គការ ឬស្ថាប័នជាអ្នកនិពន្ធ

ប្រសិនបើស្នាដៃដែលបង្កើតឡើងមានតែឈ្មោះអង្គការ ឬស្ថាប័ន យើងត្រូវសរសេរឈ្មោះអង្គការ ឬស្ថាប័ននោះនៅត្រង់កន្លែងអ្នកនិពន្ធ។ ជារឿយៗ គេតែងសង្កេតឃើញឈ្មោះអង្គការ ឬស្ថាប័ននោះជាអ្នកបោះ

ពុម្ពផ្សាយតែម្តង។ ក្នុងករណីនេះ ត្រូវសរសេរឈ្មោះអង្គការ ឬស្ថាប័ននោះ ជំនួសឈ្មោះរោងពុម្ព។



N: 24. មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម, *វិមជ្ឈការនៅកម្ពុជា* (ភ្នំពេញៈ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម, ២០០៥), ២៥។

T: (មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ២០០៥, ២៥)

B: មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម. *វិមជ្ឈការនៅកម្ពុជា.* ភ្នំពេញៈ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម, ២០០៥។

R: មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម. ២០០៥. *វិមជ្ឈការនៅកម្ពុជា.* ភ្នំពេញៈ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម។

### 1.12. ស្នាដៃជាភាសាបរទេស

ប្រសិនបើស្នាដៃជាភាសាបរទេស ត្រូវបានប្រើនៅក្នុងការពិភាក្សា ត្រូវសរសេរឈ្មោះអ្នកនិពន្ធដើម រួចចំណងជើងទ្រេតជាភាសាបរទេស ដោយបន្ថែមការបកប្រែនៅក្នុងឃ្នាបជាអក្សរត្រង់។






N: 25. Peter F. Dale និង John D. McLaughlin, *Land Administration* [រដ្ឋបាលដីធ្លី] (New York: Oxford University Press, 1999), 34។

T: (Dale, Peter F. និង John D. McLaughlin 1999, 34) ឬ (DaleនិងJohn 1999, 34)

B: Dale, Peter F. និង John D. McLaughlin. *Land Administration* [រដ្ឋបាលដីធ្លី]. New York: OxfordUniversity Press, 1999។

R: Dale, Peter F. និង John D. McLaughlin. 1999. *Land Administration* [រដ្ឋបាលដីធ្លី]. New York: Oxford University Press។

## 1.13. ស្នាដៃដើមបូកនឹងស្នាដៃបកប្រែដែលបានបោះពុម្ពផ្សាយ

ចំពោះការយោងឯកសារបកប្រែដែលបានបោះពុម្ពផ្សាយ ហើយបើឯកសារដើមផ្តល់ចំណាប់អារម្មណ៍ដល់អ្នកអានជាង យើងអាចអនុវត្តតាមចំណុច1.8ខាងលើ។ ប៉ុន្តែ ប្រសិនបើយើងយោងទាំងឯកសារដើមទាំងឯកសារបកប្រែ តែឯកសារបកប្រែផ្តល់ចំណាប់អារម្មណ៍ដល់អ្នកអានជាង យើងត្រូវសរសេរដូចខាងក្រោម។

កន្លែងបោះពុម្ព និងរោងពុម្ពដែលបាន
បោះពុម្ពផ្សាយឯកសារដើម

N: 26. David Chandler, *History of Cambodia* (Boulder: Westview Press, 1992) បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត ជា *ប្រវត្តិសាស្ត្រខ្មែរ* (ភ្នំពេញ៖ JSRC, ២០០៥), ៩០។

បន្ថែមពាក្យ "ជា *ប្រវត្តិសាស្ត្រខ្មែរ*" មានន័យថា
ឯកសារបកប្រែផ្តល់ចំណាប់អារម្មណ៍ដល់អ្នកអានជាង

កន្លែងបោះពុម្ព និងរោងពុម្ពដែលបាន
បោះពុម្ពផ្សាយឯកសារបកប្រែ

ឬ

27. David Chandler, *ប្រវត្តិសាស្ត្រខ្មែរ*, បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត (ភ្នំពេញ៖ JSRC, ២០០៥), ៩០។ ឯកសារដើមត្រូវបានបោះពុម្ពផ្សាយជា *History of Cambodia* (Boulder: Westview Press, 1992)។

កន្លែងបោះពុម្ព និងរោងពុម្ពដែលបាន
បោះពុម្ពផ្សាយឯកសារដើម

T: (David Chandler ២០០៥, ៩០)

B: Chandler, David. *History of Cambodia*. Boulder: Westview Press, 1992. បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត ជា *ប្រវត្តិសាស្ត្រខ្មែរ* (ភ្នំពេញ៖ JSRC, ២០០៥)។

ឬ

Chandler, David. *ប្រវត្តិសាស្ត្រខ្មែរ*, បកប្រែដោយ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត. ភ្នំពេញ៖ JSRC, ២០០៥។ ឯកសារដើមសរសេរជា *History of Cambodia* (Boulder: Westview Press, 1992)។

R: Chandler, David. 1992. *History of Cambodia*. Boulder: Westview Press. បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត ជា *ប្រវត្តិសាស្ត្រខ្មែរ* (ភ្នំពេញ៖ JSRC, ២០០៥)។

ឬ

Chandler, David. ២០០៥. *ប្រវត្តិសាស្ត្រខ្មែរ*, បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត. ភ្នំពេញ៖ JSRC។ ឯកសារដើមសរសេរជា *History of Cambodia* (Boulder: Westview Press, 1992)។

### 1.14. ឯកសារបកប្រែមិនបានបោះពុម្ពផ្សាយ

ប្រសិនបើឯកសារបកប្រែមិនត្រូវបានបោះពុម្ពផ្សាយទេ ហើយយើងយោងទៅលើឯកសារបកប្រែនោះ ត្រូវសរសេរឈ្មោះចំណងជើងជាអក្សរខ្មែរ ដោយបញ្ជាក់ភាសាដើមនៅក្នុងឃ្នាបផងដូចជា "ជាភាសាអង់គ្លេស" "ជាភាសាបារាំង" ជាដើម។

N: 28. សុខ សំណាង, *រដ្ឋបាលដីធ្លី* [ជាភាសាអង់គ្លេស] (Oxford: Oxford University Press, 1999), 34។

T: (សុខ សំណាង ១៩៩៩, ៣៤)

B: សុខ សំណាង. *រដ្ឋបាលដីធ្លី* [ជាភាសាអង់គ្លេស]. Oxford: Oxford University Press, 1999។

R: សុខ សំណាង. ១៩៩៩. *រដ្ឋបាលដីធ្លី* [ជាភាសាអង់គ្លេស]. Oxford: Oxford University Press។

### 1.15. ជំពូក ឬផ្នែកខ្លះនៅក្នុងសៀវភៅដែលមានអ្នកនិពន្ធតែម្នាក់

ប្រសិនបើយើងចង់យោងទៅលើជំពូក ឬផ្នែកណាមួយជាក់លាក់នៅក្នុងសៀវភៅដែលមានអ្នកនិពន្ធតែមួយ ត្រូវសរសេរឈ្មោះជំពូក ឬផ្នែកនោះជាអក្សរឈរធម្មតានៅក្នុងអត្ថន្តរសញ្ញា លើកលែងតែនៅក្នុងឯកសារយោង យើងមិនចាំបាច់ដាក់ក្នុងអត្ថន្តរសញ្ញាឡើយ។



នៅក្នុងសម្គាល់ និងគន្ថនិទ្ទេសត្រូវ
ដាក់ចំណងជើងក្នុងអព្ភន្តរសញ្ញា

N: 29. កន វាសនា, "ជីវិត និងការពិត," ជំពូក៣ នៅក្នុង *គន្លឹះសំខាន់សម្រាប់ជីវិតជោគជ័យ* (ភ្នំពេញ៖ សុខលាប, ២០០៧), ៥៧-៥៨។

T: (កន វាសនា ២០០៧, ៥៧-៥៨)

នៅក្នុងគន្ថនិទ្ទេសត្រូវដាក់ចំណងជើង
ក្នុងអព្ភន្តរសញ្ញា

B: កន វាសនា. "ជីវិត និងការពិត." ជំពូក៣ នៅក្នុង *គន្លឹះសំខាន់សម្រាប់ជីវិតជោគជ័យ*, ៤៦-៩០. ភ្នំពេញ៖ សុខលាប, ២០០៧។

នៅក្នុងឯកសារយោងមិនចាំបាច់
ដាក់ចំណងជើងក្នុងអព្ភន្តរសញ្ញាទេ

R: កន វាសនា.២០០៧. ជីវិត និងការពិត. ជំពូក៣ នៅក្នុង *គន្លឹះសំខាន់សម្រាប់ជីវិតជោគជ័យ*, ៤៦-៩០. ភ្នំពេញ៖ សុខលាប។

### 1.16. សៀវភៅដែលចងក្រងដោយអ្នកនិពន្ធច្រើន

នៅពេលយើងយោងទៅលើសៀវភៅ ដែលចងក្រងដោយអ្នកនិពន្ធច្រើនទៅតាមផ្នែករបស់វា យើងត្រូវសរសេរឈ្មោះអ្នកនិពន្ធរបស់ផ្នែកនោះ រួចចំណងជើងរបស់វានៅក្នុងអព្ភន្តរសញ្ញា តែក្នុងឯកសារយោងមិនបាច់ដាក់ក្នុងអព្ភន្តរសញ្ញា បន្ទាប់មកប្រើពាក្យ "នៅក្នុង" រួចសរសេរចំណងជើងជាអក្សរទ្រេតរួចប្រើពាក្យ "កែសម្រួល" ប៉ុន្តែនៅក្នុងគន្ថនិទ្ទេសប្រើពាក្យ "កែសម្រួលដោយ" បន្ទាប់មកឈ្មោះអ្នកកែសម្រួល។




N: 30. ស វាសនា និងសំ សុខា, "ជីវិត និងការតស៊ូ," នៅក្នុង *ខ្លឹមសារនៃជីវិត,* កែសម្រួល ផាត់ សាយ (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៩), ៩៧។

T: (ស វាសនា និងសំ សុខា ២០០៩, ៩៧)

B: ស វាសនា និងសំ សុខា. "ជីវិត និងការតស៊ូ." នៅក្នុង *ខ្លឹមសារនៃជីវិត,* កែសម្រួលដោយ ផាត់ សាយ, ៨៩-១០៥. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៩។

> នៅក្នុងគន្ថនិទ្ទេស ត្រូវប្រើពាក្យ"កែសម្រួលដោយ"

> នៅក្នុងគន្ថនិទ្ទេស និងឯកសារយោងត្រូវសរុបចំនួនទំព័រដោយសរសេរទំព័រដែលជំពូកចាប់ផ្តើម និងបញ្ចប់

R: ស វាសនា និងសំ សុខា. ២០០៩. ជីវិត និងការតស៊ូ. នៅក្នុង *ខ្លឹមសារនៃជីវិត,* កែសម្រួល ផាត់ សាយ, ៨៩-១០៥. ភ្នំពេញ៖ បណ្ណាគារអង្គរ។

> ជំពូក ឬផ្នែក "ជីវិត និងការតស៊ូ" ចាប់ផ្តើមនៅទំព័រ៨៩ និងបញ្ចប់នៅទំព័រ១០៥

**សម្គាល់៖** រាល់ស្នាដៃដែលមានលក្ខណៈដូចចំណុច1.16 ខាងលើ ឯកសារចងក្រងពីសន្និសីទដែលមានអ្នកនិពន្ធផ្សេងៗទៅតាមផ្នែកនីមួយៗ យើងត្រូវអនុវត្តតាមចំណុចខាងលើនេះដែរ។

N: 31. Nakagawa Kasumi, "កិច្ចសហការរវាងស្ថាប័នរដ្ឋ និងផ្នែកឯកជនដើម្បីទប់ស្កាត់ Sexual harassment," នៅក្នុង *សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជនលើការបញ្ជ្រាបយេនឌ័រ* (ភ្នំពេញ៖ ក្រសួងកិច្ចការនារី, ២០០៩), ៨៩។

T: (Kasumi ២០០៩, ៨៩)

B: Kasumi, Nakagawa. "កិច្ចសហការរវាងស្ថាប័នរដ្ឋ និងផ្នែកឯកជនដើម្បីទប់ស្កាត់ Sexual harassment," នៅក្នុង *សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជនលើការ*

*វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា បញ្ហាបយេនឌ័រ, ៣៦-៤៥.* ភ្នំពេញ៖ ក្រសួងកិច្ចការនារី, ២០០៩។

R: Kasumi, Nakagawa. ២០០៩. កិច្ចសហការរវាងស្ថាប័នរដ្ឋ និងផ្នែកឯកជនដើម្បីទប់ស្កាត់ Sexual harassment, នៅក្នុង *សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជនលើការបញ្ហាបយេនឌ័រ, ៣៦-៤៥.* ភ្នំពេញ៖ ក្រសួងកិច្ចការនារី។

## 2. សំបុត្រ និងឯកសារទំនាក់ទំនងផ្សេងៗដែលបានប្រមូលបោះពុម្ព

### 2.17. អ្នកសរសេរ

ការយោងទៅនឹងសំបុត្រ កំណត់ហេតុ ឬឯកសារទំនាក់ទំនងផ្សេងទៀតដែលបានបោះពុម្ពផ្សាយត្រូវចាប់ផ្តើមដោយឈ្មោះអ្នកផ្ញើ និងអ្នកទទួល ទៅតាមលំដាប់របស់វា បន្ទាប់មកកាលបរិច្ឆេទ និងពេលខ្លះកន្លែងសរសេររបស់វា។ ចំណងជើងនៃឈ្មោះកម្រងឯកសារបោះពុម្ពនោះត្រូវសរសេរដូចចំណងជើងសៀវភៅដែរ។ អ្នកកែសម្រួល កន្លែងបោះពុម្ព និងឈ្មោះរោងពុម្ព ត្រូវសរសេរជាបន្តបន្ទាប់ដូចក្នុងករណីសៀវភៅដែរ។ ចំពោះសំបុត្រ យើងមិនចាំបាច់សរសេរពាក្យ "សំបុត្រ" ទេ ប៉ុន្តែរាល់ឯកសារទំនាក់ទំនងផ្សេងទៀតត្រូវសរសេរ បន្ទាប់ពីឈ្មោះអ្នកទទួលដោយមានសញ្ញាក្បៀស ","។

**ករណីសំបុត្រ**

N: 32. សុខ សំណាង សរសេរទៅកាន់ បាន ហេង, កំពត, ១៣ មករា ២០០៩, នៅក្នុង *កម្រងសំបុត្ររបស់លោក សុខ សំណាង ឆ្នាំ២០០៩,* ចងក្រងដោយ ទិត តៅ (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១០), ១៦០។

T: (សុខ សំណាង, សំបុត្រ)

B: សុខ សំណាង. សុខ សំណាង សរសេរទៅកាន់ បាន ហេង, កំពត, ១៣ មករា ២០០៩. នៅក្នុង *កម្រងសំបុត្ររបស់លោក សុខ សំណាង ឆ្នាំ២០០៩,* ចងក្រងដោយ ទិត តៅ. ភ្នំពេញ៖

*វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា* បណ្ណាគារអង្គរ, ២០១០។

R: សុខ សំណាង. ២០១០. *កម្រងសំបុត្ររបស់លោក សុខ សំណាង ឆ្នាំ២០០៩,* ចងក្រង ទិត គៅ. ភ្នំពេញ៖ បណ្ណាគារអង្គរ។

**ករណីកំណត់ហេតុ**

N: 33. វាំង សាត សរសេរទៅកាន់ សុខ កំសាន្ត, កំណត់ហេតុ, ២៧ វិច្ឆិកា ១៩៩៩, នៅក្នុង *កម្រងកំណត់ហេតុនាយកដ្ឋានផែនការរបស់ក្រសួងអប់រំឆ្នាំ១៩៩៩,* ចងក្រងដោយលោក ចាន់ សំណាប់ (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១០), ១៦០។

T: (វាំង សាត, កំណត់ហេតុ, ១៩៩៩)

B: វាំង សាត. វាំង សាត សរសេរទៅកាន់ កើត កំសាន្ត, កំណត់ហេតុ, ២៧ វិច្ឆិកា ១៩៩៩. នៅក្នុង *កម្រងកំណត់ហេតុនាយកដ្ឋានផែនការរបស់ក្រសួងអប់រំឆ្នាំ១៩៩៩,* ចងក្រងដោយលោក ចាន់ សំណាប់. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១០។

R: វាំង សាត. ២០១០. *កម្រងកំណត់ហេតុនាយកដ្ឋានផែនការរបស់ក្រសួងអប់រំឆ្នាំ១៩៩៩,* ចងក្រងដោយលោក ចាន់ សំណាប់. ភ្នំពេញ៖ បណ្ណាគារអង្គរ។

## 3. ការបោះពុម្ព

### 3.18. ការបោះពុម្ពបន្តបន្ទាប់ក្រៅពីការបោះពុម្ពលើកទី១

នៅពេលការបោះពុម្ពបន្តបន្ទាប់ផ្សេងពីការបោះពុម្ពលើកទី១ ត្រូវបានសរសេរយោង ត្រូវសរសេរ "បោះពុម្ពលើកទីបន្តបន្ទាប់នោះ" ឬ"បោះពុម្ពឡើងវិញ" នៅបន្ទាប់ពីចំណងជើង។

ជាទូទៅ ចំនួនលើកនៃការបោះពុម្ពបិតនៅខាងមុខនៃក្របទំព័រ ឬទំព័របន្ទាប់នៃសៀវភៅ។ បើវាបិតនៅទំព័របន្ទាប់ នោះវាត្រូវបានគេសរសេរឡើង

វិញជាមួយនឹងឆ្នាំបោះពុម្ពនៅកន្លែងទំព័ររក្សាសិទ្ធិ។ គេច្រើនប្រើពាក្យ "បោះពុម្ពលើកទី៣" ឬ"បោះពុម្ពកែសម្រួលឡើងវិញ" ឬ"បោះពុម្ពឡើងវិញ" ជាដើម។

ពាក្យថា "បោះពុម្ពលើកទី២, បោះពុម្ពលើកទី៣" ជាដើម មានន័យថា ការបោះពុម្ពនោះ គឺមានការកែសម្រួលឲ្យប្រសើរជាងការបោះពុម្ពលើកមុន។ ចំណែកឯពាក្យ "បោះពុម្ពកែសម្រួលឡើងវិញ" មានន័យដូចគ្នានឹងការបោះពុម្ពលើកទី២ ឬទី៣ដែរ គឺមានការកែសម្រួលឲ្យប្រសើរជាងការបោះពុម្ពលើកមុន ប៉ុន្តែគ្រាន់តែមិនបានប្រើពាក្យ "បោះពុម្ពលើកទី..." ប៉ុណ្ណោះ។ ចំពោះពាក្យ "បោះពុម្ពឡើងវិញ" មានន័យថា ការបោះពុម្ពនេះដូចគ្នាបេះបិទនឹងការបោះពុម្ពលើកមុន ពោលគឺមិនមានការសម្រួលអ្វីឡើយ។

ឧទាហរណ៍សៀវភៅដែលត្រូវបានបោះពុម្ពលើកទី៣

ទំព័រក្របមុខ ទំព័រទី៣បន្ទាប់ពីក្របមុខ



N: 34. សាយ បូរី, *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣ (ភ្នំពេញៈ ប្លុស្សំឡូទឹស, ២០០២), ១៩១។

T: (សាយ បូរី ២០០២, ១៩១)

B: សាយ បូរី. *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣. ភ្នំពេញៈ ប្លុស្សំឡូទឹស, ២០០២។

R: សាយ បូរី. ២០០២. *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣. ភ្នំពេញៈ ប្លុស្សំឡូទឹស។

ឧទាហរណ៍សៀវភៅដែលត្រូវបានបោះពុម្ពកែសម្រួលឡើងវិញ




N: 35. សំ វាសនា, *នីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពកែសម្រួលឡើងវិញ (ភ្នំពេញៈ សុខលាប, ២០០៣), ១០១។

T: (សំ វាសនា ២០០៣, ១០១)

B: សំ វាសនា. *នីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពកែសម្រួលឡើងវិញ. ភ្នំពេញៈ សុខលាប, ២០០៣។

R: សំ វាសនា. ២០០៣. *នីតិរដ្ឋធម្មនុញ្ញ*, បោះពុម្ពកែសម្រួលឡើងវិញ. ភ្នំពេញ៖ សុខលាប។

ឧទាហរណ៍សៀវភៅដែលត្រូវបានបោះពុម្ពឡើងវិញ






N: 36. អៀវ កើស, រៀបរៀង, *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល*, បោះពុម្ពឡើងវិញ (ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០១), ១៨-១៩។

T: (អៀវ កើស ២០០១, ១៨-១៩)

B: អៀវ កើស, រៀបរៀង. *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល*, បោះពុម្ពឡើងវិញ. ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០១។

R: អៀវ កើស, រៀបរៀង. ២០០១. *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល*, បោះពុម្ពឡើងវិញ. ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

## 4. ស្នាដៃដែលមានច្រើនភាគ

### 4.19. ការយោងទាំងមូលទៅលើស្នាដៃដែលមានច្រើនភាគ

នៅពេលស្នាដៃដែលមានច្រើនភាគ ត្រូវបានសរសេរយោងទាំងមូល ចំនួនសរុបនៃភាគនោះត្រូវសរសេរបន្ទាប់ពីចំណងជើង។ ក្នុងករណីមានអ្នកកែសម្រួល ត្រូវសរសេរឈ្មោះអ្នកកែសម្រួលចូលបន្ទាប់ពីពាក្យ "កែសម្រួល" ចំពោះសម្គាល់ ឬឯកសារយោង និងពាក្យ "កែសម្រួលដោយ" ចំពោះគន្ថនិទ្ទេស។ ប្រសិនបើភាគទាំងអស់នោះត្រូវបានបោះពុម្ពបន្តបន្ទាប់នៅឆ្នាំផ្សេងគ្នា ត្រូវដាក់ឆ្នាំបោះពុម្ពភាគដំបូង និងភាគបញ្ចប់របស់វា។

**ចំពោះសម្គាល់**

N: 37. កង ដារ៉ូ, *ដំណើរជោគជ័យនៃជីវិត*, កែសម្រួល ចាន់ តារា (ភ្នំពេញ៖ សុខលាប, ២០០៤), ១៖ ១៨២។

ឆ្នាំបោះពុម្ពភាគទី១ | ភាគទី១ | ទំព័រយោង

38. កង ដារ៉ូ, *ដំណើរជោគជ័យនៃជីវិត*, កែសម្រួល ចាន់ តារា (ភ្នំពេញ៖ សុខលាប, ២០០៤), ២៖ ២៦។

ឆ្នាំបោះពុម្ពភាគទី២ | ភាគទី២ | ទំព័រយោង

39. ពៅ ចំណាប់, *យុទ្ធសាស្ត្រជោគជ័យ*, កែសម្រួល រុន នារី (ភ្នំពេញ៖ បណ្ណាគារអង្គរ, ១៩៩៩), ១៖ ២០៥។

ឆ្នាំបោះពុម្ពភាគទី១ | ភាគទី១ | ទំព័រយោង

40. ពៅ ចំណាប់, *យុទ្ធសាស្ត្រជោគជ័យ*, កែសម្រួល រុន នារី (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០០), ២៖ ២០០។

ឆ្នាំបោះពុម្ពភាគទី២ | ភាគទី២ | ទំព័រយោង

41. ពៅ ចំណាប់, *យុទ្ធសាស្ត្រជោគជ័យ*, កែសម្រួល រុន នារី (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០២), ៣៖ ២៤០។

ឆ្នាំបោះពុម្ពភាគទី៣ | ភាគទី៣ | ទំព័រយោង

42. ពៅ ចំណាប់, *យុទ្ធសាស្ត្រជោគជ័យ*, កែសម្រួល រុន នារី (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៣), ៤៖ ១៦៥។

ឆ្នាំបោះពុម្ពភាគទី៤ | ភាគទី៤ | ទំព័រយោង

T: (កង ដារ៉ូ ២០០៤, ១៖ ១៨២)
(កង ដារ៉ូ ២០០៤, ២៖ ១៨២)
(ពៅ ចំណាប់ ១៩៩៩, ១៖ ២០៥)
(ពៅ ចំណាប់ ២០០០, ២៖ ២០០)
(ពៅ ចំណាប់ ២០០២, ៣៖ ២៤០)

*វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា*
(ពៅ ចំណាប់ ២០០៣, ៥៖ ១៦៥)

**ចំពោះគន្ថនិទ្ទេស និងឯកសារយោង**

B: កង ដារ៉ូ. *ដំណើរជោគជ័យនៃជីវិត*, កែសម្រួលដោយ ចាន់ តារា, ២ភាគ. ភ្នំពេញ៖ សុខលាប, ២០០៥។

ចំនួនភាគសរុបមាន២ភាគ

ឆ្នាំបោះពុម្ពភាគទាំងពីរគឺឆ្នាំ២០០៥

ពៅ ចំណាប់, *យុទ្ធសាស្ត្រជោគជ័យ*, កែសម្រួលដោយ រុន នារី, ៥ ភាគ. ភ្នំពេញ៖ បណ្ណាគារអង្គរ, ១៩៩៩-២០០៣។

ចំនួនភាគសរុបមាន៥ភាគ

ឆ្នាំបោះពុម្ពភាគទី១នៅឆ្នាំ១៩៩៩
និងភាគទី៥នៅឆ្នាំ២០០៣

R: កង ដារ៉ូ. ២០០៥. *ដំណើរជោគជ័យនៃជីវិត*, កែសម្រួល ចាន់ តារា, ២ភាគ. ភ្នំពេញ៖ សុខលាប។
ពៅ ចំណាប់. ១៩៩៩-២០០៣. *យុទ្ធសាស្ត្រជោគជ័យ*, កែសម្រួល រុន នារី, ៥ភាគ. ភ្នំពេញ៖ បណ្ណាគារអង្គរ។

### 4.20. ការយោងទៅលើភាគណាមួយជាក់លាក់នៃស្នាដៃដែលមានច្រើនភាគ

ចំពោះការយោងទៅលើភាគណាមួយច្បាស់លាស់ នៅក្នុងសម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទ ត្រូវបញ្ជាក់តែភាគនោះដោយមានបញ្ជាក់ទំព័រ។ ចំណែកនៅក្នុងគន្ថនិទ្ទេស ឬឯកសារយោង ត្រូវបញ្ជាក់តែភាគជាក់លាក់ណាមួយនោះជាការស្រេច ដោយមិនចាំបាច់បញ្ជាក់ភាគសរុបដូចនៅក្នុងចំណុច 4.19 ខាងលើទេ។

N: 39. សាន សំណាង, កែសម្រួល, *យុទ្ធសាស្ត្រឈ្នះៗ* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៨), ៤៖ ១៨២។

ភាគ៤ជាភាគដែលយោង

40. រុន រស្មី, *ទំពាំងស្នងឫស្សី*, ភាគ២, *វ័យជំទង់* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៤), ១៩០។

ចំណងជើងសៀវភៅ<br>ដែលមានច្រើនភាគ

ចំណងជើងភាគ

លេខភាគដែលយោង

T: (សាន សំណាង ២០០៨, ៤៖ ១៨២)
(រុន រស្មី ២០០៤, ២៖ ១៩០)

B: សាន សំណាង, កែសម្រួល. *យុទ្ធសាស្ត្រឈ្នះៗ.* ភាគ៤. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៨។
រុន រស្មី. *ទំពាំងស្នងឫស្សី.* ភាគ២, *វ័យជំទង់* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៤។

R: សាន សំណាង, កែសម្រួល. ២០០៨. *យុទ្ធសាស្ត្រឈ្នះៗ.* ភាគ៤. ភ្នំពេញ៖ បណ្ណាគារអង្គរ។
រុន រស្មី. ២០០៤. *វ័យជំទង់.* ភាគ២ នៃ *ទំពាំងស្នងឫស្សី.* ភ្នំពេញ៖ បណ្ណាគារអង្គរ។

ចំណងជើងភាគ

ចំណងជើងសៀវភៅ<br>ដែលមានច្រើនភាគ

លេខភាគដែលយោង

## 5. សៀវភៅអេឡិចត្រូនិក

### 5.21. សៀវភៅដែលចុះផ្សាយតែនៅក្នុងអ៊ិនធឺណិត

នៅពេលយោងទៅលើសៀវភៅដែលអាចរកបានតាមរយៈអ៊ិនធឺណិត ទៅតាមគេហទំព័រដែលយើងអាចទុកចិត្តបាន របៀបនៃការសរសេរយោង ត្រូវសរសេរដូចគ្នានឹងសៀវភៅដែលបានបោះពុម្ព ដោយគ្រាន់តែបញ្ជាក់ ឈ្មោះគេហទំព័ររបស់សៀវភៅនោះខាងក្រោយព័ត៌មានរបស់សៀវភៅ។ ជាមួយគ្នានេះដែរ ដើម្បីបញ្ជាក់ច្បាស់ពីកាលបរិច្ឆេទនៃការដកយកឯកសារ ឬថតចម្លងយកឯកសារនោះ គប្បីបញ្ជាក់កាលបរិច្ឆេទនៃការដកយក ឬថត ចម្លងយកឯកសារក្នុងរង្វង់ក្រចក។

N: 41. វ៉ន វ៉ុន, *ការរៀបចំផែនទីចង្អុលបង្ហាញផ្លូវ* (បាត់ដំបង៖ សូរិយា, ២០១០), ១៩៧, http://www.soriya.com/book (ថតចម្លងថ្ងៃទី១៧ វិច្ឆិកា ២០១០)។

> សញ្ញាក្បៀសរួចឈ្មោះគេហទំព័រ មានន័យថាឯកសារ ដែលយោងនេះគឺដកស្រង់យកតែពីអ៊ិនធឺណិត

T: (វ៉ន វ៉ុន ២០១០, ១៩៧)

B: វ៉ន វ៉ុន. *ការរៀបចំផែនទីចង្អុលបង្ហាញផ្លូវ.* បាត់ដំបង៖ សូរិយា, ២០១០. http://www.soriya.com/book (ថតចម្លងថ្ងៃទី១៧ វិច្ឆិកា ២០១០)។

> នៅក្នុងគន្ថនិទ្ទេស និងនៅក្នុងឯកសារយោង គេប្រើសញ្ញាចុច រួច ឈ្មោះគេហទំព័រ មានន័យថាឯកសារដែលយោងនេះគឺដកស្រង់ យកតែពីអ៊ីនធើណេត

R: វ៉ន វ៉ុន. ២០១០. *ការរៀបចំផែនទីចង្អុលបង្ហាញផ្លូវ.* បាត់ដំបង៖ សូរិយា. http://www.soriya.com/book (ថតចម្លងថ្ងៃទី១៧ វិច្ឆិកា ២០១០)។

គួរកត់សម្គាល់ថា ការផ្តល់ប្រភពចេញពីគេហទំព័រ អាចនឹងទន់ខ្សោយ ដោយហេតុថា ប្រភពនោះអាចនឹងលែងមាននៅក្នុងគេហទំព័រនៅពេលណាមួយ។ ដូច្នេះ ការផ្តល់ព័ត៌មានពីរោងពុម្ព និងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងឯកសារជាការសំខាន់។

## 5.22. សៀវភៅដែលបានបោះពុម្ព និងអាចរកបាននៅតាមអ៊ិនធឺណិត

នៅពេលយោងទៅលើសៀវភៅដែលបានបោះពុម្ព ហើយសៀវភៅនោះអាចរកបាននៅតាមអ៊ិនធឺណិត ត្រូវប្រើពាក្យ "អាចរកបាននៅ" ឬ "ក៏អាចរកបាននៅ" រួចឈ្មោះនៃគេហទំព័ររបស់វា។

N: 42. វ៉ន វ៉ុន, *ការរៀបចំផែនទីចង្អុលបង្ហាញផ្លូវ* (បាត់ដំបង៖ សូរិយា, ២០១០), ១៩៧, អាចរកបាននៅ http://www.soriya.com/book (ថតចម្លងថ្ងៃទី៣០ វិច្ឆិកា ២០១០)។

ប្រើពាក្យ "អាចរកបាននៅ" រួចឈ្មោះគេហទំព័រ មានន័យថាប្រភពនេះដកស្រង់ចេញពីសៀវភៅបោះពុម្ព តែអាចរកបាននៅតាមអ៊ីនធើណេត

T: (វ៉ន វ៉ុន ២០១០, ១៩៧)

B: វ៉ន វ៉ុន. *ការរៀបចំផែនទីចង្អុលបង្ហាញផ្លូវ.* បាត់ដំបង៖ សូរិយា, ២០១០. អាចរកបាននៅ http://www.soriya.com/book (ថតចម្លងថ្ងៃទី៣០ វិច្ឆិកា ២០១០)។

R: វ៉ន វ៉ុន. ២០១០. *ការរៀបចំផែនទីចង្អុលបង្ហាញផ្លូវ.* បាត់ដំបង៖ សូរិយា. អាចរកបាននៅ http://www.soriya.com/book (ថតចម្លងថ្ងៃទី៣០ វិច្ឆិកា ២០១០)។

ទាំងគន្ថនិទ្ទេស និងឯកសារយោងត្រូវប្រើសញ្ញាចុចនៅពីមុខពាក្យ "អាចរកបាននៅ"។

### 6. ជើនណាល ទស្សនាវដ្ដី និងកាសែត (Periodicals)

ជាទូទៅ មានព័ត៌មានចាំបាច់មួយចំនួនក្នុងការយោងទៅលើជើនណាល (Journals) ទស្សនាវដ្ដី (Magazines) និងកាសែត (Newspapers) អាចត្រូវបានផ្ដល់ឲ្យដូចខាងក្រោម៖

- ឈ្មោះអ្នកនិពន្ធ
- ចំណងជើង និងចំណងជើងរងនៃប្រធានបទ
- ចំណងជើងនៃជើនណាល ទស្សនាវដ្ដី និងកាសែត
- ព័ត៌មានទាក់ទងនឹងលេខផ្សាយ (លេខភាគ លេខរឿង កាលបរិច្ឆេទ ជាដើម)
- ទំព័រដែលត្រូវយោង
- ឈ្មោះនៃគេហទំព័រ

### 6.23. ជើនណាល (Journals)

ការយោងទៅលើជើនណាល ត្រូវសរសេរឈ្មោះអ្នកនិពន្ធ រួចចំណងជើងនៅក្នុងអព្ភន្តរសញ្ញា បន្ទាប់មកឈ្មោះនៃជើនណាលជាអក្សរទ្រេត និងលេខភាគរបស់ជើនណាល ដោយបញ្ជាក់ពីកាលបរិច្ឆេទបោះពុម្ពរបស់ជើនណាលនៅក្នុងរង្វង់ក្រចក ចុងក្រោយដោយមានបញ្ជាក់ទំព័រ។ ជាទូទៅនៅប្រទេសកម្ពុជាមិនទាន់មានជើនណាលល្បីល្បាញនៅឡើយ។ ដូច្នេះក្នុងឧទាហរណ៍ខាងក្រោម ខ្ញុំនឹងលើកយកឧទាហរណ៍នៃជើនណាលបរទេសមកបង្ហាញតែប៉ុណ្ណោះ ដោយអនុវត្តតាមវិធីជីកាហ្គោ (Chicago Style) គ្រាន់តែបកប្រែចំណងជើងប្រធានបទនៅក្នុងសញ្ញាឃ្នាប។

គួរកត់សម្គាល់ថា ពាក្យ "Journals" ក្នុងន័យខាងលើនេះ ពិបាកនឹងរកពាក្យជាភាសាខ្មែរប្រើឲ្យចំណាស់។ នៅក្នុងឯកសារ "គោលនយោបាយស្ដីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ" ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា នៅខែកក្កដា ឆ្នាំ២០១០ មានប្រើពាក្យ "ទស្សនាវដ្ដីស្រាវជ្រាវ" ដែលអាចប្រែជាភាសាអង់គ្លេស "research journal"។ ចំណែក

អនុក្រឹត្យស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត លេខ១៥១អនក្រ/បក ដែលចេញដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ មានប្រើពាក្យ "ទស្សនាវដ្តីវិទ្យាសាស្ត្រ ឬទស្សនាវដ្តីបោះពុម្ពដោយសមាគមវិជ្ជាជីវៈ" ដែលប្រែទៅជាភាសាអង់គ្លេសថា "scientific journal or journal published by professional association"។ ភាសាខ្មែរក៏មានពាក្យទស្សនាវដ្ដី ដែលបកប្រែជាភាសាអង់គ្លេសថា "magazine"។ ដូច្នេះដើម្បីជៀសវាងការភាន់ច្រឡំគ្នា ខ្ញុំប្រើពាក្យ "journal" ជាសំឡេងភាសាខ្មែរ "ជើនណល" ដើម្បីឲ្យមានភាពងាយស្រួលក្នុងការយល់តាមន័យដើមរបស់វាតែម្តង។ នៅពេលមានការប្រើពាក្យឯកភាពគ្នាជាភាសាខ្មែរ យើងអាចដូរមកប្រើពាក្យនោះវិញ។



Building upon the United Nations efforts in Namibia and Central America, it may be the harbinger **[*41]** of an enhanced United Nations role in the resolution of regional conflicts, as envisioned under chapter VI of the Charter. [246] With the end of the Cold War, the United Nations has moved...

**Legal Topics:**

For related research and practice materials, see the following legal topics:

**FOOTNOTES:**

n1 For the texts, see Letter dated 30 October 1991 from the Permanent Representatives of France and Indonesia to the United Nations addressed to the Secretary-General, UN Doc. A/46/608-S/23177, Annex (1991), *reprinted in* 31 ILM 180 (1992). The signatory states to the Paris accords are Australia, Brunei, Cambodia, Canada, China, France, India, Indonesia, Japan, Laos, Malaysia, the Philippines, Singapore, the USSR, the United Kingdom, the United States, Vietnam and Yugoslavia.

....

ទំព័រចុងក្រោយនៃប្រធានបទ

លេខសម្គាល់ក្រោមទំព័រ

**សម្គាល់ក្រោមទំព័រ** លេខសម្គាល់ក្រោមទំព័រត្រូវបានគេដាក់នៅខាងចុងអត្ថបទសម្រាប់តែជើនណលដែលគេផ្សាយនៅក្នុងគេហទំព័រ Lexisnexis តែប៉ុណ្ណោះ ប៉ុន្តែនៅក្នុងជើនណលដែលត្រូវបានបោះពុម្ពផ្សាយ សម្គាល់ក្រោមទំព័រត្រូវបានដាក់នៅតាមទំព័រនីមួយៗ

ចំណងជើងប្រធានបទនៅក្នុងអព្ភន្តរសញ្ញា

N: 43. Steven R. Ratner, "The Cambodian Settlement Agreements" [កិច្ចព្រមព្រៀងដំណោះស្រាយកម្ពុជា], *American Journal of International Law* 87 (មករា 1993): 18។

ចំណងជើងនៃជើនណល

លេខជើនណល

ទំព័រយោងនៅបន្ទាប់ពីសញ្ញាចុចពីរ

T: (Ratner 1993, 18)

ចំណងជើងប្រធានបទនៅក្នុងអព្ភន្តរសញ្ញា លើកលែងតែក្នុងឯកសារយោង

B: Ratner, Steven R. "The Cambodian Settlement Agreements" [កិច្ចព្រមព្រៀងដំណោះស្រាយកម្ពុជា]. *American Journal of International Law* 87 (មករា 1993): 1-41។

លេខជើនណាល ត្រូវសរសេរត្រង់

ទំព័រចាប់ផ្ដើម និងទំព័របញ្ចប់របស់ប្រធានបទនៅបន្ទាប់ពីសញ្ញាចុចពីរ

ចំណងជើងនៃជើនណាលជាអក្សរទ្រេត

ក្នុងឯកសារយោងចំណងជើងប្រធានបទមិនចាំបាច់ដាក់នៅក្នុងអព្ភន្តរសញ្ញាទេ

R: Ratner, Steven R. 1993. The Cambodian Settlement Agreements [កិច្ចព្រមព្រៀងដំណោះស្រាយកម្ពុជា]. *American Journal of International Law* 87 (មករា): 1-41។

ក្នុងឯកសារយោងគេរក្សាទុកខែ និងថ្ងៃនៅកន្លែងដដែលពោលគឺយកតែឆ្នាំទៅដាក់ចន្លោះឈ្មោះអ្នកនិពន្ធ និងចំណងជើង

ជើងណាលនៅក្នុងគេហទំព័ររបស់ Lexisnexis អាមេរិកាំង ត្រូវបានគេសង្ខេបក្នុងទម្រង់ដូចខាងក្រោមនេះ ដើម្បីងាយស្រួលយល់។



ការផ្តល់ប្រភពទាក់ទងនឹងជើនណលខាងលើ ត្រូវបានអនុវត្តដូចខាងក្រោម៖

ឈ្មោះអ្នកនិពន្ធ

ចំណងជើងប្រធានបទនៅក្នុងអព្តន្តរសញ្ញា

បកប្រែចំណងជើងប្រធានបទនៅក្នុង [ ]

N: 44. Lauren G. Robinson, "Rationales for Rural Land Redistribution in South Africa" [សនិទានភាពសម្រាប់ការបែងចែកដីនៅជនបទឡើងវិញនៅអាហ្វ្រិកខាងត្បូង], *Brooklyn Journal of International Law* 23 (1997): 478។

ចំណងជើងនៃជើនណលជាអក្សរទ្រេត

លេខជើនណល

កាលបរិច្ឆេទបោះពុម្ព-ផ្សាយជើនណល

ទំព័រយោងនៅបន្ទាប់ពីសញ្ញាចុចពីរ

T: (Robinson 1997, 478)

B: Robinson, Lauren G. "Rationales for Rural Land Redistribution in South Africa" [សនិទានភាពសម្រាប់ការបែងចែកដីនៅជនបទឡើងវិញនៅអាហ្វ្រិកខាងត្បូង], *Brooklyn Journal of International Law* 23 (1997): 465-504។

ប្រើរង្វង់ក្រចក ព្រោះដើម្បីកុំឲ្យច្រឡំនឹងលេខជើនណល

ទំព័រចាប់ផ្តើម និងទំព័របញ្ចប់របស់ប្រធានបទនៅបន្ទាប់ពីសញ្ញាចុចពីរ

R: Robinson, Lauren G. 1997. Rationales for Rural Land Redistributionin South Africa [សនិទានភាពសម្រាប់ការបែងចែកដីនៅជនបទឡើងវិញនៅអាហ្វ្រិកខាងត្បូង], *Brooklyn Journal of International Law* 23: 465-504។

ទំព័រចាប់ផ្តើម និងទំព័របញ្ចប់របស់ប្រធានបទ ខណ្ឌចែកលេខជើនណលដោយសញ្ញាចុចពីរ

## 6.24. កន្លែងបោះពុម្ពជើនណល

ប្រសិនបើជើនណលណា ដែលអាចនាំឲ្យមានការភាន់ច្រឡំជាមួយនឹងជើនណលផ្សេងទៀតដែលមានចំណងជើងដូចគ្នា ឬប្រសិនបើវាអាចនឹងមិនត្រូវបានគេស្គាល់ ត្រូវបន្ថែមឈ្មោះនៃកន្លែង ឬស្ថាប័នដែលជើនណលនោះត្រូវបានគេបោះពុម្ពនៅក្នុងរង្វង់ក្រចក បន្ទាប់ពីចំណងជើង។ ដូចគ្នានឹងចំណុចខាងលើនេះដែរ ខ្ញុំនឹងផ្តល់ជូនឧទាហរណ៍នៃជើនណលបរទេសដែលត្រូវការបញ្ជាក់កន្លែងបោះពុម្ពរបស់ជើនណល ដើម្បីកុំឲ្យមានការភាន់ច្រឡំនឹងជើនណលផ្សេងទៀត។

N: 45. Marvin P. Garrett, "Language and Design in *Pippa Passes*" [ភាសា និងការគូរប្លង់នៅ*ក្រុងភីប៉ាភែសស៊ីស*], *Victorian Poetry* (West Virginia University) 13, no. 1 (1975): 50។

T: (Garrett 1975, 50)

B: Garrett, Marvin P. "Language and Design in *Pippa Passes.*" [ភាសា និងការគូរប្លង់នៅ*ក្រុងភីប៉ាភែសស៊ីស*]. *Victorian Poetry* (West Virginia University) 13, no. 1 (1975): 47-60។

R: Garrett, Marvin P. 1975. Language and design in *Pippa Passes.* [ភាសា និងការគូរប្លង់នៅ*ក្រុងភីប៉ាភែសស៊ីស*] *Victorian poetry* (West Virginia University) 13. No. 1: 47-60។

ចំពោះជើនណលដែលបានចុះផ្សាយក្នុងប្រព័ន្ធអេឡិចត្រូនិក ត្រូវបញ្ជាក់ឈ្មោះគេហទំព័រ ឬឈ្មោះអេឡិចត្រូនិកផង។

N: 46. Bernard Testa និង Lamont B. Kier, "Emergence and Dissolvence in the Self-Organisation of Complex Systems" [ការលេចឡើង និងការរលាយបាត់នៅក្នុងការរៀបចំខ្លួនឯងនៃប្រព័ន្ធសាំញ៉ាំ], *Entropy* 2, no.1 (មីនា 2000)៖ 17, http://www.mdpi.org /entropy/papers/e20100001.pdf។

T: (Testa 2000, 17)

B: Testa, Bernard និង Lamont B. Kier. "Emergence and Dissolvence in the Self-Organisation of Complex Systems" [ការលេចឡើង និងការរលាយបាត់នៅក្នុងការរៀបចំខ្លួនឯងនៃប្រព័ន្ធសាំញ៉ាំ]. *Entropy* 2, no. 1 (មីនា 2000)៖ 1-25, http://www. mdpi.org/entropy/papers/e20100001.pdf។

R: Testa, Bernard និង Lamont B. Kier. 2000. Emergence and Dissolvence in the Self-Organisation of Complex Systems [ការលេចឡើង និងការរលាយបាត់នៅក្នុងការរៀបចំខ្លួនឯងនៃប្រព័ន្ធសាំញ៉ាំ]. *Entropy* 2, no. 1 (មីនា)៖ 1-25, http://www. mdpi.org /entropy/papers/e20100001.pdf។

### 6.25. ទស្សនាវដ្ដី (Magazines)

ការយោងទៅលើទស្សនាវដ្ដី ត្រូវដាក់ឈ្មោះអ្នកនិពន្ធ រួចចំណងជើងរបស់អត្ថបទនៅក្នុងអព្ភន្តរសញ្ញា រួចឈ្មោះរបស់ទស្សនាវដ្ដីជាអក្សរទ្រេត បន្ទាប់មកកាលបរិច្ឆេទបោះពុម្ពផ្សាយ និងទំព័រយោង។ ប្រសិនបើទស្សនាវដ្ដីដែលគេស្គាល់ទូលំទូលាយ ឬទស្សនាវដ្ដីដែលមានឈ្មោះ

ច្បាស់លាស់ មិនចាំបាច់ប្រើពាក្យទស្សនាវដ្ដីទេ។ ផ្ទុយទៅវិញ ប្រសិនបើទស្សនាវដ្ដីគេមិនសូវស្គាល់ ឬបើគ្មានពាក្យទស្សនាវដ្ដីពីមុខទេអាចនឹងធ្វើឲ្យមានការភាន់ច្រឡំ ត្រូវរក្សាទុកពាក្យទស្សនាវដ្ដី។

N: 47. គាំ ហេង, "នៅពេលដែលគេចាត់ទុកបឹងទន្លេសាបសំខាន់," *ប្រជាប្រិយ*, ឆ្នាំទី១៣ លេខ៤០០, ២១-៣១ តុលា ២០០៧, ១១-១២។




T: (គាំ ហេង ២០០៧, ១១-១២)

B: គាំ ហេង. "នៅពេលដែលគេចាត់ទុកបឹងទន្លេសាបសំខាន់." *ប្រជាប្រិយ*, ឆ្នាំទី១៣ លេខ៤០០, ២១-៣១ តុលា ២០០៧។

R: គាំ ហេង. ២០០៧. នៅពេលដែលគេចាត់ទុកបឹងទន្លេសាបសំខាន់. *ប្រជាប្រិយ*, ឆ្នាំទី១៣ លេខ៤០០, ២១-៣១ តុលា។

ប្រសិនបើពាក្យ "ទស្សនាវដ្ដី" ចាំបាច់សម្រាប់បន្ថែមទៅលើឈ្មោះរបស់វាដើម្បីឲ្យអ្នកអានដឹងច្បាស់ថាវាជាទស្សនាវដ្ដី យើងអាចសរសេរពាក្យ "ទស្សនាវដ្ដី" នៅពីមុខឈ្មោះរបស់វាបាន។

ចំពោះការយោងទៅលើទស្សនាវដ្ដីតាមគេហទំព័រ ត្រូវដាក់ឈ្មោះអាសយដ្ឋានរបស់គេហទំព័រនោះផង។

N: 48. *ទស្សនាវដ្ដីអង្គរធំ*, "ស្ត្រី២នាក់ដូរប្ដីគ្នា,"http://www.angkorthommagazine.com/index.php?page=economy_society_life) (ទស្សនាចុងក្រោយ ១៨ វិច្ឆិកា ២០១០)។

6.26. កាសែត (Newspapers)

ការយោងទៅលើកាសែត ត្រូវសរសេរឈ្មោះរបស់អ្នកនិពន្ធ (ប្រសិនបើស្គាល់) និងចំណងជើងអត្ថបទនៅក្នុងអព្ភន្តរសញ្ញា បន្ទាប់មកចំណងជើងកាសែតជាអក្សរទ្រេត និងបញ្ចប់ដោយកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ។ ប្រសិនបើកាសែតមានបញ្ជាក់លេខ ឆ្នាំ ឬផ្នែក ត្រូវដាក់លេខ ឆ្នាំ ឬផ្នែករបស់វា នៅពីមុខកាលបរិច្ឆេទ រួចបញ្ជាក់លេខទំព័រ។

ជាទូទៅ ការយោងទៅលើកាសែតច្រើនតែសរសេរចូលនៅក្នុងសម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទ ឬសម្គាល់ក្នុងអត្ថបទតែប៉ុណ្ណោះ។

N: 49. ម៉េងឆៃ, "អ្នកជំនាញព្រំដែនមិនអនុញ្ញាតឲ្យមានការចូលពិនិត្យកន្លែងបោះបង្គោលព្រំដែនទេ," *រស្មីកម្ពុជា*, ឆ្នាំទី១៨ លេខ៥៣៤៧, ១០ វិច្ឆិកា ២០១០, ទំព័រក១-២។

T: (ម៉េងឆៃ ២០១០)

នៅក្នុងសម្គាល់ក្នុងអត្ថបទ ប្រសិនបើការយោងមានច្រើនចំពោះអ្នកនិពន្ធតែមួយដែលមានកាលបរិច្ឆេទបោះពុម្ពផ្សេងពីគ្នា ត្រូវសរសេរ ថ្ងៃ ខែ ឆ្នាំ នៃការបោះពុម្ពផ្សាយនោះ។

T: (ម៉េងឆៃ ១០ វិច្ឆិកា ២០១០)
(ម៉េងឆៃ ១៩ វិច្ឆិកា ២០១០)

ប្រសិនបើក្នុងហេតុផលណាមួយ ការយោងកាសែតត្រូវការសរសេរចូលនៅក្នុងគន្ថនិទ្ទេស និងឯកសារយោង គេត្រូវសរសេរដូចខាងក្រោម៖

B: ម៉េងឆៃ. "អ្នកជំនាញព្រំដែនមិនអនុញ្ញាតឲ្យមានការចូលពិនិត្យកន្លែងបោះបង្គោលព្រំដែនទេ." *រស្មីកម្ពុជា*, ឆ្នាំទី១៨ លេខ៥៣៤៧, ១០ វិច្ឆិកា ២០១០។

R: ម៉េងឆៃ.២០១០. អ្នកជំនាញព្រំដែនមិនអនុញ្ញាតឲ្យមានការចូលពិនិត្យកន្លែងបោះបង្គោលព្រំដែនទេ. *រស្មីកម្ពុជា*, ឆ្នាំទី១៨ លេខ ៥៣៤៧, ១០ វិច្ឆិកា។

ប៉ុន្តែ ក្នុងករណីមិនមានឈ្មោះអ្នកនិពន្ធ ត្រូវសរសេរតែឈ្មោះកាសែត និងឆ្នាំនៅក្នុងសម្គាល់ក្នុងអត្ថបទ។

N: 50. *រស្មីកម្ពុជា*, "ភ្នំភ្លើង Merapi បង្កើតបានជាពិភពប្រផេះ," ឆ្នាំទី ១៨ លេខ៥៣៤៧, ១០ វិច្ឆិកា ២០១០, ទំព័រគ១។

T: (រស្មីកម្ពុជា ២០១០)

B: *រស្មីកម្ពុជា*. "ភ្នំភ្លើងMerapi បង្កើតបានជាពិភពប្រផេះ." ឆ្នាំទី១៨ លេខ ៥៣៤៧, ១០ វិច្ឆិកា ២០១០។

R: *រស្មីកម្ពុជា*. ២០១០. ភ្នំភ្លើង Merapi បង្កើតបានជាពិភពប្រផេះ. ឆ្នាំទី ១៨ លេខ៥៣៤៧, ១០ វិច្ឆិកា។

ក្នុងករណីដែលដកស្រង់ពីកាសែតតាមរយៈគេហទំព័រ ត្រូវបញ្ជាក់ឈ្មោះគេហទំព័រនោះផង។

N: 51. កោះឯករាជ្យ, "សោកនាដកម្មផ្ទុះមីនតោន កសិករជិះគោយន្ត ១៤នាក់ស្លាប់ទាំងអស់," *កោះសន្តិភាព*, ១៨ វិច្ឆិកា ២០១០, http://kohsantepheapdaily.com.kh/article/20101117-190753.html (បានចូលមើលចុងក្រោយ ១៨ វិច្ឆិកា ២០១០)។

T: (កោះឯករាជ្យ ២០១០)

B: កោះឯករាជ្យ. "សោកនាដកម្មផ្ទុះមីនតោន កសិករជិះគោយន្ត១៤នាក់

ស្លាប់ទាំងអស់." *កោះសន្តិភាព*, ១៨ វិច្ឆិកា ២០១០, http://kohsantepheapdaily.com.kh/article/20101117-190753.html (បានចូលមើលចុងក្រោយ ១៨ វិច្ឆិកា ២០១០)។

R: កោះឯករាជ្យ. ២០១០. សោកនាដកម្មផ្ទុះមីនតោន កសិករជិះគោយន្ត ១៨នាក់ស្លាប់ទាំងអស់. *កោះសន្តិភាព*, ១៨ វិច្ឆិកា, http://kohsantepheapdaily.com.kh/article/20101117-190753.html (បានចូលមើលចុងក្រោយ ១៨ វិច្ឆិកា ២០១០)។

*** ព្រឹត្តិបត្រ

ចំពោះការផ្តល់ប្រភពទាក់ទងនឹងព្រឹត្តិបត្រគឺដូចគ្នានឹងជើនណាល ឬ ទស្សនាវដ្តីដែរ ពោលគឺចំណងជើងអត្ថបទ ជាអក្សរត្រង់នៅក្នុងរង្វង់ក្រចក ឈ្មោះព្រឹត្តិបត្រ ជាអក្សរទ្រេត រួចព័ត៌មានទាក់ទងនឹងលេខរបស់ព្រឹត្តិបត្រ។






N: 51. ធនាគារជាតិនៃកម្ពុជា, *ព្រឹត្តិបត្រប្រចាំត្រីមាស*, លេខ១២ (២០០៥), ៥០។

T: (ធនាគារជាតិនៃកម្ពុជា ២០០៥)

B: ធនាគារជាតិនៃកម្ពុជា. *ព្រឹត្តិបត្រប្រចាំត្រីមាស*, លេខ១២ (២០០៥)។

R: ធនាគារជាតិនៃកម្ពុជា. ២០០៥. *ព្រឹត្តិបត្រប្រចាំត្រីមាស*, លេខ១២។

## 7. បទសម្ភាស និងទំនាក់ទំនងផ្ទាល់ខ្លួន

នៅក្នុងទម្រង់បែបណាក៏ដោយ ចំពោះបទសម្ភាស ឬទំនាក់ទំនងផ្ទាល់ខ្លួន ឈ្មោះរបស់អ្នកដែលត្រូវគេសម្ភាស ឬគេសួរត្រូវសរសេរមុនគេ ហើយឈ្មោះរបស់អ្នកសម្ភាសគេត្រូវសរសេរបន្ទាប់។

### 7.27. បទសម្ភាសផ្លូវការ

#### បទសម្ភាសដែលមិនបានបោះពុម្ពផ្សាយ

ជាទូទៅ ចំពោះបទសម្ភាសដែលមិនបានបោះពុម្ពផ្សាយ គេត្រូវសរសេរនៅក្នុងសម្គាល់ក្រោមទំព័រ សម្គាល់ចុងអត្ថបទ ឬសម្គាល់ក្នុងអត្ថបទដោយកម្រនឹងប្រើវានៅក្នុងគន្ថនិទ្ទេស ឬក្នុងឯកសារយោង។ ការផ្តល់ប្រភពឯកសារគួររាប់បញ្ចូលឈ្មោះអ្នកដែលគេសម្ភាស ឈ្មោះអ្នកសម្ភាសគេ ព័ត៌មានបញ្ជាក់ខ្លីៗប្រសិនបើអាច កន្លែង ឬ/និងកាលបរិច្ឆេទនៃបទសម្ភាស និងសំណៅឯកសារ ឬកាសែតសំឡេង បើមាន។ ក្នុងករណីចាំបាច់ ត្រូវសុំការអនុញ្ញាតដកស្រង់សំដីពីអ្នកត្រូវគេសម្ភាស។

N: 52. កង ចាន់ (ប្រធាននាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា), បទសម្ភាសដោយ កែវ សំណាង, ១៨ វិច្ឆិកា ២០០០។

53. ទូច រចនា, បទសម្ភាសដោយ ចក់ ជំនោរ, ខេត្តប៉ៃលិន, ២៣ ធ្នូ ២០០៩។

54. កង ចាន់ (ប្រធាននាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា), បទសម្ភាសផ្ទាល់ខ្លួន (ខ្សែអាត់ថតសំឡេងនៅជាមួយអ្នកនិពន្ធ)។

T: (កង ចាន់, បទសម្ភាសដោយ កែវ សំណាង)
(ទូច រចនា, បទសម្ភាសដោយ ចក់ ជំនោរ)
(កង ចាន់, បទសម្ភាសផ្ទាល់ខ្លួន)

#### បទសម្ភាសដែលមិនបង្ហាញឈ្មោះអ្នកត្រូវគេសម្ភាស

ក្នុងបទសម្ភាសជាមួយនឹងអ្នកដែលចង់មិនឲ្យគេបញ្ចេញឈ្មោះ ឬអ្នកដែលអ្នកនិពន្ធមិនចង់បង្ហាញឈ្មោះ អាចត្រូវបានសរសេរតាមទម្រង់អ្វីក៏បាន។ អវត្តមាននៃឈ្មោះអាចត្រូវបញ្ជាក់ដូចជា "គ្រប់បទសម្ភាសត្រូវ

បានធ្វើឡើងដោយសម្ងាត់" ឬ "អ្នកនិពន្ធសុំមិនបញ្ចេញឈ្មោះអ្នកត្រូវគេសម្ភាស" ជាដើម។

N: 55. បទសម្ភាសជាមួយនឹងបុគ្គលិកអង្គការស្តារកម្ពុជា, ១២ តុលា ២០០៩។

N: 56. បទសម្ភាសផ្ទាល់ខ្លួនជាមួយនឹងបុគ្គលិកសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (បទសម្ភាសត្រូវបានធ្វើឡើងដោយសម្ងាត់), ១២ តុលា ២០០៩។

**បទសម្ភាសដែលបានបោះពុម្ពផ្សាយ ឬផ្សាយតាមវិទ្យុ ទូរទស្សន៍**

ចំពោះបទសម្ភាសដែលត្រូវបានគេបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ត្រូវចាត់ទុកជាប្រធានបទនៅក្នុងទស្សនាវដ្ដី ឬជំពូកនៅក្នុងសៀវភៅ។

N: 57. គឹម រតនា, បទសម្ភាសដោយ រស់ សារុន, *ទូរទស្សន៍ជាតិកម្ពុជា,* ២០ កញ្ញា ២០០៩។

T: (គឹម រតនា, បទសម្ភាស)

B: គឹម រតនា. បទសម្ភាសដោយ រស់ សារុន. *ទូរទស្សន៍ជាតិកម្ពុជា.* ២០ កញ្ញា ២០០៩។

R: គឹម រតនា. ២០០៩. បទសម្ភាសដោយ រស់ សារុន. *ទូរទស្សន៍ជាតិកម្ពុជា.* ២០ កញ្ញា។

**8. ឯកសារមិនបានបោះពុម្ពផ្សាយ និងបានបោះពុម្ពផ្សាយមិនផ្លូវការ**

**8.28. ចំណាងជើង**

ចំណាងជើងនៃស្នាដៃដែលមិនបានបោះពុម្ពផ្សាយ ទោះបីជាសៀវភៅ និក្ខេបបទ សន្ទរកថា ឬក៏អ្វីក៏ដោយមិនត្រូវសរសេរជាអក្សរទ្រេតទេ។ នៅក្នុងសម្គាល់ ឬគន្ថនិទ្ទេស ត្រូវសរសេរចំណងជើងនោះនៅក្នុងអព្តន្តរសញ្ញា ប៉ុន្តែ នៅក្នុងឯកសារយោង មិនចាំបាច់ដាក់នៅក្នុងអព្តន្តរសញ្ញាឡើយ។ ចូរកត់សម្គាល់ថា ទាំងនៅក្នុងសម្គាល់ គន្ថនិទ្ទេស និងឯកសារយោង ចំណាងជើងនៃស្នាដៃមិនបានបោះពុម្ពផ្សាយ ឬបោះពុម្ពផ្សាយមិនផ្លូវការ ត្រូវសរសេរជាអក្សរត្រង់។

N: 58. ជា មាលា, "សំណាបយោងដី" (ឯកសារថតចម្លង, ២០១០), ២៣។

59. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, "ព័ត៌មានស្តីពីគ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់" (បោះពុម្ពចេញពីកុំព្យូទ័រ, ថ្នាក់ក្រោយបរិញ្ញាបត្រ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១០), ៦។

B: ជា មាលា. "សំណាបយោងដី." ឯកសារថតចម្លង, ២០១០។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច."ព័ត៌-មានស្តីពីគ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់." បោះពុម្ពចេញពីកុំព្យូទ័រ, ថ្នាក់ក្រោយបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១០។

R: ជា មាលា. ២០១០. សំណាបយោងដី. ឯកសារថតចម្លង។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ២០១០. ព័ត៌មានស្តីពីគ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់. បោះពុម្ពចេញពីកុំព្យូទ័រ, ថ្នាក់ក្រោយបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**8.29. និក្ខេបបទ**

ការយោងទៅលើនិក្ខេបបទ ត្រូវសរសេរប្រភេទនៃនិក្ខេបបទថាតើជានិក្ខេបបទថ្នាក់អនុបណ្ឌិត ឬនិក្ខេបបទថ្នាក់បណ្ឌិត ស្ថាប័នសិក្សា និងកាលបរិច្ឆេទនៅពីក្រោយចំណងជើងនៃនិក្ខេបបទ។

N: 60. លឹម ហុង, "ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា," (និក្ខេបបទអនុបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុវិជ្ជា, ២០០៩), ១៣៤-១៣៥។

T: (លឹម ហុង ២០០៩, ១៣៤-១៣៥)

B: លឹម ហុង. "ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា." និក្ខេបបទអនុបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុវិជ្ជា, ២០០៩។

R: លឹម ហុង. ២០០៩. ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា. និក្ខេបបទអនុបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុវិជ្ជា។

ក្នុងករណីគ្មានកាលបរិច្ឆេទ ត្រង់កន្លែងឆ្នាំផលិត ត្រូវដាក់ថា "គ្មានកាលបរិច្ឆេទ"។

N: 61. ឡេង សាយ៉េង, "ការចុះបញ្ជីដីធ្លីនៅកម្ពុជា" (និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុវិជ្ជា, គ្មានកាលបរិច្ឆេទ), ១៣៩។

T: (ឡេង សាយ៉េង គ្មានកាលបរិច្ឆេទ,១៣៩)

B: ឡេង សាយ៉េង. "ការចុះបញ្ជីដីធ្លីនៅកម្ពុជា." និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុវិជ្ជា, គ្មានកាលបរិច្ឆេទ។

R: ឡេង សាយ៉េង. គ្មានកាលបរិច្ឆេទ. ការចុះបញ្ជីដីធ្លីនៅកម្ពុជា. និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុវិជ្ជា។

**8.30. មេរៀន ឯកសារធ្វើបទបង្ហាញ និងឯកសារដូចផ្សេងទៀត**

ចំពោះការយោងទៅលើមេរៀន ឯកសារធ្វើបទបង្ហាញ និងឯកសារដូច ផ្សេងទៀត ត្រូវដាក់ប្រភេទឯកសារ ទីកន្លែង និងកាលបរិច្ឆេទនៃការបង្រៀន ឬការធ្វើបទបង្ហាញបន្ទាប់ពីចំណងជើងរបស់វា។ ចំណងជើងត្រូវដាក់នៅក្នុងអព្ភន្តរសញ្ញា ចំពោះសម្គាល់ និងគន្ថនិទ្ទេស តែមិនត្រូវដាក់អព្ភន្តរសញ្ញាទេ ចំពោះឯកសារយោង។

**មេរៀនចងក្រងសម្រាប់បង្រៀននិស្សិត**




N: 62. ជួន ស៊ុនឡេង, "នីតិរដ្ឋប្បវេណី" (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រ ឆ្នាំទី២, មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១៩៩៩-២០០០), ៦៨។

T: (ជួន ស៊ុនឡេង ១៩៩៩-២០០០, ៦៨)

B: ជួន ស៊ុនឡេង. "នីតិរដ្ឋប្បវេណី." មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី ២, មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១៩៩៩-២០០០។

R: ជួន ស៊ុនឡេង. ១៩៩៩-២០០០. "នីតិរដ្ឋប្បវេណី." មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### ឯកសារធ្វើបទបង្ហាញ

N: 63. ជួង ជា, "ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ" (បទបង្ហាញនៅក្នុងសន្និសីទជាតិ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១០ ឧសភា ២០១០)។

T: (ជួង ជា ២០១០)

B: ជួង ជា. "ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ." បទបង្ហាញនៅក្នុងសន្និសីទជាតិ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១០ ឧសភា ២០១០។

R: ជួង ជា. ២០១០. ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ. បទបង្ហាញនៅក្នុងសន្និសីទជាតិ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១០ ឧសភា។

### កិច្ចប្រជុំ

N: 64. ជា មុនីរ័ត្ន, "សេដ្ឋកិច្ចជាតិខ្មែរឆ្នាំ២០១០" (ឯកសារបង្ហាញនៅ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ, សណ្ឋាគារភ្នំពេញ, ១៤ ឧសភា ២០០៩)។

T: (ជា មុនីរ័ត្ន ២០០៩)

B: ជា មុនីរ័ត្ន. "សេដ្ឋកិច្ចជាតិខ្មែរឆ្នាំ២០១០." ឯកសារបង្ហាញនៅ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ, សណ្ឋាគារភ្នំពេញ, ១៤ ឧសភា ២០០៩។

R: ជា មុនីរ័ត្ន. ២០០៩. សេដ្ឋកិច្ចជាតិខ្មែរឆ្នាំ២០១០. ឯកសារបង្ហាញនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ, សណ្ឋាគារភ្នំពេញ, ១៥ ឧសភា។

**ឯកសារពិភាក្សា (Working Papers) និងឯកសារមិនបានបោះពុម្ពផ្សាយផ្សេងទៀត**

**ឯកសារពិភាក្សា**

នៅកម្ពុជា ឯកសារពិភាក្សាត្រូវបានបោះពុម្ពដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាដែលមានអាសយដ្ឋាន #៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ចំណងជើងរបស់ឯកសារពិភាក្សាត្រូវសរសេរជាអក្សរត្រង់។ នៅក្នុងសម្គាល់ និងគន្ថនិទ្ទេស ត្រូវដាក់ចំណងជើងឯកសារពិភាក្សាក្នុងអព្ភន្តរសញ្ញា ប៉ុន្តែក្នុងឯកសារយោង មិនចាំបាច់ដាក់ក្នុងអព្ភន្តរសញ្ញាទេ។






N: 65. ព្រុំ តុលា និងBruce McKenney, "ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសល្អសំរាប់ជ័រទឹកនៅកម្ពុជា," (ឯកសារពិភាក្សាលេខ២៨, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ, ខែធ្នូ ២០០៣), ១៥។



T: (ព្រុំ តុលា និងBruce McKenney ២០០៣, ១៥)

B: ព្រុំ តុលា និងBruce McKenney. "ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសល្អសំរាប់ជ័រទឹកនៅកម្ពុជា." ឯកសារពិភាក្សាលេខ២៨, វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ, ខែធ្នូ ២០០៣។

R: ព្រុំ តុលា និងBruce McKenney. ២០០៣. ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសល្អសំរាប់ជ័រទឹកនៅកម្ពុជា. ឯកសារពិភាក្សាលេខ២៨, វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ, ខែធ្នូ។

## ឯកសារមិនបានបោះពុម្ពផ្សាយ

ចំណាងជើងឯកសារមិនបានបោះពុម្ពផ្សាយ ត្រូវសរសេរដូចគ្នានឹងចំណាងជើងរបស់ឯកសារពិភាក្សាដែរ។ ប្រសិនបើឯកសារនោះជាឯកសារថតចម្លង ឬបោះពុម្ពចេញពីកុំព្យូទ័រ ត្រូវបញ្ជាក់នៅក្នុងសញ្ញាវង្ងង់ក្រចកផង។ (សូមមើល8.28 សម្រាប់ព័ត៌មានបន្ថែម)។

N: 66. ណុំ វណ្ណា, "អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ" (ឯកសារថតចម្លង, ២០១១), ១៣៩។

T: (ណុំ វណ្ណា ២០១១, ១៣៩)

B: ណុំ វណ្ណា. "អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ." ឯកសារថតចម្លង, ២០១១។

R: ណុំ វណ្ណា. ២០១១. អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ. ឯកសារថតចម្លង។

N: 67. ជា ពិសេដ្ឋ, "អំណាចប្រជាជន និងអំណាចរដ្ឋ" (បោះពុម្ពចេញពីកុំព្យូទ័រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០១), ២៩៣។

បើដឹងកន្លែងបោះពុម្ពចេញពីកុំព្យូទ័រ យើងអាចបញ្ជាក់វាបាន

T: (ជា ពិសេដ្ឋ ២០០១, ២៩៣)

B: ជា ពិសេដ្ឋ. "អំណាចប្រជាជន និងអំណាចរដ្ឋ." បោះពុម្ពចេញពីកុំព្យូទ័រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០១។

R: ជា ពិសេដ្ឋ. ២០០១. អំណាចប្រជាជន និងអំណាចរដ្ឋ. បោះពុម្ពចេញពីកុំព្យូទ័រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### *9. របាយការណ៍ និងលិខិតបោះពុម្ពផ្សាយផ្សេងៗ*

របាយការណ៍ និងលិខិតបោះពុម្ពផ្សាយផ្សេងៗ ត្រូវបានចាត់ទុកសំខាន់ដូចជាសៀវភៅដែរ។ ទិន្នន័យចំពោះអ្នកនិពន្ធ និងរោងពុម្ពអាចនឹងមិនដូចក្នុងករណីសៀវភៅទេ ប៉ុន្តែព័ត៌មានគ្រប់គ្រាន់ផ្សេងទៀតអាចនឹងត្រូវផ្តល់ដើម្បីបញ្ជាក់ប្រភេទឯកសារ។

N: 68. កែប ជុតិមា, *របាយការណ៍ស្តីពីការងាររៀបចំ និងអភិវឌ្ឍន៍សហគមន៍*, លេខ៦០៩របក/ក្រ (ភ្នំពេញ៖ សាលាក្រុងភ្នំពេញ, ០៨ សីហា ២០០៦), ៦។

T: (កែប ជុតិមា ២០០៦, ៦)

B: គែប ជុតិមា. *របាយការណ៍ស្តីពីការងាររៀបចំ និងអភិវឌ្ឍន៍សហគមន៍.* លេខ៦០៩របក/ក្រ. ភ្នំពេញ៖ សាលាក្រុងភ្នំពេញ, ០៨ សីហា ២០០៦។

R: គែប ជុតិមា. ២០០៦. *របាយការណ៍ស្តីពីការងាររៀបចំ និងអភិវឌ្ឍន៍សហគមន៍.* លេខ៦០៩របក/ក្រ. ភ្នំពេញ៖ សាលាក្រុងភ្នំពេញ, ០៨ សីហា។

N: 69. ស្វាយ ស៊ីថា, *របាយការណ៍ឆមាសទី១ឆ្នាំ២០០៧ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី,* លេខ១៩៨/០៧/រប/អជដ (ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ២៤ សីហា ២០០៧), ២។

T: (ស្វាយ ស៊ីថា ២០០៧, ២)

B: ស្វាយ ស៊ីថា. *របាយការណ៍ឆមាសទី១ឆ្នាំ២០០៧ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី.* លេខ១៩៨/០៧/រប/អជដ. ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ២៤ សីហា២០០៧។

R: ស្វាយ ស៊ីថា. ២០០៧. *របាយការណ៍ឆមាសទី១ឆ្នាំ២០០៧ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី,* លេខ១៩៨/០៧/រប/អជដ. ភ្នំពេញ៖ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ២៤ សីហា។

N: 70. ធនាគារពិភពលោក, *Making Services Work for Poor People: Overview* [បង្កើតសេវាឲ្យដំណើរការសម្រាប់អ្នកក្រះទិដ្ឋភាពទូទៅ], World Develpment Report 2004 (Washington D.C.: World Bank, 2003), 9។

T: (ធនាគារពិភពលោក ២០០៣, ៩)

B: ធនាគារពិភពលោក. *Making Services Work for Poor People:*

*Overview* [បង្កើតសេវាឲ្យដំណើរការសម្រាប់អ្នកក្រ៖ ទិដ្ឋភាពទូទៅ]. World Develpment Report 2004. Washington D.C.: World Bank, 2003។

R: ធនាគារពិភពលោក. 2003. *Making Services Work for Poor People: Overview* [បង្កើតសេវាឲ្យដំណើរការសម្រាប់អ្នកក្រ៖ ទិដ្ឋភាពទូទៅ]. World Develpment Report 2004. Washington D.C.: World Bank។

## 10. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### 10.31. ច្បាប់/ព្រះរាជក្រម

ការយោងចំពោះច្បាប់ខ្មែរ ត្រូវសរសេរឈ្មោះច្បាប់ រួចលេខរបស់វា និងកាលបរិច្ឆេទប្រកាសឲ្យប្រើ។ ប្រសិនបើឈ្មោះច្បាប់វែងពេក គេអាចដាក់ឈ្មោះវាកាត់ខ្លី (តាមការយល់ឃើញរបស់អ្នកនិពន្ធ) រួចហើយអាចប្រើឈ្មោះដែលសរសេរកាត់នោះនៅសម្គាល់ក្រោយៗទៀត (សូមមើលចំណុច 11.1 ខាងក្រោមបន្ថែម)។

គួរកត់សម្គាល់ថា នៅក្នុងគន្ថនិទ្ទេស និងឯកសារយោងមិនមានអ្វីខុសប្លែកគ្នាទេ ចំពោះការយោងទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

N: 71. ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៥។

មាត្រាយោង | លេខច្បាប់ភូមិបាល | កាលបរិច្ឆេទប្រកាសឲ្យប្រើច្បាប់ភូមិបាល

T: (ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៥)

B,R: ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

N: 72. ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៩៧-៥៥៣។

កាលបរិច្ឆេទប្រកាសឲ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី

មាត្រាយោងពីមាត្រា ៤៩៧ដល់៥៥៣

លេខក្រម

T: (ក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា៤៩៧-៥៥៣)

B,R: ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

**10.32. ព្រះរាជក្រឹត្យ**

ដូចគ្នានឹងច្បាប់ដែរ ត្រូវសរសេរឈ្មោះព្រះរាជក្រឹត្យ (បើមាន) រួចលេខរបស់វា និងកាលបរិច្ឆេទប្រកាសឲ្យប្រើ។

ឧទាហរណ៍នៃព្រះរាជក្រឹត្យមានលេខ

N: 73. ព្រះរាជក្រឹត្យលេខ នស/រតត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦, មាត្រា៣។

កាលបរិច្ឆេទព្រះមហាក្សត្រឡាយព្រះហស្ថលេខា

T: (ព្រះរាជក្រឹត្យលេខ នស/រតត/០២០៦/០៩៧, មាត្រា៣)

B,R: ព្រះរាជក្រឹត្យលេខ នស/រតត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦។

ឧទាហរណ៍នៃព្រះរាជក្រឹត្យគ្មានលេខ

ប្រសិនបើព្រះរាជក្រឹត្យគ្មានលេខត្រូវសរសេរពាក្យ "គ្មានលេខ" នៅពីក្រោយព្រះរាជក្រឹត្យ។

N: 74. ព្រះរាជក្រឹត្យគ្មានលេខ, ០១ វិច្ឆិកា ១៩៩៣, មាត្រា២។

ព្រះរាជក្រឹត្យនេះមានគោលបំណងបង្កើតតំបន់ការពារធម្មជាតិ ដូច្នេះនៅក្នុងសម្គាល់ក្នុងអត្ថបទគេអាចប្រើពាក្យ "ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិឆ្នាំ១៩៩៣" ក៏បាន។

T: (ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិឆ្នាំ១៩៩៣, មាត្រា២)
ឬ
(ព្រះរាជក្រឹត្យគ្មានលេខ, មាត្រា២)

B,R: ព្រះរាជក្រឹត្យគ្មានលេខ, ០១ វិច្ឆិកា ១៩៩៣។

ឧទាហរណ៍នៃព្រះរាជក្រឹត្យមានឈ្មោះ ឬចំណងជើង

N: 75. ព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា, លេខ នស/រកត/០៣០៣/១២៩, ៣១ មីនា ២០០៣, មាត្រា៩។



T: (ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩, មាត្រា៩)

ឬ

(ព្រះរាជក្រឹត្យលេខ១២៩ ឆ្នាំ២០០៣, មាត្រា៩)

B,R: រាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា, លេខ នស/រកត/០៣០៣/១២៩, ៣១ មីនា ២០០៣។

### 10.33. អនុក្រឹត្យ

ដូចគ្នានឹងការយោងចំពោះច្បាប់ដែរ ត្រូវសរសេរចំណងជើងអនុក្រឹត្យ រួចលេខរបស់វា និងកាលបរិច្ឆេទប្រកាសឲ្យប្រើអនុក្រឹត្យនោះ។ ដើម្បីងាយស្រួលក្នុងការផ្តាច់ចេញពីគ្នារវាងអក្សរកាត់ "អនក្រ" និង "បក" ដែល ជាទូទៅគេប្រើសញ្ញាចុចមួយដូចជា "អនក្រ.បក" ដោយឡែក ឯកសារនេះប្រើសញ្ញា "/" ជំនួសវិញ ដូចជា "អនក្រ/បក"។ ដូចគ្នានេះដែរចំពោះលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតក៏ប្រើសញ្ញា "/" ដែរ។

ឈ្មោះអនុក្រឹត្យ

N: 76. អនុក្រឹត្យស្តីពីការដាក់បញ្ញាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា១០។

កាលបរិច្ឆេទដែលនាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើអនុក្រឹត្យ

មាត្រាយោង

លេខអនុក្រឹត្យ

T: (អនុក្រឹត្យលេខ១១៤អនក្រ/បក, មាត្រា១០)

B,R: អនុក្រឹត្យស្តីពីការដាក់បញ្ជាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/បក, ២៩ សីហា ២០០៧។

N: 77. អនុក្រឹត្យស្តីពីការតែងតាំងសមាសភាពគណៈកម្មការសម្ប-ទានដីសង្គមកិច្ចថ្នាក់ជាតិ, លេខ៣៤អនក្រ/បក, ១២ ឧសភា ២០០៣។

T: (អនុក្រឹត្យលេខ៣៤អនក្រ/បក ឆ្នាំ២០០៣)

B,R: អនុក្រឹត្យស្តីពីការតែងតាំងសមាសភាពគណៈកម្មការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ, លេខ៣៤អនក្រ/បក, ១២ ឧសភា ២០០៣។

N: 78. អនុក្រឹត្យស្តីពីការតែងតាំងសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, លេខ១៦៨អនក្រ/តត, ១៤ មីនា ២០០៦។

T: (អនុក្រឹត្យលេខ១៦៨អនក្រ/តត)

បើមានអនុក្រឹត្យដូចគ្នា តែឆ្នាំខុសគ្នាត្រូវបញ្ជាក់ឆ្នាំផង ដូចជា (អនុក្រឹត្យលេខ១៦៨អនក្រ/តត ឆ្នាំ២០០៦)

B,R: អនុក្រឹត្យស្តីពីការតែងតាំងសមាសភាពរបស់អាជ្ញាធរជាតិដោះ-ស្រាយទំនាស់ដីធ្លី, លេខ១៦៨អនក្រ/តត, ១៤ មីនា ២០០៦។

**10.33. ប្រកាស សារាចរ សេចក្តីណែនាំ សេចក្តីសម្រេច និងបទបញ្ជា**

ចំពោះការយោងទៅលើប្រកាស សារាចរ សេចក្តីណែនាំ សេចក្តីសម្រេច បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ត្រូវសរសេរឈ្មោះរបស់វា បន្ទាប់មកលេខ រួចបញ្ចប់ដោយកាលបរិច្ឆេទចុះហត្ថលេខាប្រកាសឲ្យប្រើ។

**ប្រកាស**

N: 79. ប្រកាសស្តីពីគោលការណ៍ណែនាំអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ២០០ជនស/ប្រក, ១៩ វិច្ឆិកា ២០០៣, ប្រការ៣។

T: (ប្រកាសលេខ២០០ជនស/ប្រក, ប្រការ៣) ឬ

(ប្រកាសលេខ២០០ជនស/ប្រក ឆ្នាំ២០០៣, ប្រការ៣)

B,R: ប្រកាសស្តីពីគោលការណ៍ណែនាំអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ២០០ជនស/ប្រក, ១៩ វិច្ឆិកា ២០០៣។

N: 80. ប្រកាសអន្តរក្រសួងស្តីពីសោហ៊ុយសេវាសំណង់, លេខ០៣៣សហវ/ប្រក, ១២ មករា ២០០៦, ប្រការ២។

T: (ប្រកាសអន្តរក្រសួងលេខ០៣៣សហវ/ប្រក, ប្រការ២) ឬ

(ប្រកាសអន្តរក្រសួងលេខ០៣៣សហវ/ប្រកឆ្នាំ២០០៦, ប្រការ២)

B,R: ប្រកាសអន្តរក្រសួងស្តីពីសោហ៊ុយសេវាសំណង់, លេខ០៣៣ សហវ/ប្រក, ១២ មករា ២០០៦។

**សារាចរ**

N: 81. សារាចរណែនាំស្តីពីការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ, លេខ០១ជនស/អកគដ/សរណន, ២១ កញ្ញា២០០៥។

T: (សារាចរណែនាំលេខ០១ជនស/អកគដ/សរណន)

B,R: សារាចរណែនាំស្តីពីការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ, លេខ០១ជនស/អកគដ/សរណន, ២១ កញ្ញា២០០៥។

**សេចក្ដីណែនាំ**

N: 82. សេចក្ដីណែនាំស្ដីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ, លេខ០០១សណន, ០៩ មករា ២០០៧។

T: (សេចក្ដីណែនាំលេខ០០១សណន)

B,R: សេចក្ដីណែនាំស្ដីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ, លេខ០០១សណន, ០៩ មករា ២០០៧។

**សេចក្ដីសម្រេច**

N: 83. សេចក្ដីសម្រេចស្ដីពីការបង្កើតប្រព័ន្ធទទួលពាក្យបណ្ដឹងសម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី, លេខ៤២សសរ, ២៣ តុលា ២០០៦។

T: (សេចក្ដីសម្រេចលេខ៤២សសរ)

B,R: សេចក្ដីសម្រេចស្ដីពីការបង្កើតប្រព័ន្ធទទួលពាក្យបណ្ដឹងសម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី, លេខ៤២សសរ, ២៣ តុលា ២០០៦។

**បទបញ្ជា**

N: 84. បទបញ្ជាស្ដីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, លេខ០២បប, ១៣ មិថុនា ២០០៥។

T: (បទបញ្ជាលេខ០២បប)

B,R: បទបញ្ជាស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, លេខ០២បប, ១៣ មិថុនា ២០០៥។

**10.34. លិខិតគតិយុត្ត**

ចំពោះការយោងទៅលើលិខិតគតិយុត្តត្រូវសរសេរពាក្យ "លិខិតរបស់" រួចឈ្មោះម្ចាស់របស់លិខិត (អាចជាឈ្មោះស្ថាប័ន ឬរូបវន្តបុគ្គល) បន្ទាប់មកប្រើពាក្យ "ស្តីពី" រួចកម្មវត្ថុរបស់លិខិតនោះ។ បើលិខិតមានលេខត្រូវដាក់លេខលិខិតនោះ និងកាលបរិច្ឆេទរបស់វា។

N: 85. លិខិតរបស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តសាលក្រម ឬសាលដីកាស្តាពរពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ, លេខ៣៣០កយ/រប, ០៣ មីនា ២០០៦។

T: (លិខិតលេខ៣៣០កយ/រប)

B,R: លិខិតរបស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តសាលក្រម ឬសាលដីកាស្តាពរពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ, លេខ៣៣០កយ/រប, ០៣ មីនា ២០០៦។

ករណីអ្នកទទួលលិខិតសំខាន់ក្នុងការពិភាក្សាត្រូវសរសេរ "លិខិតរបស់...ផ្ញើជូន..." បើមានកម្មវត្ថុច្បាស់លាស់ត្រូវបញ្ជាក់ផងក៏បាន។

N: 86. លិខិតរបស់សម្តេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រីទី២, លេខ៩១៨ខុទ្ទ/៩៥, ១៦ មិថុនា ១៩៩៥។

T: (លិខិតលេខ៩១៨ខុទ្ទ/៩៥)

B,R: លិខិតរបស់សម្តេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រីទី២, លេខ៩១៨ខុទ្ទ/៩៥, ១៦ មិថុនា ១៩៩៥។

## 11. ការយោងដូចគ្នានឹងការយោងមុនៗ

### 11.1. ប្រភពទី១

ប្រភពទី១ដូចជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវសរសេរឡើងវិញទាំងអស់ ប្រសិនបើយោងនៅសម្គាល់ក្រោយៗទៀត ទោះបីជាយោងជាប់ៗគ្នាក៏ដោយ។

ប្រសិនបើលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានយោងនោះ វែងពេក គេអាចដាក់ឈ្មោះវាសម្រាប់ងាយហៅ ក្នុងការយោងក្នុងទម្រង់ជាសម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទជាបន្តបន្ទាប់ទៀតដោយប្រើពាក្យថា "ចាប់ពីពេលនេះតទៅហៅថា..." ឬ"ចាប់ពីពេលនេះតទៅ..." "ពីពេលនេះតទៅហៅថា..." ឬ"ពីពេលនេះតទៅ..."។

ឧទាហរណ៍នៃការយោងប្រភពទី១ ដែលមានលេខសម្គាល់ជាប់គ្នាបន្តបន្ទាប់ ហើយយោងទៅនឹងប្រភពដូចគ្នា។

N: 19. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៦, លេខនស/រកម/១២០៥/០៤០, ៣០ ធ្នូ ២០០៥, មាត្រា៦ (ពីពេលនេះតទៅហៅថាច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ)។

20. ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ, មាត្រា៣។

21. ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ, មាត្រា៥។

22. ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ, មាត្រា១០។

N: 3. អនុក្រឹត្យស្តីពីការដាក់បញ្ញាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៥អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា១០ (ពីពេលនេះតទៅអនុក្រឹត្យលេខ១១៥អនក្រ/បក)។

4. អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា៨។

5. អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា១០។

ឧទាហរណ៍នៃការយោងប្រភពទី១ ដែលមានលេខសម្គាល់នៅដាច់ពីគ្នា ហើយយោងទៅនឹងប្រភពដូចគ្នា។

N: 59. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខនស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦, មាត្រា៩ (ពីពេលនេះតទៅហៅថាច្បាប់បរិស្ថានឆ្នាំ១៩៩៦)។

76. ច្បាប់បរិស្ថានឆ្នាំ១៩៩៦, មាត្រា៥។

82. ច្បាប់បរិស្ថានឆ្នាំ១៩៩៦, មាត្រា៨។

N: 60. អនុក្រឹត្យស្តីពីការដាក់បញ្ញាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៨អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា១០ (ពីពេលនេះតទៅអនុក្រឹត្យលេខ១១៨អនក្រ/បក)។

64. អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា៨។

78. អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា១០។

N: 13. សេចក្តីណែនាំស្តីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ, លេខ០០១សណន, ០៩ មករា ២០០៧ (ពីពេលនេះតទៅហៅថាសេចក្តីណែនាំលេខ០០១សណន២០០៧)។

69. សេចក្តីណែនាំលេខ០០១សណន២០០៧។

98. សេចក្តីណែនាំលេខ០០១សណន២០០៧។

**11.2. ប្រភពទី២**

ការយោងទៅនឹងប្រភពទី២ដូចជាសៀវភៅ ឬឯកសារស្រាវជ្រាវដូចគ្នាជាបន្តបន្ទាប់នៅក្នុងអត្ថបទតែមួយ គេមិនចាំបាច់សរសេរប្រភពនោះពេញទៀតទេ នៅពេលផ្តល់ប្រភពក្រោយៗទៀត។ គេអាចសរសេរខ្លីជាងមុនដោយគ្រាន់តែដាក់ឈ្មោះអ្នកនិពន្ធ និងផ្នែកខ្លះនៃចំណងជើងសៀវភៅក៏បាន។ គេអាចប្រើពាក្យ "ដូច" រួចដាក់សម្គាល់លេខសម្គាល់ដែលដូចនោះ។ ឧទាហរណ៍ "ដូច១២"។ ក្នុងករណីដែលសម្គាល់នៅខាងលើជាប់គ្នាតែម្តង ត្រូវប្រើពាក្យ "ដដែល"។ ប្រសិនបើទំព័រក៏ដូចគ្នាទៀតមិនចាំបាច់បញ្ជាក់ទំព័រឡើយ ប៉ុន្តែបើទំព័រខុសត្រូវបញ្ជាក់លេខទំព័រនោះ។

ប៉ុន្តែ ចំពោះការយោងទៅនឹងលិខិតបទដ្ឋានគតិយុត្តដែលជាប្រភពទី១ គេមិនត្រូវប្រើពាក្យ "ដូច" ឬ"ដដែល" នោះទេ គឺយ៉ាងហោចណាស់ត្រូវសរសេរឈ្មោះលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវបានហៅដោយសង្ខេបនោះតែប៉ុណ្ណោះ។ ការអនុវត្តទាំងនេះគឺធ្វើតែទៅលើសម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទតែប៉ុណ្ណោះ ចំណែកឯគន្ថនិទ្ទេស និងឯកសារយោងមិនត្រូវបានអនុវត្តឡើយ។

N: 62. អ៊ុន លាង និងផ្សេងទៀត, *គ្រឹះរបស់ទស្សនវិជ្ជា*, ជាមួយនឹងសេចក្តីផ្តើមដោយ វុន រ៉េត (ភ្នំពេញ, ២០០៦), ២។

75. ដូច៦២, ទំព័រ៨៩។

> លេខនៃសម្គាល់ទី៧៥ និង៨៩ត្រូវបានយោងដូចគ្នានឹងលេខសម្គាល់ទី៦២ មិនចាំបាច់សរសេរឡើងវិញទេ គឺប្រើតែពាក្យ "ដូច + លេខដែលដូច" ជាការស្រេច។

89. ដូច៦២, ទំព័រ៦៥។

N: 63. អ៊ុន លាង និងផ្សេងទៀត, *គ្រឹះរបស់ទស្សនវិជ្ជា*, ជាមួយនឹង

សេចក្ដីផ្ដើមដោយ វុន វ៉េត (ភ្នំពេញ,២០០៦), ២។

64. ដដែល, ទំព័រ៨។

65. ដដែល, ទំព័រ១៥។

> លេខនៃសម្គាល់ទី៦៤ និង៦៥ត្រូវបានយោងរៀងគ្នាដូចនឹងលេខសម្គាល់ទី៦៣។ ក្នុងករណីនេះ ត្រូវប្រើពាក្យ "ដដែល, ទំព័រដែលយោង (ប្រសិនបើចាំបាច់)" ជាការស្រេច។

66. សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១៥៣។

67. ជា សៅ, កែសម្រួល, *ដំណើរជីវិតឆ្ពោះទៅរកភាពជោគជ័យ*, ដោយ សំ សារាយ (ភ្នំពេញ៖ សុខលាប, ២០០៣), ៧៦។

68. ដូច៦៦។

> លេខនៃសម្គាល់ទី៦៨ ដូចនឹងលេខសម្គាល់ទី៦៦ យើងត្រូវប្រើពាក្យ "ដូច + លេខនៃសម្គាល់ដែលដូច, ទំព័រដែលយោង (ប្រសិនបើចាំបាច់)" ជាការស្រេច។ សម្គាល់នេះ យោងទំព័រដូចគ្នានឹងសម្គាល់ទី៦៦ដែរ។

69. ដូច៦៣, ទំព័រ១។

> លេខនៃសម្គាល់ទី៦៩ ដូចនឹងលេខសម្គាល់ទី៦៥ តែលេខសម្គាល់៦៥ ដូចលេខសម្គាល់៦៤ និង៦៣តគ្នា។ ដោយលេខសម្គាល់ទី៦៣មានប្រភពព័ត៌មានលំអិត យើងត្រូវប្រើពាក្យ "ដូច + លេខនៃសម្គាល់ទី៦៣, ទំព័រដែលយោង (ប្រសិនបើចាំបាច់)"។

## 12. អនុវត្តន៍ការផ្ដល់ប្រភពឯកសារ

### 12.1. អនុវត្តន៍ការផ្ដល់ប្រភពជាសម្គាល់ក្រោមទំព័រ

ខាងក្រោមនេះ ជាឧទាហរណ៍នៃការផ្តល់ប្រភពតាមទម្រង់ជាសម្គាល់ក្រោមទំព័រនៅក្នុងអត្ថបទដកស្រង់មួយ។

តាំងពីឆ្នាំ១៩៩២មក អ្នកកាន់កាប់ដីមានជម្រើសក្នុងការចុះបញ្ជីដីរបស់ពួកគេតាមរយៈនីតិវិធីចុះបញ្ជីដីដោយស្ម័គ្រចិត្ត (ការចុះបញ្ជីដីផ្ទីមានលក្ខណៈដាច់ដោយដុំ) ដើម្បីទទួលបាននូវការការពារប័ណ្ណភោគៈលើអចលនវត្ថុ។ ប្រហែល៦០០.០០០ប័ណ្ណភោគៈត្រូវបានចុះបញ្ជីរួចគិតរហូតដល់ខែមេសា ឆ្នាំ២០១០។[1] ច្បាប់ភូមិបាលឆ្នាំ២០០១ ផ្តល់ជាបន្ថែមនូវនីតិវិធីដោយឡែកមួយ គឺការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលតាមរយៈនេះ អាជ្ញាធរមានសមត្ថកិច្ចចុះបញ្ជីដីទាំងអស់នៅក្នុងតំបន់ដែលបានកំណត់ ហើយជាលទ្ធផលផ្តល់នូវប័ណ្ណកម្មសិទ្ធិពេញលេញសម្រាប់ម្ចាស់ដីនីមួយៗ។[2] តាមរយៈការអនុវត្តជាក់ស្តែងការចុះបញ្ជី ដីមានលក្ខណៈជាប្រព័ន្ធគឺស្មុគស្មាញ និងមានដំណើរការយឺត។ រហូតមកដល់ខែមេសា ឆ្នាំ២០១០ មានតួលេខប្រហែលតែ១,៣លានប័ណ្ណគត់ ត្រូវបានចុះបញ្ជីតាមរយៈការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ហើយជាសរុប គិតមកដល់ខែមេសា ឆ្នាំ២០១០ ប្រហែល១,៩លានប័ណ្ណ (គិតទាំងប័ណ្ណភោគៈ)[3] ត្រូវបានចុះបញ្ជី ក្នុងចំណោមក្បាលដីដែលបានប៉ាន់ប្រមាណចំនួន១០លាក្បាលដី។[4]

---

1. លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, លេខ៩៩៨ដនស/សដភ, ១៦ មិថុនា ២០១០ (ពីពេលនេះតទៅ លិខិតរបស់ក្រសួងរៀបចំដែនដី)។
2. ច្បាប់ភូមិបាលកម្ពុជា, លេខ នស/រកម/០៨០១/១៩, ៣០ សីហា ២០០១, មាត្រា២២៩។
3. លិខិតរបស់ក្រសួងរៀបចំដែនដី។
4. សៀក វណ្ណា (ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី), បទសម្ភាសផ្ទាល់ខ្លួន, ០៣ ធ្នូ ២០០៨។

### 12.2. អនុវត្តន៍ការផ្តល់ប្រភពជាសម្គាល់ក្នុងអត្ថបទ

ខាងក្រោមនេះ ជាឧទាហរណ៍នៃការផ្តល់ប្រភពតាមទម្រង់ជាសម្គាល់ក្នុងអត្ថបទដែលដកស្រង់ចេញពីអត្ថបទខាងលើ។

> តាំងពីឆ្នាំ១៩៩២មក អ្នកកាន់កាប់ដីមានជម្រើសក្នុងការចុះបញ្ជីដីរបស់ពួកគេតាមរយៈនីតិវិធីចុះបញ្ជីដីដោយស្ម័គ្រចិត្ត (ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ) ដើម្បីទទួលបាននូវការការពារប័ណ្ណភោគៈលើអចលនវត្ថុ។ ប្រហែល៦០០.០០០ប័ណ្ណភោគៈ ត្រូវបានចុះបញ្ជីរួចគិតរហូតដល់ខែមេសាឆ្នាំ២០១០ (លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,២០១០)។ ច្បាប់ភូមិបាលឆ្នាំ២០០១ ផ្តល់ជាបន្ថែមនូវនីតិវិធីដោយឡែកមួយ គឺការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលតាមរយៈនេះ អាជ្ញាធរមានសមត្ថកិច្ច ចុះបញ្ជីដីទាំងអស់នៅក្នុងតំបន់ដែលបានកំណត់ ហើយជាលទ្ធផលផ្តល់នូវប័ណ្ណកម្មសិទ្ធិពេញលេញ សម្រាប់ម្ចាស់ដីនីមួយៗ (ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា២២៩)។ តាមរយៈការអនុវត្តជាក់ស្តែង ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ គឺស្មុគស្មាញ និងមានដំណើរការយឺត។ រហូតមកដល់ខែមេសា ឆ្នាំ២០១០ មានតួលេខប្រហែលតែ១,៣លានប័ណ្ណគត់ត្រូវបានចុះបញ្ជី តាមរយៈការចុះបញ្ជីដីមាន
>
> 1

*សម្គាល់ក្នុងអត្ថបទ*

លក្ខណៈជាប្រព័ន្ធ ហើយជាសរុបគិតមកដល់ខែមេសា ឆ្នាំ២០១០ ប្រហែល១,៩លានប័ណ្ណ (គិតទាំងប័ណ្ណភោគៈ) (លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូនសាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១០) ត្រូវបានចុះបញ្ជី ក្នុងចំណោមក្បាល ដីដែលបាន ប៉ាន់ប្រមាណ ចំនួន១០លានក្បាលដី (សៀក វណ្ណា, បទសម្ភាសផ្ទាល់ខ្លួន)។

*សម្គាល់ក្នុងអត្ថបទ*

### ឯកសារយោង


ច្បាប់ភូមិបាលកម្ពុជា, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, លេខ ៩៩៨ដនស/សដភ, ១៦ មិថុនា ២០១០។

សៀក វណ្ណា (ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី). ២០០៨. បទសម្ភាសផ្ទាល់ខ្លួន, ០៣ ធ្នូ។


*ការផ្តល់ប្រភពមានចំនួន៩ដង ប៉ុន្តែប្រភពសរុបមានចំនួនតែ៣ប៉ុណ្ណោះ។*

2

## 13. អនុវត្តន៍ការតម្រៀបបញ្ជីប្រភពឯកសារ

### 13.1. ការតម្រៀបប្រភពក្នុងគន្ថនិទ្ទេស

ខាងក្រោមនេះ ជាឧទាហរណ៍នៃការផ្តល់ប្រភពដែលមានចំនួនច្រើន (៣០សម្គាល់) ហើយយើងតម្រៀបវាក្នុងគន្ថនិទ្ទេស។ ឧទាហរណ៍នៃសម្គាល់ទាំងនេះ ត្រូវបានដកស្រង់ចេញពីក្នុងឯកសារខាងលើនេះទាំងអស់ ដើម្បីងាយស្រួលក្នុងការយល់ ពីព្រោះវាសុទ្ធតែមានការសរសេរក្នុងទម្រង់ជាគន្ថនិទ្ទេសរួចជាស្រេច។

### សម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទ

1. សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១៥៣។

2. ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ* (ភ្នំពេញ, ១៩៧៣), ១០។

3. សារិន ឆាក, *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្តាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤), ៣៣។

4. ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៥ (ពីពេលនេះតទៅហៅថា ច្បាប់ភូមិបាលឆ្នាំ២០០១)។

5. ប៉ែន សុវណ្ណ និងនាង សារុន, *ប៉ែន សុវណ្ណ៖ ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា* (វ៉ាស៊ីងតោន៖ ចក្ខុវិស័យខ្មែរ, ២០០២), ៩៧។

6. ដដែល, ទំព័រ១៩៨។

7. ដូច២, ទំព័រ១៤០។

8. ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៤៧-៤៥៣ (ពីពេលនេះតទៅហៅថា ក្រមរដ្ឋនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦)។

9. ដូច២, ទំព័រ១៨០។

10. អ៊ុន លាង និងផ្សេងទៀត, *គ្រឹះរបស់ទស្សនវិជ្ជា* (ភ្នំពេញ, ២០០៦), ៥០។
11. *ជីវិតឆ្ពោះទៅរកជោគជ័យ* (ភ្នំពេញ, ២០០១), ៨០។
12. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ* (ភ្នំពេញ, ២០០១), ៤៣។
13. ដូច១០, ទំព័រ៥៥។
14. ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា១៥។
15. ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦, មាត្រា៣។
16. ដូច២, ទំព័រ១០២។
17. ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៦២។
18. ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៤៧។
19. ដូច៥, ទំព័រ៦៤។
20. David Chandler, *ប្រវត្តិសាស្ត្រខ្មែរ*, បកប្រែ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត (ភ្នំពេញ៖ JSRC, ២០០៥), ៩០។
21. ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៤២។
22. ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៦៤។
23.ព្រះរាជក្រឹត្យគ្មានលេខ, ០១វិច្ឆិកា ១៩៩៣, មាត្រា២។
24. ដូច១, ទំព័រ១៥។
25. ដដែល, ទំព័រ២១៣។
26. ដូច២០, ទំព័រ១៩៩។
27. អនុក្រឹត្យស្តីពីការដាក់បញ្ចាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា១០។
28. សាយ បូរី, *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ ប្អូស្សំឡូទឹស, ២០០២), ៩០។
29. ដូច១០, ទំព័រ៩២។

30. ដូច៥, ទំព័រ១៩០។

ដោយគន្ថនិទ្ទេសជាបញ្ជីនៃប្រភពឯកសារ ដំបូងយើងត្រូវដកស្រង់យកឯកសារណាដែលមានប្រភពផ្សេងគ្នា។ ក្នុងឧទាហរណ៍ខាងលើនេះមានប្រភពផ្សេងគ្នាចំនួន១៨តែប៉ុណ្ណោះ។ បន្ទាប់មក យើងអាចចាត់ថ្នាក់បញ្ជីឯកសារទៅតាមប្រភេទរបស់វា ដូចជា "ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត" "សៀវភៅ" "របាយការណ៍" ជាដើម។

នៅក្នុងឧទាហរណ៍ខាងលើនេះ មានប្រភេទបញ្ជីប្រភពឯកសារតែ២ គឺ "ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត" និង "សៀវភៅ" ដូច្នេះយើងតម្រៀបដូចតទៅនេះ។

## គន្ថនិទ្ទេស

**ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ព្រះរាជក្រឹត្យលេខ នស/រតត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦។

ព្រះរាជក្រឹត្យគ្មានលេខ, ០១ វិច្ឆិកា ១៩៩៣។

អនុក្រឹត្យស្តីពីការដាក់បញ្ចាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/បក, ២៩ សីហា ២០០៧។

**សៀវភៅ**

Chandler, David. *ប្រវត្តិសាស្ត្រខ្មែរ.* បកប្រែដោយ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត. ភ្នំពេញ៖ JSRC, ២០០៥។

ត្រឹង ងា. *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ.* ភ្នំពេញ, ១៩៧៣។

ប៉ែន សុវណ្ណ និងនាង សារុន. *ប៉ែន សុវណ្ណ៖ ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា.* វ៉ាស៊ីងតោន៖ ចក្ខុវិស័យខ្មែរ, ២០០២។

សាយ បូរី. *នីតិរដ្ឋបាលទូទៅ,* បោះពុម្ពលើកទី៣. ភ្នំពេញ៖ ប្លុស្សំឡូទីស, ២០០២។

———. *វិទ្យាសាស្ត្ររដ្ឋបាល.* ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧។

សារិន ឆាក. *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្តាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម).* ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤។

អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សារេន, ឈត ប៊ុនថង និងឈុន ផារ៉េង. *គ្រឹះរបស់ទស្សនវិជ្ជា.* ភ្នំពេញ, ២០០៦។

អ្នកនិពន្ធអនាមិក. *ជីវិតឆ្ពោះទៅរកជោគជ័យ.* ភ្នំពេញ, ២០០១។

———. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ.* ភ្នំពេញ, ២០០១។

ការតម្រៀបប្រភពឯកសារខាងលើនេះ គឺត្រូវធ្វើឡើងតាមលំដាប់អក្ខរក្រម ពោលគឺ Chandler = ឆ, ត្រឹង ងា = ត, ប៉ែន សុវណ្ណ = ប៉, សាយ បូរី = ស, សារិន ឆាក = ស, អ៊ុន លាង = អ, អ្នកនិពន្ធអនាមិក = អ។

ក្នុងករណីខាងលើ យើងឃើញមានអក្សរដូចគ្នាមួយចំនួន។ ក្នុងការចាត់លំដាប់លេខរៀងរបស់វា បើវាមានស្រៈដូចគ្នា យើងត្រូវមើលតួអក្សរបន្ទាប់។ ក្នុងឧទាហរណ៍ខាងលើ គឺអក្សរ យ នៅពីមុខ អក្សរ រ ដូច្នេះ សាយ បូរី ត្រូវឋិតនៅមុខ សារិន ឆាក។ ចំណែក អ វិញ គេត្រូវគិតអក្សរ អ ប្រកបជាមួយស្រៈសិន បន្ទាប់មកទើបជាមួយព្យញ្ជនៈ ពោលគឺ អ៊ុន ត្រូវនៅពីមុខ អ្នក ដូច្នេះហើយបានជា អ៊ុន លាង ត្រូវបានសរសេរនៅពីមុខអ្នកនិពន្ធអនាមិក។

## 13.2. ការតម្រៀបប្រភពក្នុងឯកសារយោង

ដើម្បីងាយស្រួលក្នុងការបង្ហាញ ខ្ញុំសូមលើកយកឧទាហរណ៍ខាងលើមកពិភាក្សា។ ចំពោះច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការតម្រៀបបញ្ជីប្រភពនៅក្នុងឯកសារយោង គឺដូចគ្នានឹងនៅក្នុងគន្ថនិទ្ទេសដែរ។ ចំណែកការតម្រៀបបញ្ជីប្រភពឯកសារដទៃទៀត គឺក្នុងឯកសារយោង ត្រូវដាក់ឆ្នាំបោះពុម្ពផ្សាយនៅចន្លោះឈ្មោះអ្នកនិពន្ធ និងឈ្មោះចំណងជើងឯកសារ។ ដូច្នេះយើងបានបញ្ជីឈ្មោះប្រភពឯកសារក្នុងទម្រង់ជាឯកសារយោងដូចខាងក្រោម។

### ឯកសារយោង

**ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦។

ព្រះរាជក្រឹត្យគ្មានលេខ, ០១ វិច្ឆិកា ១៩៩៣។

*វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា*
អនុក្រឹត្យស្តីពីការដាក់បញ្ញាំការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/បក, ២៩ សីហា ២០០៧។

## សៀវភៅ

Chandler, David. ២០០៥. *ប្រវត្តិសាស្ត្រខ្មែរ.* បកប្រែដោយ ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី និងសេង សោត. ភ្នំពេញ៖ JSRC។

ត្រឹង ងា. ១៩៧៣. *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ.* ភ្នំពេញ។

ប៉ែន សុវណ្ណ និងនាង សារុន. ២០០២. *ប៉ែន សុវណ្ណ៖ ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា.* វ៉ាស៊ីងតោន៖ ចក្ខុវិស័យខ្មែរ។

សាយ បូរី. ២០០២. *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣. ភ្នំពេញ៖ ប្លុស្សំឡូទីស។

———. ២០០៧. *វិទ្យាសាស្ត្ររដ្ឋបាល.* ភ្នំពេញ៖ បណ្ណាគារអង្គរ។

សារិន ឆាក. ២០០៨. *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្តាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម).* ភ្នំពេញ៖ ឥន្ទ្រទេវី។

អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សាវន, ឈត ប៊ុនថង និងឈុន ផារ៉េង. ២០០៦. *គ្រឹះរបស់ទស្សនវិជ្ជា.* ភ្នំពេញ។

អ្នកនិពន្ធអនាមិក. ២០០១. *ជីវិតឆ្ពោះទៅរកជោគជ័យ.* ភ្នំពេញ។

———. ២០០១. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ.* ភ្នំពេញ។

# ការលួចគំនិតអ្នកដទៃ

## ( Plagiarism )

នៅផ្នែកនេះ អ្នកនឹងស្វែងយល់អំពីការសរសេរដែលប្រកបដោយគុណភាព ដោយជៀសវាងការលួចគំនិតអ្នកដទៃ។ សេចក្តីស្មោះត្រង់ក្នុងការសិក្សាមានសារៈសំខាន់ណាស់សម្រាប់ការស្រាវជ្រាវទាំងឡាយ ពីព្រោះស្នាដៃ ដែលកើតចេញពីការស្រាវជ្រាវនោះវាក្លាយទៅជាប្រភពដ៏សំខាន់ និងអាចជឿជាក់បានសម្រាប់ការស្រាវជ្រាវក្រោយៗទៀត។ ការបញ្ជាក់ច្បាស់ពីរបៀបនៃការដកស្រង់សំដីទាំងស្រុង នៅក្នុងការពិភាក្សាជាការចាំបាច់ ដើម្បីឲ្យអ្នកអានយល់ដឹងច្បាស់អំពីការស្រាវជ្រាវ ថាតើជាគំនិត ឬពាក្យពេចន៍ផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវ ឬអ្នកនិពន្ធ។

គ្មានច្បាប់ណាមួយដាក់ទោសទណ្ឌចំពោះអ្នកលួចគំនិតរបស់គេ ឬលួចស្នាដៃគេដាក់ចូលក្នុងស្នាដៃរបស់ខ្លួននៅឡើយទេ នាពេលបច្ចុប្បន្ន។ ដោយឡែក ចំពោះការល្មើសនឹងកម្មសិទ្ធិបញ្ញាក្នុងការធ្វើអាជីវកម្ម ដូចជាការលួចបោះពុម្ពផ្សាយស្នាដៃរបស់គេយកទៅធ្វើអាជីវកម្ម ត្រូវបានច្បាប់កម្មសិទ្ធិបញ្ញាគ្រប់គ្រងយ៉ាងច្បាស់លាស់។ នៅប្រទេសជឿនលឿន ប្រជាពលរដ្ឋរបស់គេគោរពច្បាប់កម្មសិទ្ធិបញ្ញាយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែ នៅប្រទេសកំពុងអភិវឌ្ឍ បញ្ហានៃការគោរពច្បាប់កម្មសិទ្ធិបញ្ញា នៅមានកម្រិតនៅឡើយ។ ទោះជាគ្មានច្បាប់ដាក់ទោសទណ្ឌ ពាក់ព័ន្ធនឹងការលួចគំនិតរបស់អ្នកដទៃយ៉ាងណាក៏ដោយ នៅក្នុងពិភពសិក្សា បញ្ហានៃការលួចគំនិតគេ ឬលួចផ្នែកខ្លះនៃស្នាដៃរបស់គេមកដាក់បញ្ចូលក្នុងស្នាដៃរបស់ខ្លួនដោយមិនបានបញ្ជាក់ពីប្រភពរបស់វា គឺជាបទល្មើសនឹងវិន័យសិក្សា។ សាកលវិទ្យាល័យ ឬស្ថាប័នសិក្សាទាំងឡាយមានតួនាទីសំខាន់ណាស់ក្នុងការសម្រេចដាក់ទណ្ឌកម្មលើបញ្ហាល្មើសនឹងវិន័យសិក្សានេះ ពោលគឺសាកលវិទ្យាល័យអាចសម្រេចដកយកសញ្ញាបត្រ ដែលបានប្រគល់ឲ្យ

និស្សិតមកវិញ ប្រសិនបើនិស្សិតដែលបានសរសេរនិក្ខេបបទ ត្រូវបានគេរកឃើញថាបានលួចគំនិតរបស់អ្នកដទៃយ៉ាងធ្ងន់ធ្ងរដាក់ចូលក្នុងនិក្ខេបបទរបស់ខ្លួន។ ចំណែកឯសាស្ត្រាចារ្យបង្រៀនវិញមានសិទ្ធិពេញលេញ ក្នុងការសម្រេចលើកិច្ចការរបស់និស្សិតដែលលួចគំនិតរបស់គេ ដោយមិនបានបញ្ជាក់ប្រភព។ រាល់កិច្ចការទាំងនោះ សាស្ត្រាចារ្យមានសិទ្ធិគ្រប់គ្រាន់ក្នុងការមិនដាក់ពិន្ទុឲ្យ ដាក់ពិន្ទុធ្លាក់ ឬតម្រូវឲ្យនិស្សិតនោះរៀនឡើងវិញ។

ការលួចចម្លងគ្នានៅពេលប្រឡង ឬនៅពេលធ្វើកិច្ចការផ្ទះឬកិច្ចការស្រាវជ្រាវ ឬការដែលនិស្សិតទទួលបានផលសិក្សាពីអ្នកដទៃ ក៏ត្រូវបានចាត់ទុកថាជាការល្មើសនឹងវិន័យសិក្សាផងដែរ។ ពិន្ទុដែលនិស្សិតទទួលបានពីការសិក្សាគឺជាលទ្ធផលនៃការសិក្សាដែលត្រូវបានគេចាត់ទុកថា ជាការវាស់ស្ទង់សមត្ថភាពបញ្ញាផ្នែកសិក្សា។ ប្រសិនបើលទ្ធផលនោះបានមកដោយសារគេ នោះវាក៏មិនឆ្លុះបញ្ចាំងពីសមត្ថភាពផ្នែកចំណេះដឹងរបស់និស្សិតឡើយ។ បើសង្គមមួយពោរពេញទៅដោយបញ្ហាទាំងនេះ នោះសង្គមទាំងមូល នឹងប្រឈមមុខចំពោះការស្វែងរកសមត្ថភាពពិតដោយស្តែងចេញពីភស្តុតាងនៃការសិក្សាណាស់។ គេក៏អាចនិយាយបានផងដែរថា សង្គមនោះពោរពេញទៅដោយការអប់រំដែលគ្មានគុណភាព។ ដូច្នេះ ដើម្បីសម្រេចបានគោលដៅនេះ សាស្ត្រាចារ្យគួរពិន័យចំពោះនិស្សិតដែលបានប្រព្រឹត្តនូវកំហុសទាំងនេះឲ្យបានយ៉ាងតឹងតែងបំផុត។ ជាមួយគ្នានេះដែរ សាស្ត្រាចារ្យខ្លួនឯងផ្ទាល់ក៏គប្បីមានវិធានត្រឹមត្រូវ និងជាក់លាក់ក្នុងការដាក់ពិន្ទុដល់និស្សិតទាំងឡាយ ដើម្បីឲ្យពួកគេទទួលបាននូវសមធម៌ក្នុងការសិក្សា។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវ ឬអ្នកនិពន្ធតែងពឹងពាក់លើឯកសារស្រាវជ្រាវមុនៗ ដើម្បីជាមូលដ្ឋានក្នុងការវិភាគទៅលើអ្វីមួយ។ ក្នុងករណីនេះ អ្នកស្រាវជ្រាវ ឬអ្នកនិពន្ធ មានសិទ្ធិពេញលេញ ក្នុងការដកស្រង់សំដីទាំងស្រុងនៃផ្នែកណាមួយដែលពាក់ព័ន្ធនឹងការស្រាវជ្រាវរបស់ខ្លួន ឬគ្រាន់តែយោងទៅនឹងផ្នែកណាមួយ

ដោយមិនចាំបាច់សុំការអនុញ្ញាត លើកលែងតែមានបញ្ញត្តិហាមឃាត់ជាក់ស្តែងពីប្រភពដើមនោះតែម្តង។ រាល់ការដកស្រង់សំដីទាំងស្រុង ឬយោងប្រភពអ្នកដទៃត្រូវតែបញ្ជាក់ប្រភពដើមរបស់គេច្បាស់លាស់ បើពុំនោះទេ វាត្រូវខុសនឹងវិន័យសិក្សា។

វិធីដកស្រង់សំដីទាំងស្រុង និងវិធីប្រើពាក្យពេចន៍ផ្ទាល់ខ្លួនដោយយោងទៅនឹងប្រភពណាមួយ ដើម្បីជៀសវាងការលួចគំនិតអ្នកដទៃ ត្រូវបានលើកយកមកបញ្ជាក់លំអិតនៅផ្នែកនេះ។

# 1. គោលការណ៍សំខាន់ៗចំពោះការលួចគំនិតអ្នកដទៃ

## 1.1. ការដកស្រង់សំដីទាំងស្រុង

របៀបនៃការស្រង់សំដីទាំងស្រុងចែកចេញជាពីរៈ

- សំដីទាំងស្រុងនៅក្នុងអព្តន្តរសញ្ញា គឺជាសំដីទាំងស្រុងដែលខ្លីៗ វាអាចជាកន្សោមពាក្យ ឬល្បះដែលអាចបិតនៅក្នុងកថាខណ្ឌជាមួយគ្នាបាន។
- សំដីទាំងស្រុងមិននៅក្នុងអព្តន្តរសញ្ញា គឺជាសំដីទាំងស្រុងដែលវែងៗ វាអាចជាកថាខណ្ឌមួយ ឬច្រើន។ ករណីខ្លះសំដីទាំងស្រុងប្រភេទនេះអាចជាល្បះដែរ ដែលអ្នកស្រាវជ្រាវ ឬអ្នកនិពន្ធគិតថាវាមានសារៈសំខាន់ណាស់ ហើយចាំបាច់ត្រូវតែផ្តាច់វាឲ្យចេញពីកថាខណ្ឌខាងលើ ដើម្បីងាយស្រួលក្នុងការពិភាក្សា។ ក្នុងការសរសេរសំដីទាំងស្រុងប្រភេទនេះ គេត្រូវធ្វើយ៉ាងណាក៏ដោយឲ្យតែអ្នកអាន ងាយមើលថាវាមិនមែនជាកថាខណ្ឌដែលជាសំដីផ្ទាល់របស់អ្នកសរសេរទេ។ ជាទូទៅ គេត្រូវសរសេរវាដោយរំលងមួយ

បន្ទាត់ពីកថាខណ្ឌខាងលើ និងខាងក្រោម រួចត្រូវរំលងមួយtab ខាងឆ្វេង និងខាងស្តាំ រីឯទំហំអក្សរអាចតូចបន្តិចក៏បាន។

តទៅនេះ ការប្រើពាក្យថាការស្រង់សំដីទាំងស្រុងដោយដាក់នៅក្នុងអព្ភន្តរសញ្ញា សំដៅទៅលើការស្រង់សំដីទាំងស្រុងនៅក្នុងប្រភេទទាំងពីរខាងលើ។

### 1.1.1. ការដកស្រង់សំដីទាំងស្រុងដោយដាក់ក្នុងអព្ភន្តរសញ្ញា ប៉ុន្តែមិនបានបញ្ជាក់ប្រភព




ពាក្យទាំងឡាយនៅក្នុងអព្ភន្តរសញ្ញាខាងលើនេះគឺជាសំដីទាំងស្រុងដែលត្រូវបានសរសេរត្រឹមត្រូវតាមក្បួនខ្នាតហើយ ប៉ុន្តែវាមានកំហុស

បច្ចេកទេសដោយមិនបានបញ្ជាក់ប្រភព។ ដូច្នេះ ការសរសេរតាមលំនាំដូចខាងលើនេះត្រូវបានគេចាត់ទុកថាជាការលួចគំនិតអ្នកដទៃ។




ដូចបំណកស្រាយខាងលើដែរ សំដីទាំងស្រុងខាងលើនេះ ត្រូវបានសរសេរត្រឹមត្រូវតាមក្បួនខ្នាតហើយ ប៉ុន្តែវាមានកំហុសត្រង់មិនបានបញ្ជាក់ប្រភព។ ដូច្នេះហើយ ការសរសេរដូចលំនាំខាងលើនេះត្រូវបានគេចាត់ទុកថាជាការលួចគំនិតអ្នកដទៃ។

ខាងក្រោមនេះ ជាឧទាហរណ៍នៃការលួចគំនិតអ្នកដទៃ។

A.Leclère បានសរសេរថា "...ព្រះករុណា ព្រះអង្គដួង ចង់ដឹងអំពីគោលបំណងរបស់បារាំង និងចង់ដឹងថាតើប្រសិនជាបារាំងគ្រាន់តែគិតគូរធ្វើការសងសឹកនូវការប្រមាថ ដែលពួកអណ្ណាមបានធ្វើមកលើពួកគេ ដើម្បីរក្សាទុកនូវចំណុចមួយនៃឆ្នេរសមុទ្រតែប៉ុណ្ណោះ ឬក៏ធ្វើសញ្ជ័យលើទឹកដីកូសាំងស៊ីនក្រោម"... ។

ប្រភព៖ ទៀ ថេន, *រឿងរ៉ាវនៃទឹកដីកម្ពុជាក្រោម ឬអតីតកូសាំងស៊ីន* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៥), ៩៩។

"ចាប់ពីបង្គោលលេខ ៨៣ ដែលស្ថិតនៅចម្ងាយ ១២៨ ម ពីត្រើយខាងឆ្វេងនៃទន្លេមេគង្គលើ ព្រំដែនបានដើរជាខ្សែត្រង់ ទៅបង្គោលលេខ ៨៤ នៅត្រើយខាងស្តាំនៃទន្លេ ដោយឆ្លងកាត់តាមដើម Cay gao (Cai gao ជាភាសាវៀតណាមដែលប្រែថា ដើមត្របែក) បន្ទាប់មកទៀត ដោយធ្វើដំណើរទៅទិសខាងលិច ដើរតាមខ្សែកាច់ឆ្លងកាត់តាមបង្គោលលេខ៨៥ និងលេខ ៨៦ ត្រើយខាងឆ្វេងនៃរ៉ាច កូ ឡូវ (Rach Co Lau) និងបង្គោលលេខ ៨៧ រវាងដើមស្វាយពីរដើម នៅលើត្រើយខាងឆ្វេងនៃ រ៉ាច់ បាណាម រហូតដល់បង្គោលលេខ ៨៨ ក្នុងលក្ខណៈទុកឲ្យប្រទេសកម្ពុជានូវភូមិទាំងឡាយ ពីបង្គោលលេខ ៨៨ ទៅមាត់ពាមនៃ រ៉ាច់ បាណាម ជាមួយនឹងទន្លេខាងក្រោម"។

(ប្រភព៖ សារិន ឆាក, *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្តាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤), ១៦៥។)

លោកក្រឡាហោម មានកម្លាំងកងទ័ពដ៏សំខាន់បង្គួរ ដើម្បីជានាអំណាចរបស់ខ្លួន នៅលើទឹកដីដែលខ្លួនទទួលបន្ទុក "ថ្ងៃទី៣ ខែមិថុនា លោក De Larclause បានសម្រេចទៅធ្វើការបញ្ជាក់ដល់ទីកន្លែងនូវព័ត៌មានទាំងឡាយ ដែលគេបានរាយការណ៍ជូនលោក និងប្រឹងប្រែងធ្វើឲ្យពួកគេគោរព ព្រមទាំងបានចាប់ប្រជានខ្លះ ដែលគេបានឲ្យការណ៍ ថាជាមេដឹកនាំនៃចលនានេះ ។ លោកក្រឡាហោមបានស្នើឲ្យនាយទាហានដែលបញ្ជាបន្ទាយនៅ តែ និញ គឺលោកអនុសេនីយ៍ឯក Pinault ជាមួយនិងទាហានអមការពារចំនួន១៥នាក់ និងពលបាលត្រីម្នាក់ផង និងលោកបានបញ្ជូនបញ្ជាទៅមេកម្ពុជា គឺ លូ ខា ហួម ឲ្យដាក់នៅក្រោមកិច្ចការរបស់លោកនូវមនុស្សចំនួន ១៥០ នាក់ នៅក្នុងចំណោមមនុស្សរបស់ខ្លួនដែលមានអាវុធ..."។

ប្រភព៖ សារិន ឆាក, *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្តាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤), ៩១។

**-ធ្វើជាបាត់បង់សតិ** (Pretend irrationality): ជួនកាល អាចបំភ័យគូសត្រូវដោយធ្វើជាមានស្មារតីមិនធម្មតា។ អតីតទីប្រឹក្សាច្បាប់សេតវិមាន លោកCharles Colsonបានរំលឹកថា ប្រធានាធិបតីអាមេរិកនិច សុន មានអាថ៌កំបាំងសំរាប់ជោគជ័យ (The Secret of succes)។ យោងតាមលោក Colson បានឱ្យដឹងថា លោកនិច សុនព្យាយាមបញ្ចុះបញ្ចូលសហភាពសូវៀតឱ្យដាក់សំពាធបន្ថែមលើវៀតណាមខាងជើងឱ្យយល់ព្រមតាមសំណើរសន្តិភាពរបស់អាមេរិក ដោយណែនាំលោកហិនរី ឃីស៊ីងហ្គ័រ (Henry Kissinger) ឱ្យជួបទូតសូវៀតលោក Anatoly Dobrynin ហើយប្រាប់គាត់ថា លោកប្រធានាធិបតីបានបាត់បង់សតិហើយ ហើយគាត់(Kissinger) មិនដឹងថាអាចរាំងប្រធានាធិបតីបានឬអត់... ហើយថា លោកនិច សុន អាចប្រើអាវុធធំៗ (នុយក្លេអ៊ែរ?) នៅវៀតណាមខាងជើង ។ លោកឃីស ស៊ីនហ្គ័របន្តទៀតថា " លោកនិច សុន បានធ្វើអ្វីប្លែក ដែលគាត់ពិបាកយល់..."។

ប្រភព៖ នួន សុធិមន្ត, *ច្បាប់ការទូត* (ភ្នំពេញ៖ បណ្ណាគារអង្គរធំ, ២០០៤), ៧៧។

ស្នាដៃខាងលើនេះជាការលួចគំនិតអ្នកដទៃ ព្រោះអត្ថបទដែលបានដាក់ក្នុងអព្ភន្តរសញ្ញា មិនបានបញ្ជាក់ប្រភពទេ។ នេះគឺជាការល្មើសនឹងវិន័យសិក្សាយ៉ាងធ្ងន់ធ្ងរ ដូច្នេះ អ្នកស្រាវជ្រាវទាំងឡាយគួរជៀសវាងបញ្ហានេះ។

ដើម្បីជៀសវាងការលួចគំនិតអ្នកដទៃ ការសរសេរដូចខាងលើនេះត្រូវតែបញ្ជាក់ប្រភព ទោះជាការស្រង់សំដីតិច ឬច្រើនក៏ដោយ។ រូបភាពខាងក្រោមនេះ បញ្ជាក់ពីការស្រង់សំដីទាំងស្រុងត្រឹមត្រូវតាមក្បួនខ្នាត ដោយមិនមែនជាការលួចគំនិតអ្នកដទៃទេ ព្រោះគេមានបញ្ជាក់ប្រភពត្រឹមត្រូវ។




ខាងក្រោមនេះ ជាឧទាហរណ៍នៃភាពត្រឹមត្រូវក្នុងការស្រង់សំដីទាំងស្រុង។

> ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ បានចែងថា :
>
> - "ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ ប្រភេទក ខ គ និង ឃ ដែលកំណត់ឡើង ដោយយោងទៅតាមល័ក្ខខ័ណ្ឌអប្បបរមា នៃការបណ្តុះបណ្តាល សំរាប់បញ្ចូលក្នុងក្របខ័ណ្ឌ និងកំរិតឋានានុក្រម នៃតំណែងរបស់ក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវចាត់បញ្ចូលទៅក្នុងប្រភេទណាមួយនៃប្រភេទទាំង៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន។" (មាត្រា២)

ប្រភព៖ សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១៣៥។

ការបញ្ជាក់ស្នាដៃខាងលើនេះ ហាក់ដូចជាទម្រង់សម្គាល់ក្នុងអត្ថបទ ដោយដាក់មាត្រា២នៅក្នុងវង្ងង់ក្រចក។ ប៉ុន្តែបើគ្មានការបញ្ជាក់ខាងលើពីប្រភពរបស់វាទេ ការដាក់មាត្រា២នៅក្នុងវង្ងង់ក្រចកមិនគ្រប់គ្រាន់ទេ។ ទោះជាមិនមានលក្ខណៈត្រឹមត្រូវតាមទម្រង់ជាសម្គាល់ក្នុងអត្ថបទក៏ដោយ ក៏ស្នាដៃខាងលើនេះមិនមែនជាការលួចគំនិតអ្នកដទៃទេ ព្រោះអ្នកអាន អាចស្វែងរកប្រភពដើមរបស់វាបាន។

> មាត្រា ១ វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះចែងថា : "រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការនីតិប្រតិបត្តិ មានភារកិច្ចកំណត់ និងអនុវត្តនយោបាយរបស់រដ្ឋ ស្របតាមគោល-ការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូ-ទៅរបស់រដ្ឋ លើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិនិងអង្គការតុលាការ។ ..." ។

ប្រភព៖ សាយ បូរី, *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ បូស្សំ ឡូទឹស, ២០០២), ៩០។

ស្នាដៃខាងលើនេះ មិនមែនជាការលួចគំនិតអ្នកដទៃទេ ថ្វីត្បិតតែអ្នកនិពន្ធមិនបញ្ជាក់ប្រភពនៅក្នុងទម្រង់ជាសម្គាល់ក្រោមទំព័រ ឬសម្គាល់ក្នុងអត្ថបទក៏ដោយ ពីព្រោះការបញ្ជាក់ប្រភពត្រូវបានរៀបរាប់នៅក្នុងអត្ថបទស្រាប់ នៅផ្នែកខាងលើ។

## សម្គាល់

កន្លងមក យើងសង្កេតឃើញថា ការសរសេរជាភាសាខ្មែរមួយចំនួននៅក្នុងសៀវភៅក្តី នៅក្នុងឯកសារផ្សេងៗទៀតក្តី មានភាពផ្សេងៗគ្នាទៅតាមការយល់ឃើញរបស់អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវ។ គេតែងសង្កេតឃើញការស្រង់សំដីទាំងស្រុងត្រូវបានសរសេរឡើងតាមទម្រង់ផ្សេងៗ ដូចជា

សរសេរជាអក្សរដិតពណ៌ខ្មៅជាងគេ ជាអក្សរទ្រេត ជាប្រភេទអក្សរផ្សេង ឬទំហំអក្សរធំជាងក៏មាន។

ចូរកត់សម្គាល់ថា ក្នុងការស្រង់សំដីទាំងស្រុង អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវមានសិទ្ធិពេញលេញក្នុងការស្រង់តែសំដីណាដែលមានសារៈសំខាន់ និងចាំបាច់ក្នុងការពិភាក្សាតែប៉ុណ្ណោះ។ ដូច្នេះសំដីណាមិនសូវសំខាន់ ឬមិនទាក់ទងនឹងការពិភាក្សា គេអាចរំលងវាចោល។ របៀបនៃការរំលងគឺសញ្ញាចុចបី សម្រាប់សម្គាល់ការរំលងពាក្យ សញ្ញាចុចបួននៅក្នុងបន្ទាត់តែមួយ សម្រាប់សម្គាល់ការរំលងកថាខណ្ឌ។






ដូចគ្នានេះដែរ អ្នកនិពន្ធ និងអ្នកស្រាវជ្រាវក៏មានសិទ្ធិក្នុងការកែតម្រូវពាក្យពេចន៍នៃសំដីទាំងស្រុង ដែលត្រូវបានសរសេរខុសអក្ខរាវិរុទ្ធចូលក្នុងអត្ថបទរបស់ខ្លួន ដោយគ្រាន់តែដាក់នៅក្នុងសញ្ញាឃ្នាបជាការគ្រប់គ្រាន់។ ពាក្យនៅក្នុងសញ្ញាឃ្នាប ក៏ត្រូវបានប្រើសម្រាប់ការបន្ថែមពាក្យដែលអ្នកនិពន្ធ ឬអ្នកស្រាវជ្រាវយល់ថាដើម្បីឲ្យគ្រប់ន័យត្រឹមត្រូវនៅក្នុងការស្រង់សំដីទាំងស្រុង។

សំដីទាំងស្រុងដោយមិនមានការកែតម្រូវ

| |
|---|
| ដើម្បីជានាឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តសិទ្ធិអំណាច និងកតាព្វកិច្ចរបស់តុលាការឱ្យបានល្អប្រសើរ រួមចំណែកដល់ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ការអភិវឌ្ឍន៍ប្រទេសជាតិ ក៏ដូចជាការលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស សិទ្ធិប្រជាពលរដ្ឋក្នុងនាមជាប្រទេសហត្ថលេខានៃកតិកាសញ្ញាស្តីពីសិទ្ធិស៊ីវិល និងនយោបាយ... |

នេះជាការកែតម្រូវនៃសំដីទាំងស្រុងខាងលើ ដើម្បីឲ្យមានភាពស្របគ្នាទៅតាមអក្ខរាវិរុទ្ធនៃអត្ថបទទាំងមូល។

អក្សរដើមត្រូវបានសរសេរជា "កតាព្វកិច្ច" ដែលជាកំហុសអក្ខរាវិរុទ្ធ

> ដើម្បីជានាឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តសិទ្ធិអំណាច និង[កាតព្វកិច្ច]របស់តុលាការឱ្យបានល្អប្រសើរ រួមចំណែកដល់ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ [ការអភិវឌ្ឍ] ប្រទេសជាតិ ក៏ដូចជាការលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស សិទ្ធិប្រជាពលរដ្ឋ ក្នុងនាមជាប្រទេសហត្ថលេខានៃកតិកាសញ្ញាស្តីពីសិទ្ធិស៊ីវិល និងនយោបាយ...

អក្សរដើមត្រូវបានសរសេរជា "ការអភិវឌ្ឍន៍"

សំដីទាំងស្រុងដោយមិនមានការកែតម្រូវ

> នាយករដ្ឋបាលត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ។ នាយករដ្ឋបាលមានគណនេយ្យ ចំពោះគណៈអភិបាល និងក្រុមប្រឹក្សា។

នេះជាការកែតម្រូវនៃសំដីទាំងស្រុងខាងលើ ដោយបន្ថែមពាក្យខ្លះដើម្បីឲ្យមានអត្ថន័យត្រឹមត្រូវ។

ត្រូវបានបន្ថែមទៅលើអត្ថបទដើមដែលមិនមានពាក្យនេះទេ

> នាយករដ្ឋបាលត្រូវ[បាន]តែងតាំងដោយក្រសួងមហាផ្ទៃ។ នាយករដ្ឋបាលមានគណនេយ្យ ចំពោះគណៈអភិបាល និងក្រុមប្រឹក្សា។

**សំដីទាំងស្រុងដែលមិនទាន់បានរំលង**

| |
|---|
| ទ្រព្យមួយចំនួនរបស់រដ្ឋ ឬរបស់សមូហភាពដែនដីសាធារណៈដែលត្រូវបានដាក់នៅក្រោមរបបគតិយុត្តពិសេស គឺជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈ។ ទ្រព្យមួយចំនួនទៀតត្រូវគ្រប់គ្រងដូចកម្មសិទ្ធិឯកជននិងអាចជាកម្មវត្ថុនៃកិច្ចការជំនួញ គឺជាទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ។ |

ប្រភព៖ ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា១៤។

នេះជាសំដីទាំងស្រុងដែលត្រូវបានរំលងពាក្យខ្លះមិនពាក់ព័ន្ធនឹងការពិភាក្សា

| |
|---|
| ទ្រព្យមួយចំនួនរបស់រដ្ឋ ឬរបស់សមូហភាពដែនដីសាធារណៈដែលត្រូវបានដាក់នៅក្រោមរបបគតិយុត្តពិសេស គឺជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈ។ ទ្រព្យមួយចំនួនទៀត . . . គឺជាទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ។ |

សញ្ញាចុចបី ". . ." នេះបញ្ជាក់ថាពាក្យខ្លះត្រូវបានរំលងហើយពីព្រោះវាមិនសូវសំខាន់ និងមិនពាក់ព័ន្ធនឹងការពិភាក្សា។

**សំដីទាំងស្រុងវែងដែលជាកថាខណ្ឌមួយ ឬច្រើន**

> សិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងកំលុងពេលនៃសម្បទាន គឺជាសិទ្ធិដែលទទួលស្គាល់ដូចកម្មសិទ្ធិករ លើកលែងតែការផ្ទេរសិទ្ធិ។ សម្បទានិកមានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច។
>
> សម្បទានិកអាចការពារដីដែលបានផ្តល់ជាសម្បទានឲ្យខ្លួនចំពោះការទន្ទ្រាន ឬការប៉ះពាល់ ទោះជាតាមរូបភាពណាក៏ដោយ។
>
> សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួនធ្វើការរៀបចំដាំដុះស្របតាមគោលបំណងនៃសម្បទាន។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទានធ្វើឲ្យប៉ះពាល់ដល់រចនាសម្ព័ន្ធធម្មជាតិ និងធ្វើអាជីវកម្មដែលមានលក្ខណៈជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ។

ប្រភព៖ ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៥៦។

ខាងក្រោមនេះជាសំដីទាំងស្រុងដែលមានកថាខណ្ឌច្រើន ដែលក្នុងនោះ កថាខណ្ឌខ្លះត្រូវបានរំលង។

> សិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងកំលុងពេលនៃសម្បទាន គឺជាសិទ្ធិដែលទទួលស្គាល់ដូចកម្មសិទ្ធិករ លើកលែងតែការផ្ទេរសិទ្ធិ។ សម្បទានិកមានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច។
>
> . . . .
>
> សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួនធ្វើការរៀបចំដាំដុះស្របតាមគោលបំណងនៃសម្បទាន។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទានធ្វើឲ្យប៉ះពាល់ដល់រចនាសម្ព័ន្ធធម្មជាតិ និងធ្វើអាជីវកម្មដែលមានលក្ខណៈជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ។

សញ្ញាចុចបួន ". . . ." នេះបញ្ជាក់ថាកថាខណ្ឌខ្លះត្រូវបានរំលងហើយ ពីព្រោះវាមិនសូវសំខាន់ និងមិនពាក់ព័ន្ធនឹងការពិភាក្សា។

## 1.1.2. ការដកស្រង់សំដីទាំងស្រុងដោយមិនដាក់ក្នុងអព្ភន្តរសញ្ញា ប៉ុន្តែបញ្ជាក់ប្រភព




សំដីទាំងស្រុងមិននៅក្នុងអព្ភន្តរសញ្ញា តែបញ្ជាក់ប្រភព

### សំដីទាំងស្រុង

| |
|---|
| បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និងមាត្រា៣១នៃច្បាប់នេះ។ |

ប្រភព៖ ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៤២។

> ច្បាប់ភូមិបាលកម្ពុជាឆ្នាំ២០០១ មានចរិតអធ្យាស្រ័យដល់ពលរដ្ឋរបស់ខ្លួនដែលខកខានមិនបានចុះបញ្ជីដីរបស់ខ្លួននៅមុនច្បាប់ភូមិបាលចូលជាធរមាន នៅតែមានសិទ្ធិដែលត្រូវបានការពារដោយច្បាប់ដដែល។ បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាច នៃមាត្រា២៩ មាត្រា៣០ និងមាត្រា៣១នៃច្បាប់នេះ។[1]
>
> 1. ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៤២។

ប្រយោគទី២ជាសំដីទាំងស្រុង តែមិនត្រូវបានដាក់នៅក្នុងអព្តន្តរសញ្ញាទេ ទោះមានបញ្ជាក់ប្រភពក៏ដោយ វាជាការលួចគំនិតអ្នកដទៃ។

### 1.1.3. ការដកស្រង់សំដីទាំងស្រុងដោយផ្នែកខ្លះនៅក្នុងអព្តន្តរសញ្ញា និងផ្នែកខ្លះនៅក្រៅអព្តន្តរសញ្ញា ទោះមានបញ្ជាក់ប្រភពក៏ដោយ



**សំដីទាំងស្រុង**

ជាមួយរាស្ត្រប្រជា មន្ត្រីរាជការប្រភេទណា ក្របខ័ណ្ឌណា ឬឋានន្តរស័ក្តិកំរិតណាក៏ដោយ រមែងតែមានស្មារតីថា ខ្លួននៅក្នុងក្រុមសង្គមមួយ ដោយឡែកនិងខ្ពស់ជាងរាស្ត្រធម្មតា ពីព្រោះក្រុមខ្លួនមានអំណាចសាធារណៈ សំរាប់ប្រតិបត្តិការ ទោះបីក្នុងកំរិតប៉ុណ្ណា ក៏ដោយ។

ខាងលើនេះជាសំដីទាំងស្រុង ដែលត្រូវបានដកស្រង់ចេញពីសៀវភៅវិទ្យាសាស្ត្ររដ្ឋបាល ទំព័រ១៥៣ និពន្ធដោយបណ្ឌិត សាយ បូរី បោះពុម្ពនៅឆ្នាំ២០០៧។

ទាំងអស់ខាងក្រោមនេះជាសំដីទាំងស្រុង ប៉ុន្តែផ្នែកខ្លះនៅក្នុងអព្ភន្តរសញ្ញា និងផ្នែកខ្លះទៀតនៅក្រៅអព្ភន្តរសញ្ញាទៅវិញ ដូច្នេះវាជាការលួចគំនិតអ្នកដទៃ។

″ជាមួយរាស្ត្រប្រជា មន្ត្រីរាជការប្រភេទណា ក្របខ័ណ្ឌណា ឬឋានន្តរស័ក្តិ[កម្រិត]ណាក៏ដោយ រមែងតែមានស្មារតីថាខ្លួននៅក្នុងក្រុមសង្គមមួយ ដោយឡែកនិងខ្ពស់ជាងរាស្ត្រធម្មតា″ ពីព្រោះក្រុមខ្លួនមានអំណាចសាធារណៈ [សម្រាប់]ប្រតិបត្តិការ ទោះបីក្នុង[កម្រិត]ប៉ុណ្ណាក៏ដោយ។[1]

1. សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១៥៣។

## 1.2 ការប្រើប្រាស់ពាក្យពេចន៍ខ្លួនឯងដោយយោងទៅលើប្រភពអ្នកដទៃ តែមិនបញ្ជាក់ប្រភព




### ឯកសារដើម

កាលណាគុណភាពនៃការសិក្សានិងការអប់រំចុះអន់ សមត្ថភាពមន្ត្រីក៏ចុះអន់ខ្សោយទៅតាមហ្នឹងដែរ។ អាយុជីវិតនគររឹងមាំ ឬមិនរឹងមាំក៏អាស្រ័យទៅលើគុណភាពនៃការសិក្សា និងការអប់រំបណ្តុះបណ្តាលនេះ។ គេមិនត្រូវលេងសើចនឹងបញ្ហានេះឡើយ។ បើគេយកអ្នកឥតមានសញ្ញាប័ត្រត្រឹមត្រូវតាមជំនាញ ឬក៏យកចំណេះវិជ្ជាតិចជាងសិស្ស ទៅបង្រៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីរាជការដោយគ្រាន់តែសំអាងទៅលើឋានៈនយោបាយ ក្នុងបក្សនោះ គេប្រាកដជានឹងផលិតបានតែមន្ត្រីដែលគ្មានសមត្ថភាពជាមិនខានឡើយ។ សញ្ញាប័ត្រនឹងមានតម្លៃ លុះត្រាតែគ្រូមានតម្លៃខាងចំណេះវិជ្ជាយ៉ាងពិតប្រាកដដែរ។

*វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា*

ប្រភព៖ សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១០០។

ខាងក្រោមនេះ ជាការប្រើពាក្យពេចន៍ខ្លួនឯងដោយយោងទៅលើប្រភពដទៃ តែអ្នកសរសេរមិនបានបញ្ជាក់ប្រភពដើម ដូច្នេះវាជាការលួចគំនិតអ្នកដទៃ។

ល្បះទី១នេះជាគំនិតរបស់អ្នកសរសេរ ហើយល្បះនេះអាចដើរតួនាទីជាប្រយោគចម្បងផង។

គុណភាពនៃការអប់រំមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងការអភិវឌ្ឍប្រទេសជាតិ។ កាលណាការអប់រំមិនមានគុណភាព គេមិនអាចកសាងមន្ត្រីដែលមានសមត្ថភាពឡើយ។

ល្បះទី២នេះជាពាក្យពេចន៍ខ្លួនឯងដោយយោងទៅលើប្រភព សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ១០០។ ប៉ុន្តែការសរសេរនេះមិនបានបញ្ជាក់ប្រភពទេ ដូច្នេះវាជាការលួចគំនិតអ្នកដទៃ។

ក្នុងប្រអប់ខាងក្រោមនេះ អ្នកនិពន្ធបានប្រើពាក្យពេចន៍ផ្ទាល់ខ្លួនដោយយោងទៅលើប្រភពអ្នកដទៃ តែមិនបានបញ្ជាក់ប្រភពដើម ដូច្នេះវាត្រូវបានគេចាត់ទុកថាជាការលួចគំនិតអ្នកដទៃ។

នៅឆ្នាំ ១៨៧៣ ផលប្រយោជន៍របស់កូសាំងស៊ីនក្រោមទាំងមូល ដែលរួមមានខេត្តចូវ ដុក ត្រូវតែដើរមុខផលប្រយោជន៍របស់ប្រទេសដែលស្ថិតនៅក្រោមការការពារ។

ប្រភព៖ សារិន ឆាក, *ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្តាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម)* (ភ្នំពេញ៖ ឥន្ទ្រទេវី, ២០០៤), ១៦៥។

រីឯ ការទារយកពន្ធដារផ្សេងៗក៏បានកើតមានផងដែរ ដើម្បីចំណាយខាងសេវាសាធារណៈនេះ ឱ្យបានជាទៀងទាត់ ។ ការទារយកពន្ធដារនៅសម័យនោះ ត្រូវបានគេធ្វើឡើងដូចជា :

-ពន្ធលើខ្លួន

-ពន្ធលើផលិតផល ដូចជា ស្រូវ ស្ករ ម្រេច និង សត្វឃាដ

-ពន្ធលើសកម្មភាពអសីលធម៌ ដូចជា គ្រឿងស្រវឹង ល្បែង អាភៀន

ប្រភព៖ កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា, រៀបរៀង, *សេចក្តីផ្តើមនៃនីតិខ្មែរ* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ៥៤។

ចាប់តាំងពីសតវត្សទី១៦ មានការរីកចំរើនខ្លះក្នុងការរៀបចំប្រព័ន្ធតុលាការនេះ បើទោះបីគេនៅតែយល់ថា ព្រះរាជាគឺជាអ្នកផ្តល់យុត្តិធម៌ក៏ពិតមែន ។ ព្រះរាជាបានរៀបចំបង្កើតឱ្យមានជាសាលាជំរះក្តី ហើយបើសិនជាព្រះមហាក្សត្រជាអ្នកកាត់ក្តីដោយព្រះអង្គឯងវិញ ទ្រង់អាចកោះហៅ មន្ត្រី ឬ ចៅក្រមដែលបានជំនុំជំរះនៅដំណាក់កាលដំបូងមកសាកសួរ ។

ប្រភព៖ កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា, រៀបរៀង, *សេចក្តីផ្តើមនៃនីតិខ្មែរ* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ៥៥។

នៅក្នុងសម័យកាលនោះ ដោយសារមានបញ្ហាដែលព្រះបាទចន្ទរាជា មិនព្រមលើកសួយសារអាករទៅថ្វាយស្តេចសៀម ក៏បានធ្វើឱ្យស្តេចនេះលើកទ័ពមកឈ្លានពានមកលើប្រទេសកម្ពុជាម្តងហើយម្តងទៀត តែត្រូវទទួលការបរាជ័យយ៉ាងអាម៉ាស ជាពិសេសនៅពេលនោះកងទ័ពសៀមត្រូវបានកងទ័ពខ្មែរ បង្រ្កាបឱ្យដកថយទៅប្រទេសខ្លួនវិញ ឯខ្លះទៀតក៏បានចាប់ខ្លួនជាឈ្លើយសឹកនៅក្រុងមហានគរនេះ ។ ដោយសារជោគជ័យនេះហើយដែលនាំឱ្យរាជការខ្មែរនៅជំនាន់នោះបានប្តូរឈ្មោះទីនោះថា "ខេត្តសៀមរាប" វិញ ។

ប្រភព៖ កៅ មុយថង, មុនី វីរៈ និងវ៉ាន់ ច័ន្ទតារា, រៀបរៀង, *សេចក្តីផ្តើមនៃនីតិខ្មែរ* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧), ៧៣។

ជាទូទៅ គេសង្កេតឃើញរាជសម្បត្តិត្រូវបានបន្តពីបិតាជាក្សត្រទ្រង់រាជ្យទៅបុត្រ បានសេចក្តីថានៅពេលដែលព្រះបិតាសោយទិវង្គតទៅ ឬក៏ដាក់រាជ្យ គឺបុត្រច្បងត្រូវមានសិទ្ធិឡើងសោយរាជ្យស្នង ហើយប្រសិនបើបុត្រច្បងត្រូវសុគតមុនសោយរាជ្យ គឺបុត្របន្ទាប់មានសិទ្ធិសោយរាជ្យស្នងព្រះបិតា។ ដោយហេតុនេះហើយទើបយើងឃើញ ព្រះ***នារាយណ៍រាជា*** ឡើងសោយរាជ្យស្នងព្រះ ***បរមរាជាទី ២ ចៅពញាយ៉ាត*** ព្រះ ***សត្ថាទី១*** សោយរាជ្យស្នងព្រះ***បរមរាជាទី៤*** ឯ***ព្រះបរមរាជាទី៤*** បានសោយរាជ្យស្នងពីព្រះ***ចន្ទរាជា*** ព្រោះបុត្រច្បងនាម ***រាមា ធិបតី*** បានសុគតមុនសោយរាជ្យ (តាមរាជពង្សាវតារខ្លះថាត្រូវព្រះធរណីស្រូប) ។

ប្រភព៖ ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ* (ភ្នំពេញ, ១៩៧៣), ១៨១។

ជាការពិត កំនើនសេដ្ឋកិច្ចនាសតវត្សទី២០ បានឈានដល់ដំណាក់កាលមួយដែលគួរអោយព្រួយបារម្ភនៅឆ្នាំ១៩៩៨ មានកំនើនរហូតដល់ទៅ ៣៩.០០០.០០០លានដុល្លា បើប្រៀបធៀបទៅនឹងលទ្ធផលឆ្នាំ១៩០០ខុសគ្នា១៧ដង។ ផលិតផលឧស្សាហកម្មក្នុងអំឡុងពេលនេះ បានកើនឡើងចំនួន៥០ដង ហើយទំហំ៤ភាគ៥នៃទំហំនេះ កើនឡើងចាប់ពីឆ្នាំ១៩៥០មក។ ជាលទ្ធផលគ្រាន់តែក្នុងអំឡុងពេល៧៥ឆ្នាំគេត្រូវការថាមពលលើសពីមុន១១ដង (ប្រេងលើសពី ១០០ដង) ដែកថែប-២៥ដង អាលុយមីញ៉ូម-២៣ន់ដង។ល។ ទាំងអស់នេះគឺជាទំងន់យ៉ាងធ្ងន់ធ្ងរ សម្រាប់បរិយាកាសជីវិតនៅលើផែនដី និងសម្បត្តិធម្មជាតិ ដែលនាំអោយប៉ះពាល់បរិដ្ឋាន ដូចដែលបាននិយាយពីលើរួចមកហើយ។ សេដ្ឋកិច្ចសកលលោក និងបរិស្ថានសកលលោកស្ថិតនៅក្នុងទំនាក់ទំនងនឹងគ្នាយ៉ាស្អិតរមួត។

ប្រភព៖ ដៀប សុផល, *បញ្ហាប្រឈមមុខនៅក្នុងទំនាក់ទំនងអន្តរជាតិក្រោយសង្គ្រាមត្រជាក់* (ភ្នំពេញ៖ សុខលាភ, ២០០៧), ២២៥។

តាមទិន្នន័យនាទសវត្សឆ្នាំ៨០ គេបានឃើញប្រទេស "South" ចំនួន២៥ប្រទេស មានកំរិតសេដ្ឋកិច្ចខ្ពស់ ដែលមានប្រជាជន២៤,៩% នៃប្រជាជនប្រទេសតតីយលោកទាំងអស់។ ចំពោះប្រទេសដែលគេចាត់ទុកកំរិតមធ្យមក្នុងចំណោមប្រទេស "South" មាន៥៤ប្រទេស ដែលក្នុងនោះមានប្រជាជន២៤,៩% ហើយទំហំសេដ្ឋកិច្ចមានកំរិត ២,៤ទាបជាងកំរិតទី១។ រីឯក្រុមទីបី ៣៦ប្រទេសមានប្រជាជន ៦០,៨% មានកំរិតសេដ្ឋកិច្ច៥,៤ដងទាបជាងក្រុមទីមួយ។ នៅពាក់កណ្ដាលទសវត្សឆ្នាំ៩០ ចំណូលមធ្យមរបស់ប្រជាជនក្រុមប្រទេសទី១ (១៩ប្រទេស-ប្រជាជន១២,៥%) មានកំរិតខ្ពស់ជាងក្រុមទី២ចំនួន ២,៩ដង ហើយខ្ពស់ជាងក្រុមទីបីចំនួន១២,២ដង។

ប្រភព៖ ដៀប សុផល, *បញ្ហាប្រឈមមុខនៅក្នុងទំនាក់ទំនងអន្តរជាតិក្រោយសង្គ្រាមត្រជាក់* (ភ្នំពេញ៖ សុខលាភ, ២០០៧), ២៩៣។

រចនាបថ **ប្រាសាទអណ្ដែត** មានរយៈកាលជំនាន់រចនាបថ **ព្រៃក្មេង** ដែរ ។ ក្រោយពីព្រះបាទ **ភវវរ្ម័នទី ២** សោយទិវង្គតទៅ ព្រះបាទ **ជ័យវរ្ម័នទី ១** (៦៥៧-៦៨១) ដែលជាបុត្របានឡើងសោយរាជ្យនៅមុនឆ្នាំ ៦៥៧ ។ ព្រះអង្គបានពង្រីក និងពង្រឹងអំណាចរបស់ព្រះអង្គនៅក្នុងឥណ្ឌូចិនភាគខាងត្បូង ។ គេឃើញមាននូវសិលាចារឹក និងប្រាសាទជាច្រើនដែលបានសាងសង់នៅក្នុងរជ្ជកាលនេះ ។

ប្រភព៖ ហង់ ជួន ណារ៉ុន, *ប្រាសាទព្រះវិហារ* (ភ្នំពេញ៖ ព្រះវិហារ, ២០០៩), ២១។

ឧទាហរណ៍ទាំងអស់ខាងលើនេះ ដោយមិនគិតពីកំហុសអក្ខរាវិរុទ្ធ ជាការលួចគំនិតអ្នកដទៃ ពីព្រោះព័ត៌មានទាំងឡាយត្រូវបានយោង ឬដកស្រង់ពីប្រភពដទៃ តែមិនបានបញ្ជាក់ប្រភពនោះ។ គួរកត់សម្គាល់ថា ទោះ

បើអ្នកនិពន្ធ ឬអ្នកស្រាវជ្រាវ អះអាងថាខ្លួនបានសរសេរអត្ថបទខាងលើដោយប្រើគំនិតរបស់ខ្លួនឯងក៏ដោយ ក៏នៅតែជាកំហុសដដែលនៅក្នុងពិភពសិក្សា ពីព្រោះគំនិតខ្លួនឯងត្រូវមានមូលដ្ឋានច្បាស់លាស់។ វាមិនដូចគ្នានឹងការសរសេររឿងបែបប្រលោមលោកទេ ដែលក្នុងនោះអ្នកនិពន្ធតែងធ្វើយ៉ាងណាឲ្យអ្នកអានជក់ចិត្ត ចាប់អារម្មណ៍ និងចង់តាមដានសាច់រឿងរហូតដល់ចប់ ដោយមិនចាំបាច់បញ្ជាក់ពីប្រភពអ្វីឡើយ។

## 2. **កំហុសផ្ទាល់ខ្លួនក្នុងការយោងទៅលើប្រភពអ្នកដទៃ**

### 2.1. **កំហុសផ្ទាល់ខ្លួននៃការស្រង់សំដីទាំងស្រុង**

ពេលខ្លះ អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវដកស្រង់សំដីរបស់គេមិនបានត្រឹមត្រូវទេ ពោលគឺមានកំហុសមួយចំនួនដូចជាបាត់ពាក្យ ខុសអក្ខរាវិរុទ្ធ ឬបាត់បន្ទាត់ណាមួយជាដើម ដោយមិនមានសញ្ញាណាមួយច្បាស់លាស់បញ្ជាក់ដល់អ្នកអាន។ កំហុសបែបនេះមិនឋិតនៅក្នុងការលួចគំនិតអ្នកដទៃទេ វាជាកំហុសផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវតែប៉ុណ្ណោះ។

**ឯកសារដើម**

> ពេលខ្ញុំបានស្តាប់ដំណឹងដ៏សែនរន្ធត់នេះ ខ្ញុំបានរត់គៀសខ្លួនទៅជ្រកកោនឯក្រុងហាណូយ ប្រទេសវៀតណាមរួចទៅហើយ ។ ពេលនេះខ្ញុំឃើញរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម គេបានតាក់តែងពិធីជប់លៀងអបអរជ័យជំនះ ១៧ មេសា ១៩៧៥ របស់បដិវត្តកម្ពុជា។ ចំពោះរូបខ្ញុំនៅពេលនេះមានការតូចចិត្ត ចំពោះការធ្វើពិធីអបអរសាទរ និងជូនពរជ័យជំនះរបស់បដិវត្តកម្ពុជា ពីព្រោះជោគជ័យរបស់ប្រជាជនបដិវត្តកម្ពុជាជាប្រទេសមួយផ្សេងគ្នា តើហេតុអ្វីបានជារដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមជប់លៀងអបអរសាទរជ័យជំនះនេះ ដែលមិនមែនជាជ័យជំនះរបស់គេសោះ?។ ប៉ុន្តែខ្ញុំយល់ថា នេះជាទស្សនៈរបស់រដ្ឋាភិបាលសង្គមនិយមវៀតណាមទេ រីឯប្រេកទ្វាឈឺចាប់ និងព្រាត់និរាសរបស់ប្រជាពលរដ្ឋកម្ពុជាបានកំពុងធ្លាក់មកលើប្រជាពលរដ្ឋទូទាំងប្រទេស ហើយមានតែប្រជាពលរដ្ឋកម្ពុជាខ្លួនឯងទេដែលជាអ្នកយល់ការឈឺចាប់របស់ខ្លួន ច្បាស់ជាងជនណាទាំងអស់។

ខាងក្រោមនេះជាការដកស្រង់សំដីទាំងស្រុងចេញពីប្រភពខាងលើ ប៉ុន្តែមានកំហុសអចេតនារបស់ខ្លួន។

> លោកប៉ែន សុវណ្ណបានចាកចេញទៅប្រទេសវៀតណាមរួចហើយនៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានចូលកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គាត់បានមើលឃើញយ៉ាងច្រើនពីទស្សនៈរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងទុក្ខសោកនៃប្រជាពលរដ្ឋខ្មែរ។
>
> ពេលខ្ញុំបានស្តាប់ដំណឹងដ៏សែនរន្ធត់នេះ ខ្ញុំបានរត់កៀសខ្លួនទៅជ្រកកោនឯក្រុងហាណូយ ប្រទេសវៀតណាមរួចទៅហើយ។ ពេលនេះខ្ញុំឃើញរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម គេបានតាក់តែងពិធីជប់លៀងអបអរជ័យជំនះ ១៧ មេសា ១៩៧៥ របស់បដិវត្តកម្ពុជា។ ចំពោះរូបខ្ញុំនៅពេលនេះមានការតូចចិត្ត ចំពោះការធ្វើពិធីអបអរសាទរ និងជូនពរជ័យជំនះរបស់បដិវត្តកម្ពុជា ពីព្រោះរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមជប់លៀងអបអរសាទរជ័យជំនះនេះ ដែលមិនមែនជាជ័យជំនះរបស់គេសោះ?។ ប៉ុន្តែខ្ញុំយល់ថា នេះជាទស្សនៈរបស់រដ្ឋាភិបាលសង្គមនិយមវៀតណាមទេ រីឯច្រកទ្វារឈឺចាប់ និងព្រាត់និរាសរបស់ប្រជាពលរដ្ឋកម្ពុជាបានកំពុងធ្លាក់មកលើប្រជាពលរដ្ឋទូទាំងប្រទេស ហើយមានតែប្រជាពលរដ្ឋកម្ពុជាខ្លួនឯងទេដែលជាអ្នកយល់ការឈឺចាប់របស់ខ្លួន ច្បាស់ជាងជនណាទាំងអស់។[1]
>
> 1. ប៉ែន សុវណ្ណ និងនាង សារុន, *ប៉ែន សុវណ្ណ៖ ជីវប្រវត្តិសង្ខេប និងបុព្វហេតុជាតិមាតុភូមិកម្ពុជា* (វ៉ាស៊ីងតោន៖ ចក្ខុវិស័យខ្មែរ, ២០០២), ១៣៦-១៣៧។

ស្នាដៃខាងលើនេះ ត្រូវបានកែតម្រូវអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវ ដូចជាពាក្យដើមសរសេរ "ទ្វា" កែមកជា "ទ្វារ" ដែលជាពាក្យត្រឹមត្រូវ។ អ្នកនិពន្ធបានសរសេរត្រឹមត្រូវតាមទម្រង់សំដីទាំងស្រុង និងបញ្ជាក់ប្រភពច្បាស់លាស់ ប៉ុន្តែបានចម្លងឡើងវិញដោយបាត់១បន្ទាត់ដើមរបស់វា គឺ

បាត់ពាក្យ "ជោគជ័យរបស់ប្រជាជនបដិវត្តកម្ពុជាជាប្រទេសមួយផ្សេងគ្នា តើហេតុអ្វីបានជា" នៅត្រង់បន្ទាត់ទី៦ នៃឯកសារដើម។ ដូច្នេះ ការស្រង់សំដីដើមខាងលើនេះមិនមែនជាការលួចគំនិតរបស់អ្នកដទៃទេ តែវាគ្រាន់ជាកំហុសផ្ទាល់ខ្លួនរបស់អ្នកនិពន្ធតែប៉ុណ្ណោះ។

**ឯកសារដើម**

**គ. ឥណ្ឌាបានចេញពីតំបន់ណាខ្លះ**?

រឿងនេះពិបាកបញ្ជាក់ ព្រោះក្រៅពីអត្ថបទ៣សរសេរជាភាសាទមិឡហើយដែលមានកាលកំណត់ថ្មីៗនេះ គេឃើញមានតែឯកសារជាសំស្ក្រឹតដែលជាភាសាគេប្រើទូទៅនៅប្រទេសឥណ្ឌា។ បើគេពិនិត្យឯកសារឥណ្ឌាដែលទាក់ទងនឹងការធ្វើនាវាចរណ៍ កំណត់ហេតុរបស់អ្នកធ្វើដំណើរចិនឈ្មោះទីកន្លែង អក្សរបុរាណបុរាណវត្ថុ គេនឹងឃើញថាពិតមែនហើយថាប្រទេសឥណ្ឌាខាងត្បូងជាពិសេសតំបន់ Kanchi (Conjeveram) បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សាយអរិយធម៌ឥណ្ឌានៅអាស៊ីអាគ្នេយ៍ តែតំបន់ផ្សេងៗទៀតនៃប្រទេសឥណ្ឌា (ខ្ពង់រាបទក្សិណ វាលទំនាបទន្លេគង្គា និងឥណ្ឌាភាគពាយព្យ) សុទ្ធតែបានចូលរួមចំណែកតិចឬច្រើនក្នុងព្រឹត្តិការណ៍ខាងលើទាំងអស់។

ប្រភព៖ ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ* (ភ្នំពេញ, ១៩៧៣), ៣៧។

ខាងក្រោមនេះជាការដកស្រង់សំដីទាំងស្រុងចេញពីប្រភពខាងលើមានកំហុសអចេតនាមួយកើតឡើង។

បញ្ហាប្រវត្តិសាស្ត្រប្រទេសអាស៊ីអាគ្នេយ៍មានទំនាក់ទំនងយ៉ាងជិតស្និទ ជាមួយប្រទេសឥណ្ឌា ដូចមានបញ្ជាក់ក្នុងស្នាដៃ ត្រឹង ងា ថា "បើគេពិនិត្យឯកសារឥណ្ឌាដែលទាក់ទងនឹងការធ្វើនាវាចរណ៍ កំណត់ហេតុរបស់អ្នកធ្វើដំណើរចិនឈ្មោះទីកន្លែង អក្សរបុរាណ បុរាណវត្ថុ គេនឹងឃើញថាពិតមែន ហើយថាប្រទេសឥណ្ឌាខាងជើង ជាពិសេសតំបន់ Kanchi (Conjeveram) បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សាយ អរិយធម៌ឥណ្ឌានៅអាស៊ីអាគ្នេយ៍ តែតំបន់ផ្សេងៗទៀតនៃប្រទេសឥណ្ឌា (ខ្ពង់រាបទក្សិណ វាលទំនាបទន្លេគង្គា និងឥណ្ឌាភាគពាយព្យ) សុទ្ធតែបានចូលរួមចំណែកតិចឬច្រើនក្នុងព្រឹត្តិការណ៍ខាងលើទាំងអស់។"[1]

1. ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ* (ភ្នំពេញ, ១៩៧៣), ៣៧។

ស្នាដៃខាងលើនេះមានការដកស្រង់សំដីទាំងស្រុងនៅក្នុងអព្ភន្តរសញ្ញា ចេញពីប្រភព "ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ៖ ពីដើមដល់ការបោះបង់ក្រុងអង្គរ* (ភ្នំពេញ, ១៩៧៣), ៣៧" និងបញ្ជាក់ប្រភពដើមនេះត្រឹមត្រូវ។ ប៉ុន្តែបើពិនិត្យផ្ទៀងផ្ទាត់នឹងសំណៅឯកសារដើម គេឃើញមានកំហុសត្រង់ពាក្យ "ឥណ្ឌាខាងជើង" នៅក្នុងឯកសារថ្មីនេះ មិនមាននៅក្នុងឯកសារដើមទេ ពោលគឺមានតែពាក្យ "ឥណ្ឌាខាងត្បូង" វិញ។ អ្នកនិពន្ធបានសរសេរដោយមានកំហុសអចេតនាលើពាក្យនេះតែម្តង។ ដូច្នេះវាជាកំហុសផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ មិនមែនជាការលួចគំនិតអ្នកដទៃទេ។

## 2.2. **កំហុសផ្ទាល់ខ្លួននៃការប្រើពាក្យពេចន៍ផ្ទាល់ខ្លួនដោយយោងទៅនឹងប្រភពដទៃ ប៉ុន្តែយោងខុស**

ពេលខ្លះ ការយោងទៅលើប្រភពឯកសារដទៃដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួន អាចខុសនឹងអត្ថន័យនៃប្រភពដើមរបស់វា ទោះជាមានបញ្ជាក់ប្រភពដើមច្បាស់លាស់ក៏ដោយ។ វាជាកំហុសផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ ឬអ្នកសរសេរ ពោលគឺមិនមែនជាការលួចគំនិតអ្នកដទៃទេ។ ការយោងបែបនេះអាចបណ្តាលមកពីអ្នកយោងយល់អត្ថន័យដើមមិនច្បាស់ ហើយក៏ប្រើពាក្យពេចន៍ដែលមិនមានអត្ថន័យដូចគ្នាទៅវិញ។ ដើម្បីជៀសវាងបញ្ហានេះ អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវអាចប្រើសំដីទាំងស្រុងជំនួសវិញ ទើបអាចប្រាកដបានថា ការយោងគឺមិនខុសនឹងអត្ថន័យនៃប្រភពដើម។

**ឯកសារដើម**

> វចនានុក្រម ជាច្បាប់ដែលយើងត្រូវប្រតិបត្តិតាម គឺសរសេរឲ្យត្រូវតាមទាំងអស់គ្នា។ ការណ៍ដែលត្រូវសរសេរតាមវចនានុក្រមនេះ យើងទាំងអស់គ្នាត្រូវតែធ្វើទៅ ដោយគោរពដល់វិន័យ (discipline)។ វិន័យត្រង់នេះមានសារៈសំខាន់ដល់ជាតិជាច្រើន ព្រោះថាបើយើងនៅតែសរសេររូបពាក្យតាមចិត្តរៀងខ្លួន ផ្សេងគ្នាទៅតាមវត្ត តាមសាលាដូចពីដើម ភាសាយើងនឹងរាប់ថាជាភាសាសម្រាប់ជាតិមួយពុំបាន; ជាតិយើងក៏នឹងរាប់ថាជាប្រជាជាតិ (nation) មួយពុំសម។ ហេតុនេះសូមឲ្យបងប្អូនរួមជាតិទាំងឡាយ ព្យាយាមសរសេរពាក្យតាមរូបដែលមានក្នុងវចនានុក្រមឲ្យបានជារបៀបដូចគ្នាទាំងអស់ ហើយសូមឲ្យមានសេចក្តីខ្មាសអៀនក្នុងចិត្តកាលណាបើសរសេរភ្លាត់ប្លាតខុសពីរូបពាក្យក្នុងវចនានុក្រម ដ្បិតសរសេរខុសដូច្នេះជាហេតុសំដែងឲ្យឃើញថា យើងខ្វះសេចក្តីសិក្សា។ ខ្ញុំសង្ឃឹមថាមុខជាបងប្អូនទាំងឡាយគង់ទុកការសរសេររូបពាក្យដោយត្រឹមត្រូវតាមវចនានុក្រមនេះ ...។

ប្រភព៖ អៀវ កើស, *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល,* បោះពុម្ពឡើងវិញ (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ២០០១), ១៨។

ខាងក្រោមនេះជាការប្រើពាក្យពេចន៍ដោយខ្លួនឯង ដោយយោងទៅនឹងប្រភព "អៀវ កើស, *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល,* បោះពុម្ពឡើងវិញ (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ២០០១), ១៨" ប៉ុន្តែយោងខុសមិនត្រឹមត្រូវតាមប្រភពដើម។

> អក្សរសាស្ត្រខ្មែរនាពេលបច្ចុប្បន្ននេះ ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់អ្នកអភិរក្សអក្សរសាស្ត្រខ្មែរ ជាពិសេសរាជបណ្ឌិត្យសភា។ ទោះជាយ៉ាងណាក៏ដោយ គេតែងសង្កេតឃើញនិន្នាការអក្សរសាស្ត្រខ្មែរ នៅក្នុងសៀវភៅសិក្សាចំណោះទូទៅមានភាពមិនស្របគ្នានឹងនិន្នាការអក្សរសាស្ត្រខ្មែរដែលរៀបចំចងក្រងដោយរាជបណ្ឌិត្យសភា។ ទាក់ទងនឹងបញ្ហានេះ លោក អៀវ កើស មានសំណូមពរឲ្យប្រជាពលរដ្ឋខ្មែរចេះខ្មាសអៀនផងប្រសិនបើខ្លួនសរសេរពាក្យខុសពីវចនានុក្រម បើពុំនោះទេ ពួកគេនឹងត្រូវចាត់ទុកថាជាជនមិនចេះអក្សរ។[1]
>
> ---
>
> 1. អៀវ កើស, *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល,* បោះពុម្ពឡើងវិញ (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ២០០១), ១៨។

ប្រភពដែលយោងនៅក្នុងល្បះទី៣នៅក្នុងស្នាដៃខាងលើនេះគឺយោងឯកសារដើមរបស់លោក អៀវ កើស ក្នុងសៀវភៅដែលមានចំណងជើងថា "ភាសាខ្មែរ" និងចំណងជើងរង "ការល្បងពិនិត្យដោយរកហេតុផល" បោះពុម្ពឡើងវិញនៅឆ្នាំ២០០១ ដោយពុទ្ធសាសនបណ្ឌិត្យ ទំព័រទី១៨។ បើពិនិត្យជាក់ស្តែងទៅលើឯកសារដើម បន្ទាត់ទី៦ដល់ទី១០ ត្រូវបានសរសេរដូចតទៅនេះ "ហេតុនេះសូមឲ្យបងប្អូនរួមជាតិទាំងឡាយព្យាយាមសរសេរពាក្យតាមរូបដែលមានក្នុងវចនានុក្រម ឲ្យបានជារបៀបដូចគ្នាទាំងអស់ ហើយសូមឲ្យមានសេចក្តីខ្មាសអៀនក្នុងចិត្ត កាលណាបើ

សរសេរភ្លាត់ប្លាតខុសពីរូបពាក្យក្នុងវចនានុក្រម ដ្បិតសរសេរខុសដូច្នេះ ជាហេតុសំដែងឲ្យឃើញថា យើងខ្វះសេចក្តីសិក្សា។" អត្ថន័យនៃពាក្យ នៅក្នុងអព្ភន្តរសញ្ញាមិនមានន័យថា "លោក អៀវ កើស មានសំណូមពរ ឲ្យប្រជាពលរដ្ឋខ្មែរចេះខ្មាសអៀនផង ប្រសិនបើខ្លួនសរសេរពាក្យខុសពី វចនានុក្រម បើពុំនោះទេ ពួកគេនឹងត្រូវចាត់ទុកថាជាជនមិនចេះអក្សរ" នោះទេ គឺលោក អៀវ កើស គ្រាន់តែចង់និយាយថា អ្នកដែលមិនបាន សរសេរតាមវចនានុក្រមជាពួកដែលមិនបានស្វែងយល់អក្សរសាស្ត្រខ្មែរ តែប៉ុណ្ណោះ។ ដូច្នេះ ការយោងដោយប្រើពាក្យពេចន៍ខ្លួនឯងខាងលើនេះ គឺខុសនឹងអត្ថន័យដើម វាជាកំហុសផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ ឬអ្នកស្រាវ ជ្រាវ មិនមែនជាការលួចគំនិតអ្នកដទៃទេ។

ដើម្បីជៀសវាងការយោងដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួនខុស គេ អាចស្រង់វាជាសំដីទាំងស្រុងតែម្តងក៏បាន ដូចលើកឡើងខាងក្រោមនេះ តែម្តង។

> អក្សរសាស្ត្រខ្មែរនាពេលបច្ចុប្បន្ននេះ ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ពីសំណាក់អ្នកអភិរក្សអក្សរសាស្ត្រខ្មែរ ជាពិសេសរាជបណ្ឌិត្យសភា។ ទោះជា យ៉ាងណាក៏ដោយ គេតែងសង្កេតឃើញនិន្នាការអក្សរសាស្ត្រខ្មែរ នៅក្នុង សៀវភៅសិក្សាចំណេះទូទៅមានភាពមិនស្របគ្នានឹងនិន្នាការអក្សរសាស្ត្រខ្មែរ ដែលរៀបចំចងក្រងដោយរាជបណ្ឌិត្យសភា។ ទាក់ទងនឹងបញ្ហានេះ លោក អៀវ កើស មានសំណូមពរឲ្យប្រជាពលរដ្ឋខ្មែរឲ្យ "ព្យាយាមសរសេរពាក្យតាម រូបដែលមានក្នុងវចនានុក្រមឲ្យបានជារបៀបដូចគ្នាទាំងអស់ ហើយសូមឲ្យ មានសេចក្តីខ្មាសអៀនក្នុងចិត្ត កាលណាបើសរសេរភ្លាត់ប្លាតខុសពីរូបពាក្យ ក្នុងវចនានុក្រម ដ្បិតសរសេរខុសដូច្នេះ ជាហេតុសំដែងឲ្យឃើញថា យើងខ្វះ សេចក្តីសិក្សា។"[1]
>
> ---
>
> 1. អៀវ កើស, *ភាសាខ្មែរ៖ ការល្បងពិនិត្យដោយរកហេតុផល,* បោះពុម្ព ឡើងវិញ (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ២០០១), ១៨។

ចំពោះការយោងទៅលើប្រភពដទៃ ដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួនអ្នកនិពន្ធ ឬអ្នកស្រាវជ្រាវគប្បីអានឲ្យយល់នូវអត្ថន័យដើមរបស់វាឲ្យបានច្បាស់លាស់ជាមុនសិន ដើម្បីជៀសវាងនូវកំហុសផ្ទាល់ខ្លួនក្នុងការប្រើប្រាស់ពាក្យពេចន៍របស់ខ្លួន ដោយយោងទៅលើប្រភពដទៃនោះ។ ការយោងទៅលើឯកសារបរទេស ដោយប្រើពាក្យពេចន៍ខ្លួនឯង អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវគប្បីអានឲ្យយល់អត្ថន័យច្បាស់ និងពិនិត្យមើលសទិសន័យរបស់វាក្នុងវចនានុក្រមឲ្យបានជាក់ច្បាស់សិន ប្រសិនបើចាំបាច់ ថាតើអាចប្រើន័យមួយណាឲ្យសមស្របទៅនឹងអត្ថន័យដើមរបស់វា ជំនួសនូវពាក្យណាមួយដែលចាំបាច់។

ចំពោះសំដីទាំងស្រុងដែលត្រូវបានដកស្រង់ចេញពីប្រភពដើម ជាភាសាបរទេស គប្បីបញ្ជាក់ថាឯកសារនោះបកប្រែដោយអ្នកណា។ បើបកប្រែដោយខ្លួនឯង គ្រាន់តែដាក់នៅក្នុងសញ្ញាឃ្នាបថា [បកប្រែ] ឬបើបកប្រែដោយអ្នកផ្សេង ត្រូវសរសេរក្នុងសញ្ញាឃ្នាបថា [បកប្រែដោយ + ឈ្មោះអ្នកបកប្រែ] ដូចជា [បកប្រែដោយ នេត រតនា] ជាដើម។

> ពាក្យទ្រព្យត្រូវបានគេផ្តល់និយមន័យផ្សេងៗគ្នា។ លោក James Penner យល់ថា "ទ្រព្យត្រូវបានគេពិពណ៌នាថាជាបណ្តុំនៃសិទ្ធិផ្សេងៗគ្នា ដូចជាសិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់ សិទ្ធិប្រើអស់ សិទ្ធិកម្ទេចចោល សិទ្ធិចាត់ចែង សិទ្ធិឲ្យគេ សិទ្ធិឲ្យគេខ្ចី សិទ្ធិលក់ជាដើម [បកប្រែ]។"[1] រីឯ Black's Law Dictionary ផ្តល់និយមន័យទ្រព្យក្នុងន័យទី១ជា "សិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលនូវទ្រព្យកំណត់ណាមួយ; សិទ្ធិកម្មសិទ្ធិ [បកប្រែ]។"[2]
>
> ---
>
> 1. James E. Penner, *The Idea of Property in Law* [គំនិតនៃទ្រព្យក្នុងច្បាប់] (New York: Oxford University Press, 1997), 1-2។
> 2. Bryan A. Garner, *Black's Law Dictionary,* បោះពុម្ពលើកទី៨ (St. Paul, Minn: West Group, 2004), 1252។

ការសរសេរពាក្យបកប្រែក្នុងសញ្ញាឃ្នាបដូចឧទាហរណ៍ខាងលើនេះ មានន័យថាអ្នកនិពន្ធ ឬអ្នកស្រាវជ្រាវនៃឯកសារនេះជាអ្នកបកប្រែដោយខ្លួនឯងផ្ទាល់។

ប៉ុន្តែ ប្រសិនបើអ្នកបកប្រែជាអ្នកផ្សេង គេត្រូវសរសេរដូចខាងក្រោមនេះ។

ពាក្យទ្រព្យត្រូវបានគេផ្តល់និយមន័យផ្សេងៗគ្នា។ លោក James Penner យល់ថា "ទ្រព្យត្រូវបានគេពិពណ៌នាថាជាបណ្តុំនៃសិទ្ធិផ្សេងៗគ្នា ដូចជាសិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់ សិទ្ធិប្រើអស់ សិទ្ធិកម្ទេចចោល សិទ្ធិចាត់ចែង សិទ្ធិឲ្យគេ សិទ្ធិឲ្យគេខ្ចី សិទ្ធិលក់ជាដើម [បកប្រែដោយ ជា ផានិត]។"[1] រីឯ Black's Law Dictionary ផ្តល់និយមន័យទ្រព្យក្នុងន័យទី១ជា "សិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលនូវទ្រព្យកំណត់ណាមួយ; សិទ្ធិកម្មសិទ្ធិ [បកប្រែដោយ កន សំណាង]។"[2]

1. James E. Penner, *The Idea of Property in Law* [គំនិតនៃទ្រព្យក្នុងច្បាប់] (New York: Oxford University Press, 1997), 1-2។
2. Bryan A. Garner, *Black's Law Dictionary,* បោះពុម្ពលើកទី៨ (St. Paul, Minn: West Group, 2004), 1252។

ការបញ្ជាក់ពីឈ្មោះអ្នកបកប្រែដូចខាងលើនេះ គឺជាទង្វើមួយល្អបំផុតក្នុងពិភពសិក្សា ពីព្រោះវាទាមទារឲ្យមានសេចក្តីស្មោះត្រង់ក្នុងការសិក្សា ឬគុណធម៌នៃការសិក្សាស្រាវជ្រាវ ដែលត្រូវការរំឭកដល់ម្ចាស់ដើម ឬសំដែងនូវការដឹងគុណ ឬអរគុណដល់ម្ចាស់ដើម រាល់ពេលណាដែលការពិភាក្សាពាក់ព័ន្ធនឹងស្នាដៃរបស់គេ។

# ការសរសេរសង្ខេបសេចក្ដី

(Writing an Abstract)

សង្ខេបសេចក្ដីនៃនិក្ខេបបទ គឺជាសេចក្ដីសង្ខេបដ៏ខ្លីមួយដែលពន្យល់ពីអំណះអំណាងចម្បង ប្រធានបទ ឬរបកគំហើញ។ ជាទូទៅសង្ខេបសេចក្ដីផ្ដល់ឲ្យអ្នកអាននូវការបញ្ជាក់ខ្លីមួយ អំពីខ្លឹមសារនៃនិក្ខេបបទ។ អ្នកអានស្ទើរតែមិនចាំបាច់មើលនៅក្នុងនិក្ខេបបទទាំងមូលដើម្បីយល់នូវអ្វីដែលត្រូវបាននិយាយនៅក្នុងសង្ខេបសេចក្ដីនោះ។

សង្ខេបសេចក្ដីគួរតែខ្លី ហើយងាយស្រួលយល់ និងងាយអាន។ ជាធម្មតា សង្ខេបសេចក្ដីអាចមានមួយទំព័រ ឬតិចជាង។ គេអាចសរសេរវាតែមួយកថាខណ្ឌ ឬ៤កថាខណ្ឌ អាស្រ័យទៅតាមតម្រូវការរបស់អត្ថបទ។

ក្នុងករណីសរសេរតែមួយកថាខណ្ឌ វាត្រូវវែងបន្តិច ហើយត្រូវគ្របដណ្ដប់វត្ថុបំណង និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ លទ្ធផល និងអនុសាសន៍។

ក្នុងករណីសរសេរឲ្យងាយអាន គេត្រូវសរសេរជា៤កថាខណ្ឌទៅតាមផ្នែកនីមួយៗ ពោលគឺ៖

**កថាខណ្ឌទី១ វត្ថុបំណង និងវិសាលភាពនៃកិច្ចការស្រាវជ្រាវ**

សរសេរពីវត្ថុបំណងនៃការស្រាវជ្រាវ។ អ្វីដែលអ្នកព្យាយាមស្វែងរក។

*ឧទាហរណ៍* គោលបំណងនៃការសិក្សានេះគឺដើម្បី... (ធ្វើអត្តសញ្ញាណ, ស្វែងរក, បញ្ជាក់ ជាដើម)
គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បី...

**កថាខណ្ឌទី២ ការពិពណ៌នាអំពីវិធីសាស្ត្រដែលបានប្រើក្នុង**

**ការស្រាវជ្រាវ**

និយាយពីវិធីនៃការស្រាវជ្រាវដែលអ្នកបានធ្វើ។ ប្រសិនបើការស្រាវជ្រាវទាមទារឲ្យមានការសម្ភាស ឬការស្ទង់មតិ ត្រូវបញ្ជាក់អ្នកដែលត្រូវសម្ភាស ចំនួន និងមូលហេតុនាំឲ្យមានការសម្ភាស។

*ឧទាហរណ៍* កម្រងសំណួរចំនួនមួយរយសែសិបប្រាំបួនត្រូវបានសួរដល់អ្នកតាំងទីលំនៅថ្មី។

**កថាខណ្ឌទី៣ ការសង្ខេបនៃលទ្ធផល (របកគំហើញ)**

សរសេរពីអ្វីដែលអ្នកបានរកឃើញនៅក្នុងការស្រាវជ្រាវរបស់អ្នក វាមិនមែនជាគំនិតផ្ទាល់ខ្លួនទេ។

*ឧទាហរណ៍* លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា ប្រព័ន្ធចុះបញ្ជីដីធ្លីនៅកម្ពុជាមិនទាន់ជោគជ័យនៅឡើយទេ។ អំណាចប្រមូលផ្ដុំក្នុងការសម្រេចចេញប័ណ្ណតាមរយៈការចុះបញ្ជី ដីធ្លីមានលក្ខណៈដាច់ដោយដុំ បានធ្វើឲ្យប្រព័ន្ធចុះបញ្ជីដីកាន់តែមាននីតិវិធីស្មុគស្មាញ ប្រើរយៈពេលវែង និងចំណាយខ្ពស់ ដូច្នេះហើយ វាបានរាំងអ្នកកាន់កាប់ដីមិនឲ្យចូលរួមក្នុងការចុះបញ្ជីដីរបស់ពួកគេ។

**កថាខណ្ឌទី៤ អនុសាសន៍**

អាចទាញនូវសេចក្ដីសន្និដ្ឋាន និង/ឬផ្ដល់អនុសាសន៍។

*ឧទាហរណ៍* តាមរយៈរបកគំហើញខាងលើ ការស្រាវជ្រាវនេះបានលើកឡើងនូវអនុសាសន៍ មួយចំនួន។

គួរកត់សម្គាល់ថា ការសរសេរសង្ខេបសេចក្ដីត្រូវបានធ្វើឡើងនៅក្រោយពេលសរសេរនិក្ខេបបទរួច ចំណែកកាលដែលត្រូវប្រើគឺអតីតកាល។ គេមិនប្រើសព្វនាមបុរិសៈ ដូចជា "ខ្ញុំ" ឬ "យើង" ទេ តែគេប្រើ "អ្នកនិពន្ធ" ជំនួសវិញ។ ជាមួយគ្នានេះដែរ សង្ខេបសេចក្ដីមិនត្រូវសរសេរជាអក្សរកាត់ទេ ប៉ុន្តែបើគេត្រូវការប្រើពាក្យនោះច្រើនដងបន្តបន្ទាប់ គេអាចសរសេរជាអក្សរពេញមួយសិន ដោយបញ្ជាក់អក្សរកាត់របស់វា រួចក្រោយមកទើបគេអាចប្រើអក្សរកាត់នោះបាន។

បណ្ឌិត ហាប់ ផល្ងី

# ការសរសេរនិក្ខេបបទ

និក្ខេបបទនីមួយៗគួរមានសេចក្ដីផ្ដើម ការពិភាក្សា សេចក្ដីសន្និដ្ឋាន និងអនុសាសន៍។ គេអាចដាក់សេចក្ដីផ្ដើមនៅក្នុងជំពូកទី១ក៏បាន។ ការពិភាក្សាគឺជាសាច់រឿងខ្លឹមនៃនិក្ខេបបទទាំងមូលពោលគឺអាចសរសេរជាច្រើនជំពូកក៏បាន។ ការបកស្រាយអំណះអំណាង និងលទ្ធផលនៃការសិក្សាគឺបិតក្នុងជំពូកទាំងនេះ។ រីឯសេចក្ដីសន្និដ្ឋានអាចដាក់នៅក្នុងជំពូកមួយផ្សេងទៀតក៏បាន។

ជាទូទៅ និក្ខេបបទអាចមានរចនាសម្ព័ន្ធដូចខាងក្រោម៖

## ជម្រើសទី១

ក្របមុខ
សេចក្ដីថ្លែងអំណរគុណ
អារម្ភកថា
សង្ខេបសេចក្ដី
សេចក្ដីថ្លែងអំណះអំណាង (ទៅតាមសាកលវិទ្យាល័យ)
មាតិកា
បញ្ជីតារាង (បើមាន)

អក្សរកាត់ (បើមាន)
សេចក្តីផ្តើម
ជំពូកទី១
ជំពូកទី២
ជំពូកទី៣
. . . .
សេចក្តីសន្និដ្ឋាន
អនុសាសន៍
គន្ថនិទ្ទេស/ឯកសារយោង
ឧបសម្ព័ន្ធ (បើមាន)

## ជម្រើសទី២

ក្របមុខ
សេចក្តីថ្លែងអំណរគុណ
អារម្ភកថា
សង្ខេបសេចក្តី
សេចក្តីថ្លែងអំណះអំណាង (ទៅតាមសាកលវិទ្យាល័យ)
មាតិកា
បញ្ជីតារាង (បើមាន)
អក្សរកាត់ (បើមាន)

ជំពូកទី១ សេចក្តីផ្តើម

ជំពូកទី២

ជំពូកទី៣

. . . .

ជំពូកទី៦ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គន្ថនិទ្ទេស/ឯកសារយោង

ឧបសម្ព័ន្ធ (បើមាន)

ក្រសួងអប់រំ យុវជន និងកីឡា តម្រូវឲ្យសេចក្តីផ្តើមគ្របដណ្តប់ចំណុចដូចតទៅ៖

- លំនាំបញ្ហា
- ចំណោទបញ្ហានៃការស្រាវជ្រាវ
- គោលបំណងនៃការស្រាវជ្រាវ
- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ
- សារៈសំខាន់នៃការស្រាវជ្រាវ
- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

យើងអាចបញ្ចូលវិធីសាស្ត្រស្រាវជ្រាវនៅក្នុងសេចក្តីផ្តើមនេះក៏បាន ដោយរៀបរាប់គ្រួសៗនូវវិធីសាស្ត្រដែលយើងស្រាវជ្រាវ។